វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទេសន្តរប្រវេសន៍ មិនស្របច្បាប់ពីកម្ពុជា

## លក្ខណៈសម្គាល់ បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង



http://www.camnews.org/2011/06/29/


http://www.traffickingproject.org/2009/07/migrant-fishermen-fall-through-cracks.html

ហ៊ីង វុត្ថា លន់ ពិដេ និង ផាន់ ដាលីស

ឯកសារពិភាក្សាលេខ ៥៨

ខែតុលា ២០១១

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# ទេសន្តរប្រវេសន៍មិនស្របច្បាប់ ពីកម្ពុជា

## លក្ខណៈសម្គាល់ បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង

**ឯកសារពិភាក្សាលេខ ៥៨**

**ហ៊ីង វុត្ថា លន់ ពិដេ និង ផាន់ ដាលីស**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខែតុលា ២០១១ ភ្នំពេញ កម្ពុជា**

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

© **រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះដែលអាចយកទៅចម្លងទុកឬផ្សព្វផ្សាយតាមទម្រង់និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វបសអ ។

ISBN-10: 99950–52–51-5

**ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា៖** លក្ខណៈសម្គាល់ បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង

**Irregular Migration from Cambodia: Characteristics, Challenges and Regulatory Approach**

**ហ៊ីង វុត្ថា  លន់ ពិដេ  និង ផាន់ ដាលីស**

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។*

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh    http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និងយូ-សិទ្ធីរិទ្ធ

បកប្រែដោយ៖ សំរិត សូផា

បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព ស៊ុន ហ៊ាង រាជធានីភ្នំពេញ

# មាតិកា


បញ្ជីពាក្យបំព្រួញ ..... v

សេចក្តីថ្លែងអំណរគុណ ..... vii

ខ្លឹមសារសង្ខេប ..... 1

**១. សេចក្តីផ្តើម** ..... 5

១.១ សាវតារ ..... 5

១.២ គោលបំណងនៃការសិក្សា ..... 6

១.៣ ក្របខ័ណ្ឌទស្សនទាន ..... 6

១.៤ វិធីសាស្ត្រស្រាវជ្រាវ ..... 7

១.៥ រចនាសម្ព័ន្ធនៃរបាយការណ៍ ..... 8

**២. ទម្រង់នៃទេសន្តរប្រវេសន៍មិនស្របច្បាប់ កម្ពុជា** ..... 9

២.១ សេចក្តីសង្ខេបអំពីទេសន្តរប្រវេសន៍ការងារជាអន្តរជាតិរបស់កម្ពុជា ..... 9

២.២ ទេសន្តរប្រវេសន៍ក្រៅផ្លូវការៈ និយមន័យ និងស្ថានភាព ..... 9

២.៣ លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃជនទេសន្តរប្រវេសន៍មិនស្របច្បាប់ កម្ពុជា ..... 11

**៣. មូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់** ..... 15

**៤. បញ្ហា និងការប្រឈមនៃទេសន្តរប្រវេសន៍មិនស្របច្បាប់** ..... 19

**៥. ក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័ន** ..... 23

៥.១ គោលនយោបាយ ..... 23

៥.២ ក្របខ័ណ្ឌច្បាប់ ..... 24

៥.៣ ក្របខ័ណ្ឌស្ថាប័ន ..... 26

**៦. វិធីសាស្ត្រកសាងក្របខ័ណ្ឌច្បាប់គ្រប់គ្រងទេសន្តរប្រវេសន៍មិនស្របច្បាប់** ..... 29

៦.១ ការដោះស្រាយមូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់ ..... 29

៦.២ កិច្ចការពារ និងសុខុមាលភាពរបស់ពលករទេសន្តរប្រវេសន៍ ..... 31

៦.៣ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ..... 32

**៧. សេចក្តីសន្និដ្ឋាន** ..... 35

**ឯកសារយោង** ..... 36

**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន** CDRI ..... 45

# បញ្ជីតារាង

តារាង ១៖ លក្ខណៈនៃភូមិបានធ្វើអង្កេត........8
តារាង ២៖ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ នៅប្រទេសថៃ តាមផ្នែកឧស្សាហកម្ម ឆ្នាំ២០០៩........10
តារាង ៣៖ គ្រួសារ និងសមាជិកធ្វើទេសន្តរប្រវេសន៍........11
តារាង ៤៖ ជនទេសន្តរប្រវេសន៍ទៅកាន់ទីដៅសំខាន់ៗ តាមប្រភេទ និងយេនឌ័រ........12
តារាង ៥៖ ជនទេសន្តរប្រវេសន៍តាមប្រភេទការងារ និងទីដៅ........12
តារាង ៦៖ លក្ខណៈនៃជនទេសន្តរប្រវេសន៍ និងជនមិនមែនទេសន្តរប្រវេសន៍........12
តារាង ៧៖ ចំណាយប្រើប្រាស់មធ្យមប្រចាំថ្ងៃ និង តម្លៃទ្រព្យសម្បត្តិ........13

# តារាងឧបសម្ព័ន្ធ

A. **ឧបសម្ព័ន្ធផ្នែកស្ថិតិ**........38
តារាង A ១៖ ពលករទេសន្តរប្រវេសន៍កម្ពុជាដែលបានបញ្ជូនទៅក្រៅជាផ្លូវការ........38
តារាង A ២៖ បញ្ជីរាយមុខចំណាយលើការបញ្ជូនពលករទៅប្រទេសថៃ........38
តារាង A ៣៖ បញ្ជីរាយនាមអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករដែលទទួលអាជ្ញាប័ណ្ណ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១០........39
**ឧបសម្ព័ន្ធ** B៖ **អនុក្រឹត្យលេខ ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស**........40

# បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| FGD | ការពិភាក្សាតាមក្រុមគោលដៅ (Focus Group Discussion) |
| GMS | មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) |
| ILO | អង្គការពលកម្មអន្តរជាតិ (International Labour Organization) |
| IOM | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (International Organization for Migration) |
| UNIAP | អន្តរទីភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (United Nations Inter-Agency Project on Human Trafficking) |
| UNIFEM | មូលនិធិអភិវឌ្ឍស្ត្រីនៃអង្គការសហប្រជាជាតិ (United Nations Development Fund for Women) |

# សេចក្តីថ្លែងអំណរគុណ


របាយការណ៍នេះបង្ហាញពី ការងារថ្មីមួយស្តីពីទេសន្តរប្រវេសន៍កម្លាំងពលកម្មឆ្លងកាត់ព្រំដែន ធ្វើឡើងដោយក្រុមស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ដែលរួមមាន លោក ហ៊ីង វុត្ថា និង លោក លន់ ពិដេ ជាអ្នកស្រាវជ្រាវ និង កញ្ញា ផាន់ ដាលីស ជាជំនួយការស្រាវជ្រាវ ដោយមានការគាំទ្រហិរញ្ញវត្ថុពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍអន្តរជាតិ (IDRC) ។ អ្នកនិពន្ធ និង CDRI សូមសម្តែងនូវកត្តញ្ញូតាធម៌ចំពោះ IDRC ដែលបានផ្តល់ការគាំទ្រដ៏សប្បុរសដល់គម្រោងនេះ។

អ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណជូនឯកឧត្តម ហេង សួ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានផ្តល់មតិយោបល់ដ៏ថ្លៃថ្លាស្តីពីគោលនយោបាយទេសន្តរ ប្រវេសន៍ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ក្នុងពេលផ្តល់បទសម្ភាសន៍យ៉ាងស៊ីជម្រៅដល់ក្រុមស្រាវជ្រាវ។ អ្នកនិពន្ធក៏សូមសម្តែងនូវកត្តញ្ញូតាធម៌ចំពោះលោក Bruno Maltoni អ្នកសម្របសម្រួលគម្រោងនៃអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅកម្ពុជា លោក លីម ទិត អ្នកសម្របសម្រួលថ្នាក់ជាតិនៃ គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP) លោកស្រី ទូស សោភ័ណ អតីតអ្នកសម្របសម្រួលគម្រោងនៃអង្គការពលកម្មអន្តរជាតិ (ILO) លោកស្រី Deepa Bharathi អ្នកគ្រប់គ្រងកម្មវិធីនៃ មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM) នៅការិយាល័យតំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងលោក អន ប៊ុនហាក់ ប្រធានសមាគមក្រុមហ៊ុនជ្រើសរើសពលករកម្ពុជា ដែលបានជួយផ្តល់មតិយោបល់ក្នុងពេលជួបប្រជុំពិគ្រោះយោបល់ជាមួយក្រុមស្រាវជ្រាវ ។ អ្នកនិពន្ធបានទទួលព័ត៌មានដ៏មានប្រយោជន៍ ស្តីពីទេសន្តរប្រវេសន៍គ្មានឯកសារ និងបញ្ហាប្រឈមនានាក្នុងទេសន្តរប្រវេសន៍ពីអ្នកផ្តល់ព័ត៌មានទាំងឡាយ ក្នុងអំឡុងពេលចុះស្រាវជ្រាវដល់កន្លែង ហើយសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការចូលរួមវិភាគទានដ៏ថ្លៃថ្លានេះ។

# ខ្លឹមសារសង្ខេប

១. ការសិក្សានេះ ពិនិត្យពីលក្ខណៈសម្គាល់ និងឫសគល់នៃបញ្ហា ព្រមទាំងបញ្ហាប្រឈមនានា នៃការធ្វើទេសន្តរប្រវេសន៍គ្មានឯកសារផ្លូវការពីកម្ពុជា ហើយបន្ទាប់មកពិភាក្សាពីវិធីសាស្ត្ររៀបចំច្បាប់ និងជម្រើសគោលនយោបាយ សម្រាប់គ្រប់គ្រងបញ្ហានេះ។ ការសិក្សាបានប្រើវិធីសាស្ត្រចម្រុះ ដែលក្នុងនេះ មានអង្កេតលើ ៥០៧ គ្រួសារ នៅ ៦ភូមិដែលមានទេសន្តរប្រវេសន៍កម្រិតខ្ពស់ ការពិភាក្សាតាមក្រុមស្នូល ដោយមានអ្នកចូលរួមជាពលករទេសន្តរប្រវេសន៍ត្រឡប់មកស្រុកវិញ និងពលករដែលមានបំណងធ្វើទេសន្តរប្រវេសន៍ និងការធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយមន្ត្រីរដ្ឋាភិបាល អ្នកជំនាញការផ្នែកទេសន្តរប្រវេសន៍ និងមេដឹកនាំសហគមន៍មូលដ្ឋាន។

២. ទេសន្តរប្រវេសន៍កម្លាំងពលកម្មឆ្លងកាត់ព្រំដែននៅកម្ពុជាបានវិវត្តគួរឱ្យកត់សម្គាល់ក្នុង ១ ទសវត្សរ៍កន្លងទៅនេះ នៅក្រោយចលនាជនភៀសខ្លួនក្នុងទសវត្សរ៍១៩៨០ និង១៩៩០ ដោយសារសង្គ្រាមស៊ីវិល និងអស្ថិរភាពនយោបាយដែលបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចជាតិ និងការចិញ្ចឹមជីវិតរបស់ប្រជាជន។ ការវិវត្តនាពេលថ្មីៗ បានធ្វើឱ្យកម្ពុជាស្ថិតនៅក្រោយគេក្នុងការងារគ្រប់គ្រង និងដំណើរការរដ្ឋបាលលើទេសន្តរប្រវេសន៍ពលកម្ម ដោយមានគោលនយោបាយ និងក្របខ័ណ្ឌស្ថាប័នទន់ខ្សោយ និងគ្មានប្រសិទ្ធភាព។ គោលនយោបាយទេសន្តរប្រវេសន៍ពលកម្ម បានកំណត់ឡើងនាពេលថ្មីៗបំផុត ហើយកំពុងស្ថិតក្នុងដំណាក់កាលចាប់ផ្តើម ហើយខ្វះភាពរលូនគ្នា។ ច្បាប់ និងបទបញ្ញត្តិមានដោយចោះៗ មានតិចនៅឡើយ និងគ្របដណ្តប់មិនបានទូលំទូលាយទេ។ កង្វះខាតការទទួលខុសត្រូវច្បាស់លាស់ កង្វះការសម្របសម្រួល និងកង្វះធនធាននិងសមត្ថភាព ជាបញ្ហារួមនៅក្នុងបណ្តាស្ថាប័នដែលទទួលខុសត្រូវលើការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម។

៣. ទេសន្តរប្រវេសន៍គ្មានឯកសារ ដែលត្រូវបានកំណត់ថា ជាចលនាខុសច្បាប់ ដើម្បីទៅធ្វើការនៅប្រទេសមួយទៀត ឬជាចលនាដោយគ្មានការអនុញ្ញាតដើម្បីទៅធ្វើការ គឺជាទម្រង់ពេញនិយមបំផុតក្នុងចំណោមពលករកម្ពុជាដែលស្វែងរកការងារនៅក្រៅប្រទេស ដោយគេមើលឃើញថា មានសុវត្ថិភាពគួរសម ងាយស្រួល និងមានតម្លៃថោក ព្រោះពុំចាំបាច់រង់ចាំយូរ គ្មានទាមទារឯកសារ និងគ្មាននីតិវិធីជ្រើសរើសស្មុគស្មាញទេ។ ការជ្រើសរើសពលករក្រៅផ្លូវការ អាចចែកចេញជាពីរប្រភេទ។ ប្រភេទទី១ ការធ្វើទេសន្តរប្រវេសន៍ចម្ងាយជិតតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ តាមធម្មតា វិធីនេះផ្តល់ការងារក្នុងវិស័យកសិកម្ម ដែលជនទេសន្តរប្រវេសន៍បានដឹងពីមគ្គុទេសក៍ជាជនទេសន្តរប្រវេសន៍ មិត្តភ័ក្តិ ឬអ្នកភូមិ។ មគ្គុទេសក៍ទាំងនេះ សម្របសម្រួលការផ្តល់ការងារ និងបង្កើតជាបណ្តាញតភ្ជាប់គ្រួសារនានានៅតាមជនបទ ទៅនឹងគោលដៅនៅប្រទេសថៃ។ បន្ទុកចំណាយលើការធ្វើទេសន្តរប្រវេសន៍ប្រែប្រួលពី ៣,០០ ដល់ ៥,៥០ដុល្លារអាមេរិក។ ប្រភេទទី២ គឺទេសន្តរប្រវេសន៍ចម្ងាយឆ្ងាយទៅប្រទេសថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់ ឬកម្មកររោងចក្រ។ ក្នុងករណីភាគច្រើន ជនទេសន្តរប្រវេសន៍ ធ្វើដំណើរជាក្រុមតូចៗ ដោយមានជនជាមេខ្យល់ ជូនដំណើរឆ្លោះទៅកន្លែងធ្វើការ។ ជនទេសន្តរប្រវេសន៍ត្រូវបង់កម្រៃជួយសម្រួលការជាមុន ចំនួនពី ១០០ ដល់ ២០០ដុល្លារអាមេរិក។

៤. ទេសន្តរប្រវេសន៍គ្មានឯកសារត្រឹមត្រូវ បង្កឡើងដោយមូលហេតុជាច្រើនតាំងពី ភាពក្រីក្ររ៉ាំរ៉ៃ ភាពគ្មានការងារធ្វើ និងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងសហគមន៍ដើម រហូតដល់គោលនយោបាយអន្តោប្រវេសន៍រឹតបន្តឹងនៅក្នុងប្រទេសទទួលពលករ និងដំណើរការស្របច្បាប់ជ្រើសរើសពលករមានតម្លៃខ្ពស់ ស្មុគស្មាញ និងចំណាយពេលយូរ។ កត្តាចម្បងគេ គឺកង្វះលទ្ធភាពដោះស្រាយចំណាយលើការជ្រើសរើសតាមផ្លូវច្បាប់។ គ្រួសារជនទេសន្តរប្រវេសន៍គ្មានឯកសារភាគច្រើន គឺមានស្ថានភាពសេដ្ឋកិច្ចលំបាកជាង ជនទេសន្តរប្រវេសន៍មានឯកសារត្រឹមត្រូវ និងមានកម្រិតជីវភាពទាបជាងបន្ទាត់ភាពក្រីក្រ។ ការជ្រើសរើសតាមផ្លូវច្បាប់នេះ ក្រៅពីមានតម្លៃខ្ពស់ (៧០០ដុល្លារអាមេរិកទៅប្រទេសថៃ) វាថែមទាំងយឺតយ៉ាវទៀត ចំណែកឯការជ្រើសរើសក្រៅផ្លូវការត្រូវចំណាយពេលតែ ៣-៤ ថ្ងៃ និងត្រូវការឯកសារតិចតួច ឬគ្មានសោះ។

៥. ជនទេសន្តរប្រវេសន៍កម្ពុជាដែលគ្មានឯកសារកំពុងកើនឡើង ក្នុងនេះ មួយចំនួនបានទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ច ដែលរួមមាន ការយាយីផ្លូវភេទ និងរូបកាយ លក្ខខណ្ឌចងកូនបំណុល និងការគំរាមកំហែងរាយការណ៍ដល់អាជ្ញាធរ ដោយពុំមានលទ្ធភាពទទួលបានកិច្ចការពារផ្នែកច្បាប់ និងមួយចំនួនបានក្លាយជាជនរងគ្រោះដោយការជួញដូរមនុស្ស។ តាមព័ត៌មានពី UNIAP (2010) ក្នុងមួយឆ្នាំៗមានប្រជាជនកម្ពុជារាប់ពាន់នាក់ ត្រូវបានគេជួញដូរទៅប្រទេសថៃ។ ជារឿយៗ បុរសគេជួញដូរឱ្យទៅធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់ក្នុងលក្ខខណ្ឌដ៏លំបាកលំបិន ចំណែកឯស្ត្រីវិញ គេជួញដូរឲ្យទៅធ្វើការក្នុងឧស្សាហកម្មកំសាន្ត រួមទាំងពេស្យាចារផង។

៦. ហេតុអ្វីបានជារដ្ឋត្រូវមានគោលនយោបាយស្ដីពីទេសន្តរប្រវេសន៍មិនស្របច្បាប់? ទេសន្តរប្រវេសន៍អន្តរជាតិ ជាពិសេស ទេសន្តរប្រវេសន៍គ្មានឯកសារផ្លូវការ កំពុងបង្កើនកង្វល់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងសន្តិសុខសម្រាប់ប្រទេសមួយចំនួននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក (សេចក្ដីប្រកាសក្រុងបាងកក)។ ទេសន្តរប្រវេសន៍គ្មានឯកសារចោទបញ្ហាដល់កិច្ចការពារ ពីព្រោះជនទេសន្តរប្រវេសន៍គ្មានឯកសារជាច្រើននាក់ បានទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ច ដោយមានការការពារតាមផ្លូវច្បាប់ និងសង្គមតែតិចតួច ឬគ្មានសោះ។ ទេសន្តរប្រវេសន៍ក្រៅផ្លូវការ ក៏ចោទបញ្ហាផ្នែកគ្រប់គ្រងដែរ ទាំងនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល។ តាមលក្ខណៈផ្ទាល់នៃទេសន្តរប្រវេសន៍នេះ ដែលប្រជាជនទៅធ្វើការក្នុងប្រទេសទីដៅ ដោយពុំមានឯកសារស្របច្បាប់តំរូវឡើងដោយប្រទេសនោះ ដូច្នេះគេជួបការពិបាកក្នុងការពិនិត្យតាមដាន និងផ្ដល់សេវាកម្មការពារសង្គម និងសេវាកម្មគាំទ្រសំខាន់ៗ។

៧. តើរដ្ឋត្រូវដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ក្រៅផ្លូវការដោយវិធីណា? គេបានឯកភាពគ្នាជាអន្តរជាតិមួយថា បញ្ហាទេសន្តរប្រវេសន៍គ្មានឯកសារនេះ ត្រូវតែដោះស្រាយក្នុងទម្រង់ទាំងមូល និងគ្រប់ជ្រុងជ្រោយ ដោយពិនិត្យពីមូលហេតុ ព្យាយាមដោះស្រាយផលប៉ះពាល់របស់វា និងកែលម្អកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។

i. **ដោះស្រាយមូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់៖** ភាពក្រីក្របំផុត កង្វះខាតឱកាសការងារ តម្លៃខ្ពស់នៃការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ ការអនុវត្តខុសឆ្គងដោយក្រុមហ៊ុនផ្ដល់ការងារឯកជនខ្លះ និងសកម្មភាពរបស់ជនល្មើសជួញដូរ បានជំរុញឱ្យពលករកម្ពុជាធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ ហើយអន្តរាគមន៍ដោះស្រាយកត្តាជំរុញទាំងនេះ នឹងជួយកាត់បន្ថយទេសន្តរប្រវេសន៍មិនស្របច្បាប់ ។

**ក. ពង្រឹងការអភិវឌ្ឍសហគមន៍ប្រភពដើម៖** ថ្វីបើនៅពេលនេះ មិនទាន់មានភស្តុតាងជាក់ស្ដែងរឹងប៉ឹងបញ្ជាក់ពីទំនាក់ទំនងរវាងការអភិវឌ្ឍសហគមន៍ និងទេសន្តរប្រវេសន៍ក្ដី ក៏ការអភិវឌ្ឍអាចកាត់បន្ថយទេសន្តរប្រវេសន៍ ដោយជួយជំនះលើហេតុផលបង្ខំឲ្យធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ និងធ្វើឱ្យទេសន្តរប្រវេសន៍ក្លាយជាជម្រើសវិជ្ជមាន ស្របច្បាប់ ដោយសេរី។ វិធានការជាអាទិភាពរួមមាន ការបង្កើនជំនួយកសិកម្ម ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ការបង្កើនលទ្ធភាពបានប្រើប្រាស់ធនធានធម្មជាតិ និងការចូលរួមពីសហគមន៍ក្នុងការគ្រប់គ្រងធនធានទាំងនេះ ការពង្រឹងសេវាកម្មសាធារណៈជាពិសេសការអប់រំ និងសុខាភិបាល ការបណ្ដុះបណ្ដាលជំនាញសហគមន៍ និងសេវាកម្មមីក្រូហិរញ្ញវត្ថុ។ ជំនួយអភិវឌ្ឍន៍ ត្រូវផ្ដោតចំលើសហគមន៍ណាដែលមានអត្រាទេសន្តរប្រវេសន៍ខ្ពស់។

**ខ. បើកឱកាសឱ្យមានទេសន្តរប្រវេសន៍ស្របច្បាប់៖** គេបានឯកភាពគ្នាជាអន្តរជាតិដូចបានលើកឡើងក្នុងកិច្ចប្រជុំត្រីភាគីឆ្នាំ២០០៣ នៅតំបន់អាស៊ីរបស់អង្គការពលកម្មអន្តរជាតិ (ILO) នៅក្រុងបាងកកថា ឱកាសធ្វើទេសន្តរប្រវេសន៍ងាយស្រួល និងតាមផ្លូវច្បាប់ដោយមានតម្លាភាព អាចជាផ្នែកមួយនៃការឆ្លើយតបដោយមានប្រសិទ្ធភាពចំពោះការធ្វើទេសន្តរប្រវេសន៍គ្មានឯកសារ។ អាទិភាពសំខាន់បំផុតសម្រាប់ការជ្រើសរើសពលករតាមផ្លូវច្បាប់របស់កម្ពុជាគឺ ត្រូវរៀបចំនីតិវិធីរដ្ឋបាល បង្កើនល្បឿនការសម្របសម្រួល

និងកាត់បន្ថយការចំណាយ។ បន្ថែមលើការបង្កើនល្បឿនការចេញលិខិតឆ្លងដែន និងទិដ្ឋាការ របាយការណ៍នេះបង្ហាញថា ត្រូវមានការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីដំណើរការជ្រើសរើស ព្រមទាំងសោហ៊ុយ និងចំណាយផ្សេងៗដែលបានកំណត់។

**គ. រៀបចំច្បាប់គ្រប់គ្រងក្រុមហ៊ុនជ្រើសរើសពលករ៖** បច្ចុប្បន្ន អនុក្រឹត្យលេខ ៥៧ គឺជាលិខិតុបករណ៍ដ៏សំខាន់មួយ។ អនុក្រឹត្យនេះ មិនសូវច្បាស់លាស់ និងមានការគ្របដណ្តប់ធំទូលាយពេក ជាពិសេសទាក់ទិននឹងថ្លៃឈ្នួល ការបណ្តុះបណ្តាល និងការឃ្លាំមើលកន្លែងធ្វើការ ការត្រួតពិនិត្យ ការប្រតិបត្តិតាម និងការដាក់ទណ្ឌកម្ម។ ត្រូវរៀបចំច្បាប់គ្រប់គ្រងលើការជ្រើសរើស និងការផ្តល់ការងារតាមរយៈប្រព័ន្ធអាជ្ញាប័ណ្ណ ដែលត្រូវកំណត់យ៉ាងច្បាស់លាស់ពីការទទួលខុសត្រូវរបស់ក្រុមហ៊ុន លក្ខខណ្ឌជ្រើសរើស ការដាក់ទណ្ឌកម្មលើការរំលោភបំពាន និងធានាការអនុវត្តន៍។ ការធ្វើច្បាប់គួរមានចែងពីការលុបអាជ្ញាប័ណ្ណក្នុងករណីប្រព្រឹត្តខុស និងមាននីតិវិធីព្រហ្មទណ្ឌដាក់ទោសជនល្មើសធ្ងន់ធ្ងរ។

**ឃ. ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស៖** ការទប់ស្កាត់ការជួញដូរ នឹងជួយកាត់បន្ថយទេសន្តរប្រវេសន៍មិនស្របច្បាប់ និងការពារជនទេសន្តរប្រវេសន៍ឱ្យរួចផុតពីទាសភាព និងការកេងប្រវ័ញ្ចធ្ងន់ធ្ងរ។ ការស្រាវជ្រាវនេះ មិនមានបំណងបរិយាយលម្អិតពីគោលនយោបាយប្រយុទ្ធប្រឆាំងនឹងការជួញដូរទេ ប៉ុន្តែការទប់ស្កាត់បទល្មើសអាចកែលម្អបានដោយវិធានការដូចតទៅ៖ ចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមថ្នាក់តំបន់ និងធ្វើការងារកាន់តែជិតស្និទ្ធ ជាមួយប្រទេសទីដៅសំខាន់ៗ ពង្រឹងការអនុវត្តច្បាប់ កសាងសមត្ថភាពមន្ត្រីនានា បង្កើនការតស៊ូមតិ និងការលើកកម្ពស់ការយល់ដឹង។

ii. **កិច្ចការពារ និងសុខុមាលភាពរបស់ពលករទេសន្តរប្រវេសន៍៖** គេអាចការពារពលករទេសន្តរប្រវេសន៍កាន់តែប្រសើរឡើង តាមរយៈការពង្រឹងយុទ្ធនាការអប់រំ និងការពង្រីកសេវាកម្មគាំទ្រ។

**ក. ពង្រឹងការអប់រំ និងការលើកកម្ពស់ការយល់ដឹង៖** ជនទេសន្តរប្រវេសន៍ជាច្រើន ជាពិសេសអ្នកគ្មានឯកសារត្រឹមត្រូវ គឺមិនបានដឹងពីផលវិបាកជាក់ស្តែង ផលវិបាកផ្នែកច្បាប់ សង្គមកិច្ច និងសេដ្ឋកិច្ចពីការធ្វើដំណើរទៅប្រទេសមួយទៀតទេ។ គេឃើញមានព័ត៌មានកាន់តែប្រសើរជាងមុន មានន័យថា មានការពារកាន់តែប្រសើរ ដូច្នេះជាអនុសាសន៍ គួរពង្រឹងការអប់រំ និងលើកកម្ពស់ការយល់ដឹងមុនពេលពេញដំណើរ។ ព័ត៌មានអាចផ្សព្វផ្សាយតាមរយៈវិធានការចម្រុះដូចតទៅ៖

- បង្កើតមណ្ឌលធនធានទេសន្តរប្រវេសន៍ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីចុះបញ្ជីពលករទេសន្តរប្រវេសន៍ និងផ្តល់ព័ត៌មាន។ មណ្ឌលទាំងនេះ គួរដើរតួជាចំណុចកណ្តាលសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងជាទីកន្លែងដែលជនទេសន្តរប្រវេសន៍ អាចទូរស័ព្ទ ឬមកជួបដើម្បីប្រឹក្សាយោបល់។ ព័ត៌មានអាចផ្សព្វផ្សាយតាមរយៈកូនសៀវភៅ រូបភាពផ្ទាំងធំៗ ការប្រឹក្សាយោបល់ ប្រព័ន្ធផ្សព្វផ្សាយ កិច្ចប្រជុំ និងសិក្ខាសាលា។

- ត្រូវពង្រឹងយុទ្ធនាការអប់រំដោយផ្តោតលើសហគមន៍ដែលមានអត្រាទេសន្តរប្រវេសន៍មិនស្របច្បាប់កម្រិតខ្ពស់។ ដោយសារការិយាល័យពលកម្មថ្នាក់ស្រុក និងខេត្ត តែងខ្វះខាតធនធាន ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលធ្វើការនៅតាមសហគមន៍ មេភូមិ ឬមេឃុំ ព្រះសង្ឃ និងគ្រូបង្រៀន អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានដល់ជនទេសន្តរប្រវេសន៍។

**ខ. ពង្រីកសេវាកម្មគាំទ្រ៖** កន្លងមក មានកង្វះខាតការគាំទ្រដើម្បីការពារ និងផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសន៍ ជាពិសេសជនទេសន្តរប្រវេសន៍មិនស្របច្បាប់។ ការចាត់តាំងឱ្យមានអនុព័ន្ធការងារនៅប្រទេសថៃ និងម៉ាឡេស៊ី ជាវិធីមួយសម្រាប់ពង្រឹងការគាំទ្រ។ មុខងាររបស់ពួកគេ គួររួមបញ្ចូលទាំងការបង្កើតទំនាក់ទំនងការងារយ៉ាងរឹងមាំមួយជាមួយប្រទេសម្ចាស់ផ្ទះអំពីបញ្ហាការងារ ការពិនិត្យតាម

ដានចំណាត់ការផ្សេងៗ ទៅលើពលករទេសន្តរប្រវេសន៍ ការផ្តល់ជំនួយផ្លូវច្បាប់ប្រឆាំងនឹងការរំលោភកិច្ចសន្យា ការបំពាន ឬការកេងប្រវ័ញ្ច ការផ្តល់ឱវាទអំពីបញ្ហាកិច្ចសន្យា ឬការងារ និងធានាថាជនទេសន្តរប្រវេសន៍មិនស្របច្បាប់ បានទទួលកិច្ចការពារ និងការសម្របសម្រួលក្នុងពេលធ្វើមាតុភូមិនិវត្តន៍។

iii. **ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** ទេសន្តរប្រវេសន៍ជាបញ្ហាពាក់ព័ន្ធច្រើនផ្នែក ដែលត្រូវមានកិច្ចប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយ។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ អាចដោះស្រាយបានប្រសើរបំផុត ក្នុងក្របខ័ណ្ឌទ្វេភាគី និងក្របខ័ណ្ឌថ្នាក់តំបន់ ដើម្បីបំពេញបន្ថែមលើគោលនយោបាយជាតិ។

ក. **ការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី៖** សហប្រតិបត្តិការរវាងប្រទេសបញ្ជូន និងប្រទេសទទួលមានប្រសិទ្ធភាពល្អក្នុងការដោះស្រាយទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ របាយការណ៍នេះបង្ហាញថា កម្ពុជាគួរសហការថែមទៀតជាមួយប្រទេសថៃ និងម៉ាឡេស៊ី ទាំងក្នុងការរៀបចំនីតិវិធីជ្រើសរើសស្របច្បាប់ និងកម្មវិធីផ្តល់ឯកសារផ្លូវការដល់ពលករកម្ពុជាក្រៅផ្លូវការ។

ខ. **ការឈានទៅបង្កើតទីផ្សារការងារចម្រុះនៅមហាអនុតំបន់មេគង្គ** (GMS)៖ ចលនាករការងារឆ្លងកាត់ព្រំដែននៅទូទាំង GMS មានសន្ទុះខ្លាំង ប៉ុន្តែមិនទាន់មានក្របខ័ណ្ឌច្បាប់ថ្នាក់អនុតំបន់ ឬក្របខ័ណ្ឌស្ថាប័នសម្រាប់សម្របសម្រួលនៅឡើយទេ។ ឯកសារនេះផ្តល់អនុសាសន៍ឱ្យមានការធ្វើសមាហរណកម្មទីផ្សារការងារក្នុង GMS ។ ជំហានដំបូងដើម្បីសម្រេចកិច្ចការនេះ គឺត្រូវដាក់បញ្ចូលទេសន្តរប្រវេសន៍ការងារទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ GMS ហើយបន្ទាប់មក បង្កើតវេទិកាជំនាញមួយដើម្បីសិក្សាពីលទ្ធភាពអាចធ្វើបាន និងផ្តល់អនុសាសន៍ដល់មេដឹកនាំ។

គ. **សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងចលនាកម្លាំងពលកម្មដោយសេរី៖** ថ្វីបើទេសន្តរប្រវេសន៍ និងលំហូរពលករ គួរស្ថិតក្នុងចំណោមបញ្ហាជាអាទិភាពសម្រាប់អាស៊ានក្តី ប៉ុន្តែកន្លងមកមានការពិភាក្សាតិចតួចអំពីលំហូរកម្លាំងពលកម្ម ឬការធ្វើទេសន្តរប្រវេសន៍ ក្នុងកិច្ចប្រជុំនានារបស់រដ្ឋមន្ត្រីក្រសួងការងារ។ អាស៊ានគួរអនុម័តលិខិតុបករណ៍ក្របខ័ណ្ឌអាស៊ាន ជាឯកសារដាក់កាតព្វកិច្ចតាមផ្លូវច្បាប់។ អាស៊ានក៏គួរធ្វើការសំដៅឱ្យមានលំហូរកម្លាំងពលកម្មដោយសេរីនៅក្នុងតំបន់ ហើយត្រូវចាត់ទុកទេសន្តរប្រវេសន៍ជារបៀបវារៈអភិវឌ្ឍន៍ដ៏សំខាន់ ដោយជួយសម្រួលដល់ចរាចរណ៍ពលករមានជំនាញ និងគ្មានជំនាញដោយសេរី។

# ១ សេចក្តីផ្តើម

## ១.១ សាវតារ

*" ...ទេសន្តរប្រវេសន៍អន្តរជាតិ ជាពិសេសទេសន្តរប្រវេសន៍មិនស្របច្បាប់ បានក្លាយជាកង្វល់កាន់តែច្រើនឡើងលើសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងសន្តិសុខ នៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក" (សេចក្តីប្រកាសក្រុងបាងកក ស្តីពីទេសន្តរប្រវេសន៍មិនស្របច្បាប់)។*

ទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាបញ្ហារសើប ស្មុគស្មាញ និងពិបាកបំផុត ដោយប៉ះពាល់ដល់អភិបាលកិច្ចនៅថ្នាក់ជាតិ និងថ្នាក់សាកល លើទេសន្តរប្រវេសន៍ពលកម្ម (IOM 2010b)។ វាចោទបញ្ហាខាងគ្រប់គ្រងដល់ទាំងប្រទេសបញ្ជូន និងប្រទេសទទួល ពីព្រោះជារឿយៗ ការធ្វើដំណើរបានធ្វើឡើងនៅក្រៅក្របខ័ណ្ឌច្បាប់នៃប្រទេសទាំងពីរ ដូច្នេះពិបាកធ្វើការកត់ត្រា និងពិនិត្យតាមដាន។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ ក៏ចោទបញ្ហាខាងកិច្ចការពារផងដែរ។ ស្ថានភាពខុសច្បាប់ បានដាក់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ឱ្យស្ថិតក្នុងហានិភ័យធ្ងន់ធ្ងរបំផុតនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចពីសំណាក់និយោជក ហើយជារឿយៗ ពួកគេពុំបានទទួលកិច្ចការពារតាមផ្លូវច្បាប់ទេ។ ការសិក្សាជាច្រើនលើលក្ខខណ្ឌរស់នៅ និងការងាររបស់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ បានបង្ហាញពីវត្តមានកម្រិតខ្ពស់នៃការកេងប្រវ័ញ្ច ដែលជាទូទៅមានទម្រង់ជាការបោកបញ្ឆោតលើប្រាក់ឈ្នួល ប្រភេទការងារនិងស្ថានភាពផ្លូវច្បាប់ ការកាត់ប្រាក់ខែ ការដកហូតលិខិតឆ្លងដែន និងឯកសារសម្គាល់ខ្លួន ការឃុំឃាំងខ្លួន លក្ខខណ្ឌការងារក្រោមស្តង់ដារ និងការគំរាមកំហែងរាយការណ៍ដល់អាជ្ញាធរ។ ភាពធ្ងន់ធ្ងរនៃបញ្ហា បានជម្រុញឱ្យមានការពិភាក្សាដេញដោលនៅអន្តរជាតិ ពីគោលនយោបាយ និងគំនិតផ្តួចផ្តើម ដើម្បីដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់។ សេចក្តីថ្លែងការណ៍ក្រុងបាងកក ស្តីពីទេសន្តរប្រវេសន៍មិនស្របច្បាប់ ដែលទទួលការអនុម័តពីប្រទេសនានានៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ការបង្កើតវេទិកាពិគ្រោះយោបល់អន្តរជាតិជាច្រើនស្តីពីទេសន្តរប្រវេសន៍[1] និងការតស៊ូមតិ និងការផ្តល់គំនិតរបស់ទីភ្នាក់ងារឯកទេស ដូចជា អង្គការពលកម្មអន្តរជាតិ និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ក្នុងការធ្វើគោលនយោបាយថ្នាក់ជាតិ និងអន្តរជាតិជាដើម គឺជាការឆ្លើយតបដ៏សំខាន់នៅក្នុងរឿងនេះ។

នៅកម្ពុជា ទេសន្តរប្រវេសន៍ភាគច្រើនមានលក្ខណៈមិនស្របច្បាប់។ ក្រៅពីមូលហេតុធំៗ ដូចជា ភាពក្រីក្រពុំរ៉ៃ ការលំបាកលំបិនផ្នែកសេដ្ឋកិច្ចជាដើម បញ្ហាផ្សេងៗក្នុងការធ្វើទេសន្តរប្រវេសន៍ផ្លូវការ ក៏ជម្រុញឱ្យជនទេសន្តរប្រវេសន៍ជ្រើសយកមធ្យោបាយមិនស្របច្បាប់ដែរ។ អតុល្យភាពរវាងតម្រូវការពលកម្មក្នុងប្រទេសម្ចាស់ផ្ទះ និងការផ្តល់កូតាចំណាយខ្ពស់ពីដំបូង ក៏ដូចជា ការអនុវត្តខុសឆ្គងរបស់បណ្តាញជ្រើសរើសស្របច្បាប់ ក៏សុទ្ធតែជាមូលហេតុធ្លាប់បានពិនិត្យឃើញ។ ក្នុងករណីភាគច្រើន ទេសន្តរប្រវេសន៍មិនស្របច្បាប់ តែងមានការជួយសម្រួលអំពីជនទេសន្តរប្រវេសន៍ធ្លាប់មានពិសោធន៍ ឬឈ្មួញកណ្តាល ហើយដំណើរការវាងាយស្រួល និងថោកជាខ្លាំងជាងការជ្រើសរើសជាផ្លូវការ។ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ កម្ពុជាមិនបានគេចផុតពីការរំលោភបំពាន និងការកេងប្រវ័ញ្ចទេ ហើយក្នុងករណីធ្ងន់ធ្ងរបំផុត គឺត្រូវរងគ្រោះដោយការជួញដូរមនុស្សថែមទៀត។ របាយការណ៍មួយរបស់គំរោងអន្តរទីភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP) បានបង្ហាញថា បុរស ស្ត្រី និងកុមារកម្ពុជា ត្រូវបានគេជួញដូរទៅថៃ ម៉ាឡេស៊ី ម៉ាកាវ និងតៃវ៉ាន់។ បុរសគេជួញដូរឱ្យទៅធ្វើការដោយបង្ខំក្នុងវិស័យកសិកម្ម នេសាទ និងសំណង់។ ស្ត្រីគេជួញដូរទៅធ្វើអាជីវកម្មផ្លូវភេទ និងធ្វើពលកម្មដោយបង្ខំក្នុងរោងចក្រ ឬធ្វើជាអ្នកបម្រើតាមផ្ទះ។

1 កិច្ចប្រឹងប្រែងសហការ និងពិគ្រោះយោបល់ក្រៅផ្លូវការសំខាន់ៗរួមមាន គំនិតផ្តួចផ្តើម Bern កិច្ចសន្ទនាកម្រិតខ្ពស់របស់ UN ស្តីពីទេសន្តរប្រវេសន៍អន្តរជាតិ និងការអភិវឌ្ឍ វេទិកាសាកលស្តីពីទេសន្តរប្រវេសន៍និងអភិវឌ្ឍន៍ និងការពិគ្រោះយោបល់ត្រីភាគីរបស់ ILO ។

បញ្ហាទេសន្តរប្រវេសន៍មានច្រើនពាសពេញ អាចពាក់ព័ន្ធមួយចំណែកទៅនឹងកង្វះខាតគោលនយោបាយ និងច្បាប់ល្អៗ។ កម្ពុជាជាអ្នកថ្មីថ្មោងក្នុងការគ្រប់គ្រង និងដំណើរការរដ្ឋបាលលើទេសន្តរប្រវេសន៍ពលកម្ម ហើយគេមើលឃើញថា ក្របខណ្ឌច្បាប់ និងស្ថាប័ននៅកម្ពុជា នៅទន់ខ្សោយ និងគ្មានប្រសិទ្ធភាព។ ច្បាប់ផ្សេងៗនៅមានតិចមានចោះៗ និងខ្វះការគ្របដណ្តប់គ្រប់ជ្រុងជ្រោយ ជាពិសេសក្នុងការគ្រប់គ្រងដំណើរការទេសន្តរប្រវេសន៍ពលកម្ម កិច្ចការពារពលករទេសន្តរប្រវេសន៍ និងការធ្វើសមាហរណកម្មពលករដែលវិលត្រឡប់មកវិញ។ ស្ថាប័នសាធារណៈនៅខ្វះខាតការទទួលខុសត្រូវច្បាស់លាស់ ការសម្របសម្រួល ធនធានមនុស្ស និងហិរញ្ញវត្ថុ។ ភាពទន់ខ្សោយផ្នែកច្បាប់ និងស្ថាប័ន វាកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារការមិនបានគិតគូរពីបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ នៅក្នុងលិខិតុបករណ៍ក្នុងច្បាប់ជាតិ និងអន្តរជាតិជាច្រើន។

គម្លាតយ៉ាងធ្ងន់ធ្ងរក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាហេតុផលចម្បងនៃការស្រាវជ្រាវវិភាគស៊ីជម្រៅលើប្រធានបទនេះ។ ការស្រាវជ្រាវនេះ មានទិសដៅផ្តល់ការវិភាគលម្អិតលើទេសន្តរប្រវេសន៍ ដោយផ្តោតជាពិសេសលើទេសន្តរប្រវេសន៍មិនស្របច្បាប់ ការវាយតម្លៃពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងការផ្តល់គំនិតពីជម្រើសផ្សេងៗ សម្រាប់ដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ឲ្យបានកាន់តែប្រសើរ។

## ១.២ គោលបំណងនៃការសិក្សា

ការសិក្សានេះមានបំណង ១) ស្វែងយល់ពីប្រព័ន្ធបច្ចុប្បន្នក្នុងការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេស ២) វិភាគស្ថានភាពទេសន្តរប្រវេសន៍នៃលំហូរពលករផ្សេងៗ ដោយផ្តោតលើនិន្នាការ លក្ខណៈ និងកត្តានានាដែលជះឥទ្ធិពលលើសេចក្តីសម្រេចចិត្តរបស់គ្រួសារ ៣) វាយតម្លៃលើគោលនយោបាយ និងក្របខ័ណ្ឌច្បាប់គ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្ម ៤) ពិភាក្សាពីជម្រើសគោលនយោបាយដើម្បីដោះស្រាយទេសន្តរប្រវេសន៍មិនស្របច្បាប់ ។

## ១.៣ ក្របខ័ណ្ឌទស្សនទាន

ក្របខ័ណ្ឌទស្សនទាននៃការសិក្សា ត្រូវបានរៀបចំតាមក្របខ័ណ្ឌទស្សនទានទូទៅមួយស្តីពីទេសន្តរប្រវេសន៍អន្តរជាតិ ប្រាក់ផ្ញើទៅផ្ទះ និងការអភិវឌ្ឍ ដោយស្នើឡើង ១) គោលនយោបាយ និងការរៀបចំស្ថាប័ន ២) ការធ្វើសេចក្តីសម្រេចចិត្តរបស់គ្រួសារ ដែលជាសមាសភាពដ៏សំខាន់នៅក្នុងទេសន្តរប្រវេសន៍កម្លាំងពលកម្ម។

**គោលនយោបាយ និងការរៀបចំស្ថាប័ន៖** ប្រទេសបញ្ជូន និងប្រទេសទទួល គេគ្រប់គ្រងទេសន្តរប្រវេសន៍តាមរយៈគោលនយោបាយ ដែលត្រូវយកមករៀបចំជាច្បាប់អនុវត្តដោយស្ថាប័នរដ្ឋាភិបាល ព្រមទាំងសេវាកម្មផ្សេងៗដែលបើកឱកាស និងជួយសម្រួលចលនាប្រជាជន និងដែលមានលក្ខណៈជាកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី។ ដូចគ្នាដែរ ក្រុមហ៊ុនឯកជនផ្តល់សេវាកម្មរកការងារឱ្យធ្វើ ដើម្បីឆ្លើយតបនឹងគោលនយោបាយរដ្ឋាភិបាល រីឯស្ថាប័នមិនមែនរដ្ឋាភិបាលផ្តល់សេវាកម្មដល់ពលករទេសន្តរប្រវេសន៍ ដូចជា ព័ត៌មាន ការជួយសង្គ្រោះ និងការប្រឹក្សាយោបល់។

**ការសម្រេចចិត្តរបស់គ្រួសារ៖** តួអង្គចម្បងគឺ គ្រួសារដែលសម្រេចចិត្តបញ្ជូនសមាជិករបស់ខ្លួនម្នាក់ ឬច្រើននាក់ ទៅធ្វើការនៅបរទេសដោយរំពឹងថានឹងទទួលបានប្រាក់ផ្ញើទៅផ្ទះ។ ការសម្រេចចិត្តនេះ ជាការឆ្លើយតបទៅនឹងស្ថានភាពទីផ្សារពលកម្មសាកល និងទទួលរងឥទ្ធិពលពីកត្តាជាច្រើន មានជាអាទិ៍ ទីផ្សារពលកម្មក្នុងស្រុក ស្ថានភាពសេដ្ឋកិច្ចគ្រួសារ គោលនយោបាយទេសន្តរប្រវេសន៍ក្នុងស្រុក និងវិធានក្រៅផ្លូវការ និងការអនុវត្តទូទៅ។ ការសម្រេចចិត្តផ្នែកទេសន្តរប្រវេសន៍ពលកម្ម អាចសម្រាប់រយៈពេលវែង ឬខ្លី។ ការសម្រេចចិត្ត ក៏អាចទាក់ទិននឹងការចូលទៅប្រទេសគេដោយស្របច្បាប់ ឬខុសច្បាប់ ហើយបន្ទុកចំណាយ និងអត្ថប្រយោជន៍នៃជម្រើសនីមួយៗ វាជះឥទ្ធិពលលើការសម្រេចចិត្ត។ នៅក្នុងទេសន្តរប្រវេសន៍ស្របច្បាប់ អត្ថប្រយោជន៍ត្រូវតែសមរម្យតាមការចំណាយពេលវេលា និងធនធាន ក្នុងការរៀបចំការធ្វើទេសន្តរប្រវេសន៍បែបនេះ។ ទេសន្តរប្រវេសន៍ខុសច្បាប់ មានតម្លៃថោកជាងច្រើន

ពីព្រោះកម្រិតជំនាញគេទទួលយកតាមលទ្ធភាពជាក់ស្តែង ហើយដំណើរការទៀតសោត ក៏សាមញ្ញជាងដែរ។ ការសម្រេចចិត្តផ្សេងៗ វាប៉ះពាល់ជាខ្លាំងដល់មូលធនមនុស្សក្នុងគ្រួសារ និងការគ្រប់គ្រងទេសន្តរប្រវេសន៍។




ការសិក្សានេះផ្តោតលើ បែបបទដែលការសម្រេចចិត្តរបស់គ្រួសារក្នុងការធ្វើទេសន្តរប្រវេសន៍តាមច្រកមិនស្របច្បាប់ វាប៉ះពាល់ដល់នយោបាយ និងច្បាប់ ឧស្សាហកម្មទេសន្តរប្រវេសន៍ក្នុងស្រុក ទីផ្សារពលកម្មក្នុងស្រុក និងការអនុវត្តធ្វើទេសន្តរប្រវេសន៍ជាទូទៅ។

## ១.៤ វិធីសាស្ត្រស្រាវជ្រាវ

ដោយហេតុថា គេត្រូវការព័ត៌មានទាំងផ្នែកបរិមាណ និងគុណភាព ការសិក្សាបានប្រើវិធីសាស្ត្រចម្រុះដែលរួមមានការពិនិត្យឯកសារឡើងវិញ អង្កេតគ្រួសារ និងសម្ភាសន៍ស៊ីជម្រៅ។

**ការពិនិត្យឯកសារមានស្រាប់ឡើងវិញ៖** ឯកសារទេសន្តរប្រវេសន៍មានស្រាប់នានា បានយកមកពិនិត្យឡើងវិញមុនពេលធ្វើការស្រាវជ្រាវ។ លទ្ធផលដំបូងទទួលបាន គឺទិដ្ឋភាពទូទៅនៃទេសន្តរប្រវេសន៍ពលកម្ម កត្តាជះឥទ្ធិពលលើការសម្រេចចិត្តធ្វើទេសន្តរប្រវេសន៍ ប្រាក់ផ្ញើទៅផ្ទះ និងផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច។ ឯកសារទេសន្តរប្រវេសន៍ គោលនយោបាយ និងបទបញ្ញត្តិច្បាប់ ជាទុនដ៏សំខាន់សម្រាប់ការវិភាគ និងការវាយតម្លៃលើគោលនយោបាយ និងបទបញ្ញត្តិច្បាប់។

**អង្កេតគ្រួសារ៖** អង្កេតផ្តល់នូវទិន្នន័យដ៏សំខាន់សម្រាប់ការវិភាគបែបបរិមាណនៃស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារជនទេសន្តរប្រវេសន៍ និងការសម្រេចចិត្តធ្វើទេសន្តរប្រវេសន៍របស់ពួកគេ។ វិទ្យាស្ថាន CDRI បានធ្វើអង្កេត

នៅដំណាច់ឆ្នាំ២០០៧ លើ "ការចំណាយ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍ពលកម្មឆ្លងកាត់ព្រំដែនក្នុង GMS៖ ករណីសិក្សានៅកម្ពុជា" ដោយបានធ្វើសម្ភាសន៍ ៥២៦គ្រួសារ ក្នុង ៦ភូមិ ដែលមានអត្រាទេសន្តរប្រវេសន៍ខ្ពស់។ តារាង ១ បង្ហាញពីលក្ខណៈនៃភូមិដែលបានធ្វើអង្កេត។ សម្ភាសន៍ទល់មុខមេគ្រួសារ បានប្រើបញ្ជីសំណួរដើម្បីស្រង់យកព័ត៌មានអំពីប្រជាសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ទ្រព្យសម្បត្តិ ចំណូល ចំណាយ តម្លៃ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍ និងប្រាក់ផ្ញើទៅផ្ទះ។

**ការពិភាក្សាតាមក្រុមគោលដៅ៖** ដើម្បីបំពេញបន្ថែមដល់អង្កេតគ្រួសារ ការពិភាក្សាតាមក្រុមគោលដៅ (FGDs) បានធ្វើឡើងក្នុង ៦ភូមិ ជាមួយជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ និងជាមួយមេគ្រួសារដែលមានសមាជិកទៅធ្វើការនៅបរទេស។ ក្រុមគោលដៅមានអ្នកផ្តល់ព័ត៌មានពី ៦-៨នាក់ និងពិភាក្សាគ្នាពីបញ្ហាដូចជាមូលហេតុនៃទេសន្តរប្រវេសន៍ ចំណេះដឹងពីទេសន្តរប្រវេសន៍ ដំណើរការទេសន្តរប្រវេសន៍ ចំណាយនិងហិរញ្ញប្បទាន និងលក្ខខ័ណ្ឌការងារ។ ក្នុងភូមិនីមួយៗ មានដំណើរការ FGDs ចំនួន ៤ ដែលសម្របសម្រួលដោយអ្នកចុះធ្វើសម្ភាសន៍មានការបណ្តុះបណ្តាលច្បាស់លាស់។

តារាង ១៖ លក្ខណៈនៃភូមិបានធ្វើអង្កេត

| **ភូមិ** | **ចំនួនគ្រួសារ** | **% ប៉ាន់ស្មាននៃគ្រួសារធ្វើទេសន្តរប្រវេសន៍** | **ទីដៅ** |
|---|---|---|---|
| ១. ស្រម៉មាស (ខេត្តបាត់ដំបង) | 330 | >30 | ម៉ាឡេស៊ី |
| ២. ក្រសាំង (ខេត្តបាត់ដំបង) | 250 | >30 | ថៃ |
| ៣. គោកធ្លង់ (ខេត្តបន្ទាយមានជ័យ) | 105 | >70 | ថៃ |
| ៤. រំដួល (ខេត្តបន្ទាយមានជ័យ) | 280 | >50 | ថៃ |
| ៥. សៀមពាយ (ខេត្តកំពង់ធំ) | 185 | >40 | ថៃ |
| ៦. ខ្នាយ (ខេត្តព្រៃវែង) | 110 | >50 | ថៃ |

ប្រភព៖ Chan (2009)

**សម្ភាសន៍ស៊ីជម្រៅ៖** ការសិក្សារួមមាន សម្ភាសន៍ស៊ីជម្រៅជាមួយមន្ត្រីមកពីរដ្ឋបាលថ្នាក់ក្រោមជាតិ (កម្រិតភូមិ ឃុំ និងស្រុក) មន្ត្រីជាន់ខ្ពស់មកពីក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត (MLVT) អ្នកជំនាញបច្ចេកទេសមកពី ILO, IOM, UNIAP និងមូលនិធិអភិវឌ្ឍស្ត្រីនៃអង្គការសហប្រជាជាតិ (UNIFEM) ប្រធានសមាគមក្រុមហ៊ុនជ្រើសរើសពលករកម្ពុជា និងតំណាងក្រុមហ៊ុនជ្រើសរើសពលករឯកជន ដើម្បីទទួលបានការវាយតម្លៃរបស់ពួកគេលើគោលនយោបាយ និងក្របខ័ណ្ឌច្បាប់របស់កម្ពុជា ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម និងជម្រើសគោលនយោបាយដើម្បីដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ ការសិក្សាក៏បានធ្វើសម្ភាសន៍ជាមួយមេភូមិ និងប្រធានមន្ទីរការងារខេត្តផងដែរ។

សម្ភាសន៍ស៊ីជម្រៅ និង FGDs ត្រូវបានធ្វើឡើងនៅដំណាច់ឆ្នាំ២០១០ និងដើមឆ្នាំ២០១១។

## ១.៥ រចនាសម្ព័ន្ធនៃរបាយការណ៍

ផ្នែកទី២ ពិនិត្យពីទម្រង់នៃទេសន្តរប្រវេសន៍មិនស្របច្បាប់នៅកម្ពុជា ដោយផ្តោតលើនិយមន័យ ស្ថានភាព និងលក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ច។ ផ្នែកទី៣ ពិនិត្យពីមូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់ ហើយផ្នែកទី៤ ពិភាក្សាពីបញ្ហាប្រឈមនានា។ ផ្នែកទី៥ ពិនិត្យពី គោលនយោបាយ ច្បាប់ និងស្ថាប័នគ្រប់គ្រងលើទេសន្តរប្រវេសន៍នៅកម្ពុជា។ ផ្នែកទី៦ ពិភាក្សាពីវិធីសាស្ត្រ ធ្វើច្បាប់គ្រប់គ្រងទេសន្តរប្រវេសន៍មិនស្របច្បាប់ និងផ្នែកទី៧ ផ្តល់ជាសេចក្តីសន្និដ្ឋាន។

# ២ ទម្រង់នៃទេសន្តរប្រវេសន៍មិនស្របច្បាប់ កម្ពុជា

## ២.១ សេចក្តីសង្ខេបអំពីទេសន្តរប្រវេសន៍ការងារជាអន្តរជាតិរបស់កម្ពុជា

ក្នុងទសវត្សរ៍កន្លងទៅ ការធ្វើនីរប្រវេសន៍ (emigration) ស្វែងរកការងាររបស់ប្រជាជនកម្ពុជា បានវិវត្តគួរឱ្យកត់សម្គាល់ទាំងក្នុងម៉ូដ កម្រិត ទំហំ និងអន្តរាគមន៍ផ្នែកគោលនយោបាយ។ ក្នុងទសវត្សរ៍១៩៨០ និង១៩៩០ ទេសន្តរប្រវេសន៍ពលកម្មភាគច្រើនជាជនភៀសខ្លួន ឬប្រជាជនភៀសសឹក ទៅស្នាក់នៅបណ្តោះអាសន្នក្នុងប្រទេសថៃ ដោយសារសង្គ្រាមស៊ីវិល ឬអស្ថិរភាពនយោបាយ។ គេក៏ឃើញមានចលនាឆ្លងកាត់ព្រំដែន ដើម្បីទៅធ្វើការងារកសិកម្មតាមរដូវផងដែរ។

នីរប្រវេសន៍កម្លាំងពលកម្មថ្មីនេះ បានកើតឡើងតាំងពីឆ្នាំ២០០០ ដោយសារកំណើនយ៉ាងលឿននៃជនទេសន្តរប្រវេសន៍ទៅកាន់ទីដៅជាច្រើន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា ពីឆ្នាំ១៩៩៨-២០០៩ មានជនកម្ពុជា ៤៥.៦៥៦នាក់ ត្រូវបានបញ្ជូនជាផ្លូវការឲ្យទៅធ្វើការងារនៅបរទេស ភាគច្រើនទៅម៉ាឡេស៊ី និងថៃ ធ្វើជាកម្មកររោងចក្រ ឬអ្នកបម្រើតាមផ្ទះ (មើលស្ថិតិលម្អិតក្នុងឧបសម្ព័ន្ធ)។ ការផ្លាស់ប្តូរនេះជំរុញឡើងជាសំខាន់ដោយគោលនយោបាយលើកទឹកចិត្តការនាំចេញពលករ និងការកែលម្អអភិបាលកិច្ចលើទេសន្តរប្រវេសន៍តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងការបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់។

ផលប៉ះពាល់សេដ្ឋកិច្ចបានកើនឡើងស្របគ្នានឹងចំនួនជនទេសន្តរប្រវេសន៍។ ប្រាក់ផ្ញើទៅផ្ទះកើនឡើងពី ១២ លានដុល្លារអាមេរិក ឬ ០,៣៤% នៃ ផសស ឆ្នាំ១៩៩៦ ដល់ ៣២៥លានដុល្លារអាមេរិក ឬ ៣,៤%នៃ ផសស ឆ្នាំ២០០៨ (World Bank 2011)។ គ្រួសារជនទេសន្តរប្រវេសន៍ បានប្រើប្រាក់ផ្ញើទៅផ្ទះ ដើម្បីទិញស្បៀងអាហារ សងបំណុល ថែទាំសុខភាព ទិញសម្ភារៈកសិកម្ម និងទ្រព្យជាប់លាប់សម្រាប់គ្រួសារ ធ្វើឱ្យពួកគេអាចចាកផុតពីភាពក្រីក្រ (Chan 2009, Maltoni 2006b, FitzGerald *et al.* 2007 )។

ចំនួនប្រជាជនកម្ពុជាទៅធ្វើការនៅបរទេសដោយគ្មានការអនុញ្ញាត ឬឯកសារ ក៏បានកើនឡើងគួរឲ្យកត់សម្គាល់ដែរ។ ទាំងរដ្ឋាភិបាល និងអង្គការអន្តរជាតិ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើចលនាមិនស្របច្បាប់នេះ។

## ២.២ ទេសន្តរប្រវេសន៍ក្រៅផ្លូវការៈ និយមន័យ និងស្ថានភាព

ទេសន្តរប្រវេសន៍មិនស្របច្បាប់ អាចកំណត់និយមន័យយ៉ាងខ្លីថាជា ចលនាផ្លាស់ទីខុសច្បាប់ដើម្បីទៅធ្វើការក្នុងប្រទេសមួយ ឬចលនាផ្លាស់ទីដោយពុំមានការអនុញ្ញាតឱ្យធ្វើការ។ ប្រការនេះរួមមានករណីនៃ ប្រជាជនធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ ប៉ុន្តែក្រោយមកបានបាត់បង់ស្ថានភាពស្របច្បាប់របស់ខ្លួន (ឧទាហរណ៍ ដោយសារការស្នាក់នៅហួសកំណត់) (UN General Assembly; Brennan 1984; Global Commission on International Migration 2005; LeVoy &Geddie 2010; Lee 2005)។ ពាក្យអង់គ្លេស "irregular (មិនរៀបរយ)" អាចប្រើជាផ្លាស់ប្តូរគ្នាបានជាមួយពាក្យ"គ្មានឯកសារ""គ្មានការអនុញ្ញាត""មិនស្របច្បាប់"ឬ"លួចលាក់"។ជនទេសន្តរប្រវេសន៍មិនស្របច្បាប់កម្ពុជាភាគច្រើន ធ្វើដំណើរដោយពុំមានឯកសារស្របច្បាប់គ្រប់គ្រាន់ទេ។

ការជ្រើសរើសពលករមិនស្របច្បាប់ ក៏ជាទម្រង់ពេញនិយមបំផុតនៃ ចលនាឆ្លងកាត់ព្រំដែនក្នុងចំណោមពលករកម្ពុជាដែលស្វែងរកការងារនៅបរទេស។ ទង្វើនេះកើតឡើងនៅក្រៅក្របខ័ណ្ឌច្បាប់នៃប្រទេសបញ្ជូន ប្រទេសឆ្លងកាត់ និងប្រទេសទទួល។ ការជ្រើសរើសពលករមិនស្របច្បាប់អាចចែកជាពីរប្រភេទគឺ ទី១ ទេសន្តរប្រវេសន៍ចម្ងាយជិតតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ហើយតាមធម្មតា ដើម្បីទៅធ្វើការងារកសិកម្មដែលជនទេសន្តរប្រវេសន៍បានដឹងពីសាច់

ញាតិជនទេសន្តរប្រវេសន៍ធ្លាប់ទៅមុនគេ មិត្តភ័ក្តិ ឬអ្នកភូមិឯទៀត។ អ្នកធ្លាប់ទៅមុនទាំងនេះជួយសម្រួលការចូលធ្វើការ និងដើរតួជាបណ្តាញតភ្ជាប់ជាមួយគ្រួសារធំនៅជនបទ និងទីដៅនៅប្រទេសថៃ។ ឧទាហរណ៍ ពលករទេសន្តរប្រវេសន៍ពីភូមិក្រសាំង ខេត្តបាត់ដំបង បានធ្វើដំណើរទៅច្រកព្រំដែនបវេល តាមរថយន្តតាក់ស៊ី រួចឆ្លងដែនទៅប្រទេសថៃ ដោយប្រើប័ណ្ណឆ្លងព្រំដែន។ បន្ទាប់មកនិយោជកមកទទួលយកពួកគេទៅកសិដ្ឋានរបស់ខ្លួន។ ជនទេសន្តរប្រវេសន៍ភាគច្រើនចាត់ទុកវិធីនេះថាមានសន្តិសុខគួរសម តម្លៃថោក ងាយស្រួល មិនបាច់ចំណាយពេលរង់ចាំ មិនត្រូវការឯកសារ និងមិនបាច់មាននីតិវិធីជ្រើសរើសស្មុគស្មាញទេ។ សម្រាប់អ្នកទិញប័ណ្ណឆ្លងព្រំដែនរយៈពេលមួយសប្តាហ៍ ចំណាយដំបូងសម្រាប់ការធ្វើទេសន្តរប្រវេសន៍មានចំនួនពី ៣,០០-៥,៥០ដុល្លារអាមេរិក ក្នុងនេះមាន ថ្លៃតាក់ស៊ី ពី ២,៥០-៥,០០ដុល្លារអាមេរិក និងថ្លៃប័ណ្ណឆ្លងព្រំដែន ០,៥០ដុល្លារអាមេរិក។ ជនទេសន្តរប្រវេសន៍ត្រូវធ្វើប័ណ្ណថ្មីរាល់សប្តាហ៍នៅព្រំដែន ឬក៏អាចទិញប័ណ្ណមានរយៈពេលដល់មួយឆ្នាំដែលមានតម្លៃ ១៩ដុល្លារអាមេរិក។

ប្រភេទទីពីរគឺ ទេសន្តរប្រវេសន៍ចម្ងាយឆ្ងាយទៅប្រទេសថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការលើទូកនេសាទ ឬធ្វើជាកម្មកររោងចក្រ ឬកម្មករសំណង់។ ក្នុងករណីភាគច្រើន ជនទេសន្តរប្រវេសន៍ធ្វើដំណើរជាក្រុមតូចៗដោយមានមេខ្យល់មួយនាក់ នាំពួកគេទៅកន្លែងធ្វើការនៅប្រទេសថៃ។ សេវាសំខាន់ៗដែលមេខ្យល់ផ្តល់ឱ្យមាន ការដឹកជញ្ជូនទៅព្រំដែន និងជួយសុំប័ណ្ណធ្វើការ និងការងារនៅប្រទេសទីដៅ។ ជនទេសន្តរប្រវេសន៍ត្រូវបង់ថ្លៃសម្រួលការជាមុនពី ១០០ ដល់ ២០០ដុល្លារអាមេរិក។ ក្នុងករណីខ្លះ ជនទេសន្តរប្រវេសន៍ធ្វើដំណើរជាក្រុមតូចៗដោយ មានជំនួយពីអ្នកធ្លាប់ទៅពីមុនដែលដឹងស្ថានភាពការងារ និងមានទំនាក់ទំនងល្អជាមួយនិយោជក។

ប្រទេសថៃជាទីដៅដ៏សំខាន់សម្រាប់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា។ IOM បានបញ្ជាក់ថា អាចមានជនកម្ពុជា ១៨០.០០០នាក់ មកពីខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង និងពោធិ៍សាត់ ដែលកំពុងធ្វើការដោយខុសច្បាប់នៅថៃ។ ក្រសួងការងារថៃ (in Paitoonpong & Sukaruji, forthcoming) បានប៉ាន់ស្មានថា មានជនទេសន្តរប្រវេសន៍មិនស្របច្បាប់ជាតិកម្ពុជាប្រមាណ ១២០.០០០នាក់ គឺប្រហែលគ្នានឹងជនទេសន្តរប្រវេសន៍មិនស្របច្បាប់ពីឡាវ ប៉ុន្តែនៅតិចជាងមីយ៉ាន់ម៉ា។ ប្រភពដដែល (តារាង ២) បានឱ្យដឹងថា នៅប្រទេសថៃ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ជាតិកម្ពុជាភាគច្រើនណាស់ ធ្វើការក្នុងវិស័យកសិកម្ម (៤២%) និងវិស័យសំណង់ (២៦%)។

តារាង ២៖ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ នៅប្រទេសថៃ តាមផ្នែកឧស្សាហកម្ម ឆ្នាំ២០០៩

| **ឧស្សាហកម្ម** | **ចំនួនកម្មករ** | | | |
|---|---|---|---|---|
| | **កម្ពុជា** | **ឡាវ** | **មីយ៉ាន់ម៉ា** | **សរុប** |
| នេសាទ | 14969 | 1800 | 39809 | 56578 |
| ពាក់ព័ន្ធនេសាទ | 6020 | 1180 | 129773 | 136973 |
| ដាំដុះ និងចិញ្ចឹមសត្វ | 24085 | 18035 | 179583 | 221703 |
| ពាក់ព័ន្ធការដាំដុះ និងចិញ្ចឹមសត្វ | 7077 | 4469 | 62611 | 74157 |
| សំណង់ | 32465 | 12635 | 175136 | 220236 |
| យករ៉ែ/ថ្ម | 61 | 35 | 1747 | 1843 |
| លក់ដុំ និងលក់រាយ | 4778 | 7565 | 30471 | 42814 |
| អាហារ និងភេសជ្ជៈ (អ្នកលក់) | 4483 | 13074 | 36668 | 54225 |
| អ្នកបម្រើតាមផ្ទះ | 6578 | 21267 | 101945 | 129790 |
| ផ្សេងទៀត | 24245 | 30794 | 321024 | 376063 |
| **សរុប** | 124761 | 110854 | 1078767 | 1314382 |

ប្រភព៖ Paitoonpong & Sukaruji (forthcoming)

ប្រទេសម៉ាឡេស៊ីជាទីដៅទី២ សម្រាប់ជនទេសន្តរប្រវេសន៍កម្ពុជាដែលគ្មានឯកសារ ហើយភាគច្រើនមកពីក្រុមជនជាតិភាគតិចចាម។ ផ្លូវធ្វើដំណើរជាទូទៅបំផុត គឺជិះយន្តហោះទៅម៉ាឡេស៊ីក្នុងលក្ខណៈជាទេសចរ ហើយបន្ទាប់មករកការងារដោយពុំមានប័ណ្ណធ្វើការ។ ផ្លូវទីពីរ គឺធ្វើដំណើរទៅប្រទេសថៃ រួចហើយឆ្លងព្រំដែនទៅម៉ាឡេស៊ី។ ជនទេសន្តរប្រវេសន៍គ្មានការអនុញ្ញាតភាគច្រើន តែងទៅម៉ាឡេស៊ីស្វែងរកការងារក្នុងវិស័យសំណង់ និងកម្មន្តសាល។

## ២.៣ លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃជនទេសន្តរប្រវេសន៍មិនស្របច្បាប់ កម្ពុជា

ការពិភាក្សាពីលក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃជនទេសន្តរប្រវេសន៍មិនស្របច្បាប់ បានធ្វើឡើងដើម្បីប្រៀបធៀបពួកគេទៅនឹងជនមិនមែនទេសន្តរប្រវេសន៍ និងដើម្បីកំណត់ពីកត្តាជំរុញចលនាផ្លាស់ទីមិនស្របច្បាប់។ ក្រុមស្រាវជ្រាវបានប្រើទាំងទិន្នន័យបែបបរិមាណបានពីអង្កេតលើជនទេសន្តរប្រវេសន៍នៅឆ្នាំ២០០៧ និងទិន្នន័យបែបគុណភាពបានពី FGDs ជាបន្តមកទៀត និងសម្ភាសន៍ពាក់កណ្តាលរៀបរយដែលបានធ្វើឡើងនៅដំណាច់ឆ្នាំ២០១០ និងដើមឆ្នាំ២០១១ ដោយបានចាត់ថ្នាក់អ្នកឆ្លើយសម្ភាសន៍ជាជនទេសន្តរប្រវេសន៍ផ្លូវការ មិនស្របច្បាប់ និងជនមិនមែនទេសន្តរប្រវេសន៍។

ដូចមានបង្ហាញក្នុងតារាង ៣ ជាងពាក់កណ្តាលនៃចំនួនគ្រួសារក្នុងសំណាកនេះ មានសមាជិកគ្រួសារធ្វើទេសន្តរប្រវេសន៍ ដោយភាគច្រើនបំផុតជាជនទេសន្តរប្រវេសន៍មិនស្របច្បាប់។ ជនទេសន្តរប្រវេសន៍ប្រហែលមួយភាគបីជាស្ត្រី ហើយពួកគេក៏ដូចជាអាជ្ញាធរមូលដ្ឋាន បានឱ្យដឹងថា ភាគច្រើនបំផុតនៃជនទេសន្តរប្រវេសន៍ក្នុងសំណាកចូលចិត្តប្រើបណ្តាញក្រៅផ្លូវការ។ គួរកត់សម្គាល់ថា ជនទេសន្តរប្រវេសន៍ស្របច្បាប់នៅក្នុងសំណាកអង្កេតនេះមានចំនួនតិចណាស់ ដូច្នេះលទ្ធផលពិនិត្យឃើញ ត្រូវតែបកស្រាយនៅក្នុងកំហិតនេះ។

តារាង ៣៖ គ្រួសារ និងសមាជិកធ្វើទេសន្តរប្រវេសន៍

| | ផ្លូវការ | % | មិនស្របច្បាប់ | % | មិនមែនទេសន្តរប្រវេសន៍ | % | សរុប |
|---|---|---|---|---|---|---|---|
| គ្រួសារ | 16 | 3 | 293 | 56 | 217 | 41 | 526 |
| ជនទេសន្តរប្រវេសន៍ | 19 | 4 | 494 | 96 | - | - | 513 |
| ស្ត្រី | 6 | 3 | 171 | 97 | - | - | 177 |

ប្រភព៖ Chan (2009)

ទិន្នន័យអង្កេតបង្ហាញថា សមាមាត្រដ៏ច្រើននៃពលករមិនស្របច្បាប់ ទទួលបានការងារនៅក្នុងប្រទេសថៃ និងនៅតាមព្រំដែនកម្ពុជា-ថៃ។ ពលករដែលបានធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសថៃភាគច្រើនធ្វើការក្នុងវិស័យកសិកម្ម និងសំណង់ (រួមទាំងនេសាទ) រីឯពលករនៅតាមព្រំដែនធ្វើការនៅកសិដ្ឋាន។ ជនទេសន្តរប្រវេសន៍ផ្លូវការ មិនស្នាក់នៅជិតព្រំដែនទេ ពួកគេធ្វើការក្នុងរោងចក្រ និងនៅការដ្ឋានសំណង់។ ពលករទេសន្តរប្រវេសន៍ផ្លូវការ និងមិនស្របច្បាប់នៅប្រទេសម៉ាឡេស៊ី មានការងារក្នុងវិស័យសំណង់ ឬកម្មន្តសាល ឬធ្វើជាអ្នកបម្រើតាមផ្ទះ (តារាង ៤ និង ៥)។

លទ្ធផលសម្ភាសន៍ និង FGDs បង្ហាញថា ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ភាគច្រើនបំផុត បម្រើការងារគ្មានជំនាញ ឬមានជំនាញទាប ដោយសារពលករក្នុងស្រុកមិនចង់ធ្វើការងារទាំងនេះទេ ព្រោះយល់ថា វាជាការងារថ្នាក់ទាប និងយ៉ាប់យ៉ឺន។ ក្នុងករណីជាច្រើន ការងាររបស់ជនទេសន្តរប្រវេសន៍ សឹងតែមិនទាមទារជំនាញអ្វីទេ។ ឧទាហរណ៍ ក្នុងការដ្ឋានសំណង់ ពួកគេគ្រាន់តែលើកដាក់ឥដ្ឋ ឬលាយបេតុងតែប៉ុណ្ណោះ។ ក្នុងកសិកម្ម ពួកគេគ្រាន់តែយាមកសិដ្ឋាន បាញ់ថ្នាំសម្លាប់សត្វល្អិត និងប្រមូលផលដំណាំ។ ប៉ុន្តែពលករដែលទៅធ្វើការនៅចំការកៅស៊ូ អាចទទួលបានជំនាញដូចជា ការចៀរជ័រ ឬបច្ចេកទេសថែទាំ និងដាំកៅស៊ូ។

តារាង ៤៖ ជនទេសន្តរប្រវេសន៍ទៅកាន់ទីដៅសំខាន់ៗ តាមប្រភេទ និងយេនឌ័រ

| ទីដៅ | មិនស្របច្បាប់ | | | | ផ្លូវការ | | | |
|---|---|---|---|---|---|---|---|---|
| | បុរស | | ស្ត្រី | | បុរស | | ស្ត្រី | |
| | N | % | N | % | N | % | N | % |
| ក្នុងប្រទេសថៃ | 173 | 53.5 | 76 | 44.4 | 12 | 92.3 | 2 | 33.3 |
| តាមព្រំដែនថៃ | 120 | 37.1 | 70 | 40.9 | 0 | 0 | 0 | 0 |
| ម៉ាឡេស៊ី | 30 | 9.2 | 25 | 14.6 | 1 | 7.6 | 4 | 66.6 |
| សរុប | 323 | 100 | 171 | 100 | 13 | 100 | 6 | 100 |

ប្រភពៈ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧

តារាង ៥៖ ជនទេសន្តរប្រវេសន៍តាមប្រភេទការងារ និងទីដៅ

| មិនស្របច្បាប់ | សំណង់ | កសិកម្ម * | ការងារផ្ទះ | រោងចក្រ | ផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| ក្នុងប្រទេសថៃ | 104 | 89 | 22 | 12 | 22 | 249 |
| តាមព្រំដែនថៃ | 1 | 189 | 0 | 0 | 0 | 190 |
| ម៉ាឡេស៊ី | 16 | 7 | 3 | 23 | 6 | 55 |
| សរុប | 121 | 218 | 25 | 35 | 28 | 494 |
| **ផ្លូវការ** | | | | | | |
| ក្នុងប្រទេសថៃ | 12 | 0 | 0 | 2 | 0 | 14 |
| ម៉ាឡេស៊ី | 0 | 0 | 3 | 2 | 0 | 5 |
| សរុប | 12 | 0 | 3 | 4 | 0 | 19 |

* រួមទាំងនេសាទ។ ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧

ដូចមានបង្ហាញក្នុងតារាង ៦ ភាគច្រើនបំផុតនៃជនទេសន្តរប្រវេសន៍ទាំងផ្លូវការ និងមិនស្របច្បាប់ ស្ថិតក្នុងវ័យម្ភៃប្លាយឆ្នាំ។ គ្រួសាររបស់ពួកគេមានទំហំជាមធ្យម ប្រហាក់ប្រហែលនឹងទំហំគ្រួសាររបស់ជនមិនមែនទេសន្តរប្រវេសន៍។ ប៉ុន្តែការអប់រំរបស់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ និងផ្លូវការ មានការខុសគ្នាច្រើន។

តារាង ៦៖ លក្ខណៈនៃជនទេសន្តរប្រវេសន៍ និងជនមិនមែនទេសន្តរប្រវេសន៍

| ប្រភេទទេសន្តរប្រវេសន៍ | ផ្លូវការ | មិនស្របច្បាប់ | មិនមែនទេសន្តរប្រវេសន៍ |
|---|---|---|---|
| ទំហំគ្រួសារជាមធ្យម | 5.0 | 5.6 | 4.8 |
| ចំនួនអ្នកនៅក្នុងបន្ទុក * | 1.6 | 2.2 | 2.1 |
| អាយុជាមធ្យមនៃជនទេសន្តរប្រវេសន៍ | 28.6 | 27.8 | - |
| ចំនួនឆ្នាំសិក្សាជាមធ្យមនៃជនទេសន្តរប្រវេសន៍ | 6.8 | 4.3 | - |

* សមាជិកគ្រួសារមានអាយុតិចជាង១៥ឆ្នាំ ឬលើសពី ៥៤ឆ្នាំ។ ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧

អង្កេតបានបង្ហាញថា គ្រួសាររបស់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ មានស្ថានភាពសេដ្ឋកិច្ចទាបជាងជនទេសន្តរប្រវេសន៍ផ្លូវការ និងជនមិនមែនទេសន្តរប្រវេសន៍។ ផ្អែកលើទិន្នន័យគួរឱ្យទុកចិត្ត និងអាចរកបាន ក្រុមស្រាវជ្រាវបានជ្រើសយកចំណាយប្រើប្រាស់ និងតម្លៃទ្រព្យសម្បត្តិ ដើម្បីតំណាងឲ្យសុខុមាលភាព។ តារាង ៧ ផ្តល់នូវធាតុផ្សំលម្អិតលើអថេរទាំងពីរ ដែលអាចផ្លាស់ប្តូរបានសម្រាប់ប្រភេទគ្រួសារនីមួយៗ។ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ចំណាយលើស្បៀងអាហារតិចជាង ជនមិនមែនទេសន្តរប្រវេសន៍ ១៩% ប៉ុន្តែច្រើនជាងជនទេសន្តរប្រវេសន៍ជាផ្លូវការបន្តិចបន្តួចដែលគ្មានសារៈសំខាន់ខាងស្ថិតិទេ។ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ចំណាយលើទំនិញមិនមែនស្បៀងអាហារប្រហែល ៤០% តិចជាងជនទេសន្តរប្រវេសន៍ផ្លូវការ និង ១៣% តិចជាងជនមិនមែនទេសន្តរប្រវេសន៍។ ចំណាយ

ប្រើប្រាស់សរុបរបស់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ មានកម្រិត ១៧% តិចជាងជនមិនមែនទេសន្តរប្រវេសន៍។ តម្លៃនៃទ្រព្យសម្បត្តិរបស់គ្រួសារជនទេសន្តរប្រវេសន៍មិនស្របច្បាប់ មានប្រហែលពាក់កណ្តាលនៃជនទេសន្តរប្រវេសន៍ផ្លូវការ ( ទាំងនៅឆ្នាំ២០០២ និង២០០៧ )។

តារាង ៧៖ ចំណាយប្រើប្រាស់មធ្យមប្រចាំថ្ងៃ និង តម្លៃទ្រព្យសម្បត្តិ

| | | **មធ្យម** ( Mean ) | | | T- **តំលៃ**† | | |
|---|---|---|---|---|---|---|---|
| | | ផ្លូវការ ( ក ) | មិនស្របច្បាប់ ( ខ ) | មិនមែនទេសន្តរប្រវេសន៍ ( គ ) | ( ខ )-( ក ) | ( ខ )-( គ ) | ( ក )-( គ ) |
| **ចំណាយប្រើប្រាស់** ( រៀល/ម្នាក់ ) | អាហារ | 1142.0 | 1168.6 | 1391.8 | 0.2 | -5.3 * * * | -2.0 * * |
| | | ( 478.5 ) | ( 450.1 ) | ( 469.4 ) | | | |
| | មិនមែនអាហារ | 1223.0 | 877.2 | 990.4 | -2.2 * * | -1.9 * | 1.2 |
| | | ( 752.46 ) | ( 578.8 ) | ( 668.2 ) | | | |
| | ទូទៅ | 2515 | 2249 | 2641 | -0.8 | -3.3 * * * | -0.3 |
| | | ( 1155 ) | ( 1241 ) | ( 1367 ) | | | |
| **ទ្រព្យសម្បត្តិ** ( ពាន់រៀល/ម្នាក់ )‡ | 2002 | 818.9 | 371.2 | 433.9 | -3.3 * * * | -1.2 | 2.5 * * |
| | | ( 727.2 ) | ( 517.3 ) | ( 562.5 ) | | | |
| | 2007 | 1,265.9 | 665.5 | 721.1 | -3.1 * * * | -0.8 | 2.8 * * * |
| | | ( 670.6 ) | ( 765.9 ) | ( 737.7 ) | | | |

Note: Standard deviation in parentheses. † Two-sample t-test of different means with equal variance;
‡ Excluding land and house; * Significant at 10% level; * * Significant at 5% level; * * * Significant at 1% level.

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧

# ៣ មូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់

មានហេតុផលចម្រុះដែលបង្កទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ ក្នុងចំណោមគំរូជាទ្រឹស្តីផ្សេងៗស្តីពី ចលនាប្រជាជនឆ្លងប្រទេស ទ្រឹស្តីផ្នែកស្ថាប័នប្រហែលជាអាចពន្យល់បានល្អជាងគេអំពីទេសន្តរប្រវេសន៍ខុសច្បាប់ដែលកើតឡើងដោយសារកត្តាអូសទាញ ជាជាងកត្តាជំរុញ។ អំណះអំណាងផ្នែកស្ថាប័ននេះ ឈរលើអតុល្យភាពរវាងចំនួនប្រជាជនស្វែងរកការងារក្នុងប្រទេសទីដៅ ហើយនិងចំនួនប័ណ្ណធ្វើការមានកម្រិតកំណត់ដែលប្រទេសនោះចេញឲ្យ (Massey *et al.* 1993)។ ភាពខុសគ្នានេះ នាំឱ្យអ្នកស្វែងរកការងារធ្វើ ត្រូវពឹងផ្អែកលើទីផ្សារការងារលួចលាក់។ ឧទាហរណ៍ នៅប្រទេសអ៊ីតាលី ប្រហែល ៣០% នៃពលករបរទេសប៉ុណ្ណោះដែលទទួលបានកន្លែងធ្វើការនៅឆ្នាំ២០០៦ ដូច្នេះ ក៏ឱ្យមានលំហូរចូលនៃជនទេសន្តរប្រវេសន៍ខុសច្បាប់ (IOM 2008)។

ក្នុងចំណោមកត្តាជាច្រើនទៀតដែលមានរៀបរាប់ជាក្រោយ ក្រុមស្រាវជ្រាវបានវែកញែកថា បញ្ហាផ្នែកស្ថាប័ននេះ អាចជាមូលហេតុសំខាន់មួយនៃលំហូរយ៉ាងសន្ធឹកសន្ធាប់នៃជនទេសន្តរប្រវេសន៍កម្ពុជាមិនស្របច្បាប់ ជាពិសេសទៅប្រទេសថៃ។ ភាពមិនស៊ីគ្នារវាងតម្រូវការពលកម្ម និងការផ្គត់ផ្គង់ បានជំរុញនិយោជកឱ្យជ្រើសរើសពលករពីប្រទេសឯទៀត។ បន្ទាប់មកទីផ្សារងងឹតក៏បង្កើតបណ្តាញផ្តល់កម្មករ ដើម្បីទទួលបានកម្រៃ។ វិធីអនុវត្តបានយូរឆ្នាំ ដោយសារមួយចំណែកមកពីភាពស្ពឹកស្រពន់ក្នុងការពង្រឹងអនុវត្តច្បាប់លើនិយោជកដែលជួលពួកពលករមិនស្របច្បាប់។

អតុល្យភាពបានលេចធ្លោឡើង នៅពេលចុះបញ្ជីពលករមិនស្របច្បាប់នៅប្រទេសថៃ។ តាំងពីឆ្នាំ១៩៩២ មក ដោយសារកង្វះខាតពលកម្ម មានការចុះបញ្ជីជាច្រើនលើកបានធ្វើឡើងសម្រាប់ពលករមិនស្របច្បាប់ ដែលបន្ទាប់មក គេហៅពលករទាំងនោះថា "ក្រៅផ្លូវការ ប៉ុន្តែមានឯកសារបញ្ជាក់" ដែលមានន័យថា មិនមែនខុសច្បាប់ទាំងស្រុងទេ (Paitoonpong & Sukaruji, forthcoming)។ នៅឆ្នាំ២០០៩ មានជនទេសន្តរប្រវេសន៍កម្ពុជាមិនស្របច្បាប់ ១២៤.៧៦១នាក់ បានចុះបញ្ជី (*ibid*)។

បញ្ហានៅក្នុងមាតុប្រទេស ក៏ជំរុញឱ្យប្រជាជនចាកចេញដែរ។ ជម្លោះផ្ទៃក្នុង និងអស្ថិរភាពនយោបាយ លែងជាកង្វល់ចំបងសម្រាប់ប្រជាជនកម្ពុជាទៀតហើយ តែនៅពេលនេះបញ្ហាសេដ្ឋកិច្ច ជាពិសេសភាពក្រីក្រ គឺជាកង្វល់ចំបង។ តួលេខចំណាយប្រើប្រាស់ក្នុងតារាង ៦ បង្ហាញថា ជនទេសន្តរប្រវេសន៍ មានកម្រិតជីវភាពទាបជាងបន្ទាត់ភាពក្រីក្របន្តិច។ ដោយប្រៀបធៀបនឹងបន្ទាត់ភាពក្រីក្រជាតិឆ្នាំ២០០៧ ដែលវាស់វែងតាមចំណាយប្រើប្រាស់ប្រចាំថ្ងៃ ចំនួន ២៣៦៧រៀល (World Bank 2009) គម្លាតភាពក្រីក្រ រវាងជនទេសន្តរប្រវេសន៍មិនស្របច្បាប់ និងជាផ្លូវការ មានទំហំជាង ១០០រៀល។ ជនមិនមែនទេសន្តរប្រវេសន៍ មាន ១០% ស្ថិតនៅលើបន្ទាត់ក្រីក្រ។ ប្រជាជនកម្ពុជាប្រហែល ៣០% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយភាគច្រើននៅតំបន់ជនបទ (*ibid*)។

*" ...ជនក្រីក្រលក់កម្លាំងពលកម្ម ឱ្យអ្នកធូរធារ ...មានជនក្រីក្រច្រើននាក់ណាស់ ប៉ុន្តែមានអ្នកធូរធារតិចនាក់ទេ ។ ដូច្នេះគេត្រូវទៅរកការងារនៅកន្លែងផ្សេង" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី១០ មីនា ២០១១)។*

*"...យើងអាចរស់រានបានដោយសារទៅធ្វើការនៅប្រទេសថៃ។ ក្នុងចំណោមអ្នកភូមិ ១០០នាក់ មាន ៧០ នាក់ធ្វើការនៅថៃ" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តបាត់ដំបង ថ្ងៃទី២១ កញ្ញា ២០១០)។*

ឫសគល់នៃភាពក្រីក្រមានច្រើនណាស់ ចាប់តាំងពីហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ រហូតដល់កម្លាំងពលកម្មគ្មានការអប់រំ ហើយទាំងអស់នេះជាបញ្ហាបន្សល់ទុកពីសង្គ្រាមស៊ីវិល។ ប៉ុន្តែ ទិន្នន័យបែបគុណភាពបានបង្ហាញចំណុចគួរចាប់អារម្មណ៍មួយ គឺការចុះក្រ បណ្តាលមកពីជីវភាពគ្រួសារត្រូវពឹងផ្អែកលើកសិកម្ម ជាពិសេសស្រូវ ហើយខ្វះខាតប្រព័ន្ធធារាសាស្ត្រ។ គ្រួសារភាគច្រើនអាចធ្វើស្រែបានតែម្តងក្នុងមួយឆ្នាំ ហើយផលិតភាពក៏មានកម្រិតទាប ត្រឹម ២-៣តោន/

ហិកតា ដែលមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារទាំងមូលទេ។ នៅតំបន់ខ្លះ ផលស្រូវមិនបាន ១តោន/ហិកតាផង ដោយសារគ្រោះធម្មជាតិ។ ប្រហែល ៧០% នៃផ្ទៃដីដាំដុះនៅកម្ពុជា មិនទាន់មានប្រព័ន្ធស្រោចស្រពទេ (MWRM 2009)។

*"...អ្នកភូមិ ៩០% ត្រូវពឹងផ្អែកលើដំណាំស្រូវ ... ភាគច្រើនអាចដាំដុះបានតែមួយដងក្នុងមួយឆ្នាំ ... ទិន្នផលស្រូវជាមធ្យម បានប្រហែល ៨០០គ.ក/ហិកតា ... អ្នកភូមិមានពេល ៦ខែទំនេរពីការងារធ្វើស្រែ ...អ្នកភូមិ ៦០% បានធ្វើចំណាកស្រុក" (មន្ត្រីមួយរូបនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី១៦ កុម្ភៈ ២០១១)។*

*"ខ្ញុំឃើញអ្វីៗក៏ល្អទាំងអស់ក្នុងស្រុកខ្ញុំ លើកលែងតែរឿង (កង្វះ) ទឹក" (មន្ត្រីមួយរូបនៅខេត្តព្រៃវែង ថ្ងៃទី ៣១ មករា ២០១១)។*

*"ប្រជាជនភាគច្រើនទៅធ្វើការនៅប្រទេសថៃ ដោយសារមកពីមានទឹកជំនន់ និងគ្រោះរាំងស្ងួតនៅទីនេះ ...ពួកគេមិនអាចធ្វើស្រែបាន" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី១០ មីនា ឆ្នាំ២០១១)។*

គ្រួសារនានាធ្វើទេសន្តរប្រវេសន៍ដើម្បីគេចខ្លួនពីសម្ពាធសេដ្ឋកិច្ច ដោយស្វែងរកការងារមានប្រាក់ឈ្នួលនៅតាមកន្លែងសំបូរឱកាសការងារ ឬនៅកន្លែងផ្តល់ចំណូលច្រើន បើធៀបនឹងជំនាញដែលពលករមាន។ ទេសន្តរប្រវេសន៍ពីតំបន់ជនបទ ទៅតំបន់ទីក្រុង គឺជាជម្រើសមួយ ប៉ុន្តែការងារមានតែក្នុងវិស័យប្រើជំនាញទាប និងពលកម្មច្រើន ដូចជាខាងសំណង់ និងរោងចក្រកាត់ដេរ រីឯខេត្តសៀមរាប គឺជាគោលដៅទេសចរណ៍ដ៏សំខាន់ គេត្រូវការភាគច្រើនតែពលករមានជំនាញខាងផ្នែកទទួលភ្ញៀវ ។ សម្រាប់ទេសន្តរប្រវេសន៍ឆ្លងព្រំដែន ទីដៅជិតបំផុតគឺ ប្រទេសថៃ ដែលមានបណ្តាញស្រាប់ និងតម្រូវការពលករមានជំនាញទាបកំពុងទាក់ទាញប្រជាជនកម្ពុជា។ លំហូរចេញពលករ បានប៉ះពាល់ដល់ទីផ្សារការងារក្នុងស្រុក និងបង្កកំណើនថ្លៃឈ្នួលនៅកម្ពុជា។

*"កាលពីមុន អ្នកភូមិវ័យក្មេងៗតែងទៅធ្វើការនៅភ្នំពេញ។ ដោយសារពួកគេមិនអាចរកប្រាក់បានច្រើនដូចអ្នកទៅធ្វើការនៅថៃ ដូច្នេះក្រោយមកគេក៏ឈប់ (ទៅភ្នំពេញ) ហើយទៅតាមអ្នកឯទៀត ទៅប្រទេសថៃ" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី១០ មីនា ២០១១)។*

*"ពិបាករកជួលមនុស្សឱ្យធ្វើការ (នៅទីនេះ) ណាស់ លុះត្រាតែយើងឱ្យប្រាក់ឈ្នួលគេខ្ពស់ ...ពួកគេមានជម្រើសច្រើន" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី១០ មីនា ២០១១)។*

ហេតុអ្វីប្រជាជនមិនជ្រើសយកការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់? លក្ខណៈខាងសង្គមកិច្ចផ្សេងៗទៀត ក្រៅពីការអប់រំ ហាក់គ្មានអ្វីគួរឲ្យគិតឃើញថា វាជះឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តរបស់ពួកគេនោះទេ។ ប្រជាជនទាំងនោះមិនមែនកើតមកសម្រាប់ធ្វើជាពលករខុសច្បាប់នោះទេ។ ពួកគេជ្រើសរើសវិធីដែលមានជាក់ស្តែង និងអាចរ៉ាប់រងចំណាយបាន។ លោក Chan (2009) វែកញែកថា ចំណាយដ៏ខ្ពស់ពីដំបូងនៃទេសន្តរប្រវេសន៍ស្របច្បាប់ គឺជាហេតុផលចម្បងនាំឱ្យប្រជាជនចង់ដំណើរដោយខុសច្បាប់ ថ្វីបើផលចំណេញសុទ្ធបានពីទេសន្តរប្រវេសន៍ស្របច្បាប់ វាមានកម្រិតខ្ពស់ជាងក៏ដោយ។ លោក Chan រកឃើញថា ដើម្បីរកបានការងារស្របច្បាប់នៅថៃ ពលករម្នាក់ត្រូវការប្រាក់ប្រហែល ៧០០ដុល្លារអាមេរិក (សូមមើលការលម្អិតមុខចំណាយក្នុងឧបសម្ព័ន្ធ) ដែលពលករភាគច្រើននៅជនបទកម្ពុជាមិនអាចរកបានទេ។ចំណាយខាងលើនេះរួមមានថ្លៃធ្វើលិខិតឆ្លងដែនប័ណ្ណធ្វើការទិដ្ឋាការនិងថ្លៃឈ្នួលជើងសារ។ បើសិនធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់វិញ គេចំណាយមិនលើសពី ១០០ដុល្លារអាមេរិកទេ។

ទិន្នន័យបែបគុណភាព ក៏បញ្ជាក់គាំទ្រដល់ការវែកញែករបស់លោក Chan ដែលថា ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ក្រីក្រ គេមិនចាប់អារម្មណ៍ស្វែងរកការងារតាមរយៈក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់ទេ។ ក្តីកង្វល់គឺមិនត្រឹមតែចំណាយខ្ពស់នោះទេ ប៉ុន្តែថែមទាំងនីតិវិធីស្មុគស្មាញ និងការរង់ចាំយ៉ាងយូរ ទំរាំបានចេញដំណើរនោះទៀត (តាមធម្មតាពី ៣-៦ខែ ដើម្បីទៅថៃ បើតាមការអះអាងរបស់លោក Chan)។ នៅជំពូកក្រោយ នឹងមានការពិភាក្សាលម្អិតពីបញ្ហានេះ។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ ចំណាយពេលអស់តែ ២-៣ថ្ងៃ និងត្រូវការឯកសារតិចតួច ឬគ្មានសោះ។

ប៉ុន្តែពេលវេលា និងដំណើរការ វាកាន់តែសំខាន់ជាងទំហំចំណាយទៅទៀតៈ

*"ជនក្រីក្រមិនអាចរង់ចាំ ២-៣ខែបានទេ... ពួកគេស្រេកឃ្លាននៅពេលនេះ ដូច្នេះត្រូវបំពេញក្រពះឱ្យបានកាន់តែឆាប់កាន់តែល្អ" (មន្ត្រីមួយរូបនៅខេត្តបាត់ដំបង ថ្ងៃទី១៥ កុម្ភៈ ២០១១)។*

*"...អ្នកភូមិពីនាក់ដែលឆ្លងដែនតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ បានរង់ចាំអស់ជិត១ឆ្នាំ តាំងពីពេលបានបញ្ជូនពាក្យសុំទៅភ្នំពេញ។ ពួកគេត្រូវត្រឡប់ចុះត្រឡប់ឡើង ពីព្រោះពាក្យសុំ មិនបានបំពេញត្រឹមត្រូវ។ ពួកគេមិនទាន់បានទៅធ្វើការនៅម៉ាឡេស៊ីនៅឡើយទេ" (មន្ត្រីនៅបន្ទាយមានជ័យ ថ្ងៃទី១៦ កុម្ភៈ ២០១១)។*

*"បញ្ហានេះ គឺដោយសារថា ...បណ្តាញស្របច្បាប់ត្រូវការប្រាក់ ពេលវេលា និងឯកសាររដ្ឋបាលផ្សេងៗជាច្រើន ដែលអ្នកមិនចេះអក្សរដូចពួកយើងមិនអាចយល់បានទេ" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តព្រៃវែង ថ្ងៃទី២ តុលា ២០១០)។*

លើសពីនេះទៀត ការអនុវត្តខុសឆ្គង និងវិធានមិនច្បាស់លាស់របស់ក្រុមហ៊ុនជ្រើសរើសស្របច្បាប់ បានធ្វើឱ្យប្រជាជនថយចុះទំនុកចិត្តលើបណ្តាញផ្លូវការ។ ឧទាហរណ៍ មានការត្អូញត្អែរជាច្រើនស្តីពីក្រុមហ៊ុនជ្រើសរើស ដែលបានបោកប្រាស់ជនទេសន្តប្រវេសន៍ ដោយមិនផ្តល់ប្រភេទការងារដូចក្រុមហ៊ុនបានសន្យា។ បញ្ហារំលោភបំពាន ដែលកើតមានជាញឹកញយលើនារីបម្រើការតាមផ្ទះនៅម៉ាឡេស៊ី ធ្វើឱ្យប្រជាជនកាន់តែមិនជ្រើសរើសវិធីតាមផ្លូវច្បាប់។

*"កាលពីពេលថ្មីៗនេះ មានបញ្ហាមួយអំពីនារីបម្រើការតាមផ្ទះម្នាក់ បានទទួលរងការរំលោភសេពសន្ថវៈ ពីសំណាក់និយោជកបុរសរបស់ខ្លួននៅម៉ាឡេស៊ី។ នាងត្រូវភរិយារបស់និយោជកនោះ ធ្វើទារុណកម្មធ្ងន់ធ្ងររាល់ថ្ងៃដោយសារការប្រច័ណ្ឌ... គ្រួសារជនរងគ្រោះបានទាមទារសំណង... ឥឡូវនេះក្រុមហ៊ុនជ្រើសរើសពលករ កំពុងតែលាក់នារីនោះពីអាជ្ញាធរ... ពួកគេនិយាយថា គេថែទាំនាងនោះបានយ៉ាងល្អ ហើយបញ្ជូនមកផ្ទះវិញ បន្ទាប់ពីការព្យាបាល" (មន្ត្រីមួយរូបនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី១៦ កុម្ភៈ ២០១១)។*

ទីតាំងភូមិសាស្ត្រនៅជិត ក៏បង្កើនលំហូរជនទេសន្តរប្រវេសន៍មិនស្របច្បាប់ដែរ (Battistella 2002)។ កម្ពុជាមានព្រំដែនគោកប្រវែង ៨០៣គ.ម ជាមួយប្រទេសថៃដែលមានច្រកចូលក្រៅផ្លូវការជាច្រើន។ នៅកន្លែងខ្លះ ជនទេសន្តរប្រវេសន៍ ត្រូវធ្វើដំណើរកាត់ព្រៃ ហើយជួនកាលត្រូវស្នាក់នៅមួយយប់។ គេធ្វើដំណើរក្នុងយប់ងងឹត ដើម្បីជៀសវាងការឆ្មក់ដើរល្បាតរបស់ប៉ូលីសព្រំដែន។ ព្រំដែនដ៏វែងបែបនេះ ពិបាកត្រួតពិនិត្យណាស់។

ការបង្កើតបណ្តាញ ក៏ជួយសម្រួលលំហូរជនទេសន្តរប្រវេសន៍ ដែលជារឿយៗពឹងផ្អែកលើមិត្តភ័ក្តិ ឬសាច់ញាតិដែលកំពុងធ្វើការក្នុងប្រទេសទីដៅ ឬដែលដឹងពីវិធីរកការងារឱ្យពួកគេធ្វើ។ បណ្តាញប្រភេទនេះ ជួយកាត់បន្ថយបន្ទុកចំណាយលើការស្វែងរកការងារ និងបង្កើនលទ្ធភាពរកបានការងារធ្វើ (Chiuri *et al.* 2005)។ នៅកម្ពុជា លំហូរក្រៅផ្លូវការបានចាប់ផ្តើមតាំងពីមួយទសវត្សរ៍មុន នៅពេលដែលមានគ្រួសារមួយចំនួនតូច បានធ្វើទេសន្តរប្រវេសន៍ និងបានត្រឡប់មកវិញដោយមានជីវភាពប្រសើរជាងមុន រឿងនេះក៏បានទាក់ទាញប្រជាជនកាន់តែច្រើនដែរ។ អ្នកទាំងនោះបានបង្កើតជាបណ្តាញដើម្បីចែករំលែកព័ត៌មាន និងក្តីកង្វល់ពីការងារ និងលក្ខខណ្ឌការងារនៅក្នុងប្រទេសទីដៅ។

*"យើងមិនធ្វើចំណាកស្រុកទេ ប្រសិនបើយើងគ្មានស្គាល់អ្នកណាម្នាក់នៅម៉ាឡេស៊ីនោះ។ យើងមានមិត្តភ័ក្តិ ឬសាច់ញាតិ ដែលបច្ចុប្បន្នកំពុងធ្វើការនៅទីនោះ" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តបាត់ដំបង ថ្ងៃទី១៤ កុម្ភៈ ២០១១)។*

*"យើងមិនស្គាល់ផ្លូវទៅកាន់កន្លែងធ្វើការនៅប្រទេសថៃទេ ពីព្រោះយើងត្រូវលាក់ខ្លួនក្នុងរថយន្តនៅពេលធ្វើដំណើរម្តងៗ។ នេះជាមូលហេតុដែលយើងត្រូវការមេខ្យល់" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តបាត់ដំបង ថ្ងៃទី២១ កញ្ញា ២០១០)។*

# ៤ បញ្ហា និងការប្រឈមនៃទេសន្តរប្រវេសន៍មិនស្របច្បាប់

*"ចំនួនជនទេសន្តរប្រវេសន៍មិនស្របច្បាប់ កំពុងកើនឡើង... អ្នកខ្លះបានជួបនឹងស្ថានភាពរំលោភបំពាន និងកេងប្រវ័ញ្ច ដូចជា ការយាយីផ្លូវភេទ និងផ្លូវកាយ ការបង្ខំឲ្យធ្វើការដោះបំណុល ការដកហូតឯកសារសម្គាល់ខ្លួន និងការគំរាមកំហែងរាយការណ៍ប្រាប់អាជ្ញាធរជាដើម ដោយពុំអាចទទួលបានកិច្ចការពារដ៏សក្តិសិទ្ធិតាមផ្លូវច្បាប់" (ILO "សេចក្តីសម្រេចចិត្តស្តីពីដំណោះស្រាយដោយយុត្តិធម៌សម្រាប់ពលករទេសន្តរប្រវេសន៍នៅក្នុងសេដ្ឋកិច្ចសាកល")។*

បើប្រៀបធៀបជាមួយជនទេសន្តរប្រវេសន៍ស្របច្បាប់ ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ប្រឈមនឹងហានិភ័យខ្ពស់ ត្រូវគេកេងប្រវ័ញ្ច និងបដិសេធមិនឱ្យមានសិទ្ធិជាមូលដ្ឋាន ដូចជាការទទួលបានការថែទាំសុខភាព និងការអប់រំជាដើម (IOM 2003)។ មានឯកសារច្បាស់លាស់ជាច្រើនបញ្ជាក់ពីការរំលោភបំពានលើពលករទេសន្តរប្រវេសន៍ពីសំណាក់និយោជក រួមមានការបង្ខំឱ្យធ្វើការហួសម៉ោង ការកាត់ប្រាក់ខែ និងការយាយីផ្លូវភេទ។ ការផ្តល់ថ្លៃឈ្នួលទាប (Shah 2009) និងលក្ខខណ្ឌការងារអន់ខ្សោយជាងកម្រិតមធ្យម (Stoyanova 2008) ក៏មានឯកសារបញ្ជាក់ដូចគ្នាដែរ។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ ក៏ពាក់ព័ន្ធនឹងការជួញដូរមនុស្សផងដែរ។

ក្នុងចំណោមជនទេសន្តរប្រវេសន៍មិនស្របច្បាប់កម្ពុជានៅប្រទេសថៃ មានកើតករណីកេងប្រវ័ញ្ច រំលោភបំពាន និងជួញដូរមនុស្សជាច្រើន។ លោក Naro (2009) បានចងក្រងករណីសិក្សាពីជនទេសន្តរប្រវេសន៍កម្ពុជា ដែលទទួលរងការធ្វើបាបពីសំណាក់និយោជកខ្លួន ដោយអ្នកខ្លះត្រូវធ្វើការហួសម៉ោង និងបានប្រាក់ខែទាប ហើយខ្លះទៀតទទួលរងការធ្វើទុក្ខបុកម្នេញផ្លូវកាយនៅពេលពួកគេបដិសេធមិនធ្វើតាមការបញ្ជា។ Marshall (2001) បានផ្តល់ភស្តុតាងពីកុមារកម្ពុជា ត្រូវគេជួញដូរឱ្យធ្វើជាអ្នកសុំទាន និងអ្នកលក់ផ្កានៅប្រទេសថៃ ចំណែកឯជនទេសន្តរប្រវេសន៍ជាស្ត្រី ត្រូវគេបង្ខំឱ្យធ្វើជាអ្នករកស៊ីផ្លូវភេទ។ យោងតាម UNIAP (2010) ជារៀងរាល់ឆ្នាំមានជនជាតិកម្ពុជារាប់ពាន់នាក់ ត្រូវគេជួញដូរទៅប្រទេសថៃ។ ជារឿយៗ បុរសត្រូវគេជួញដូរឱ្យធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់។ នារីត្រូវគេជួញដូរឲ្យបម្រើការក្នុងឧស្សាហកម្មកំសាន្ត ពោលគឺ ពេស្យាចារ។

ការនេសាទតាមទូកសមុទ្រ ជាការងារមានគ្រោះថ្នាក់ និងការរំលោភបំពានច្រើនជាងគេ ទៅលើជនទេសន្តរប្រវេសន៍ជាបុរស ដែលភាគច្រើនមកពីប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា។ ក្រៅពីការទទួលបានប្រាក់ខែទាប ជនទេសន្តរប្រវេសន៍មានលក្ខខណ្ឌការងារលំបាកណាស់ ដោយត្រូវប្រឈមនឹងការដាក់ទណ្ឌកម្មផ្លូវកាយធ្ងន់ធ្ងរ ប្រសិនបើពួកគេមានកំហុស ដូចជា គ្រាន់តែសម្រាកបន្តិចក្នុងម៉ោងធ្វើការ ទោះបីពួកគេត្រូវធ្វើការយ៉ាងច្រើនរហូតដល់ ១៥ម៉ោងក្នុងមួយថ្ងៃ ឬលើសពីនេះទៀត ហើយក៏មានរបាយការណ៍ពីករណីដែលជនទេសន្តរប្រវេសន៍ ត្រូវគេបង្ខំឱ្យប្រើគ្រឿងញៀន ដើម្បីអាចទ្រាំទ្រនឹងការងារធ្ងន់ធ្ងរបាន (ICSW 2007)។ ជនទេសន្តរប្រវេសន៍ខ្លះ ត្រូវគេជួញដូរ និងត្រូវបានគេលក់ដោយពុំដឹងខ្លួន ហេតុនេះត្រូវធ្វើការជាច្រើនឆ្នាំ ដើម្បីសងបំណុល (*Ibid*)។

*"កម្មករធ្វើការលើទូកនេសាទ ត្រូវប្រឈមនឹងហានិភ័យជាច្រើន ជាអាទិ៍ មហន្តរាយធម្មជាតិ ដូចជាខ្យល់ព្យុះជាដើម ឬក៏ធ្លាក់ខ្លួនឈឺនៅលើទូក (ដែលមានន័យថា) មិនអាចបញ្ជូនទៅមន្ទីរពេទ្យទាន់ពេលទេ" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តព្រៃវែង ថ្ងៃទី៣០ កញ្ញា ២០១០)។*

*"មានជនជាតិកម្ពុជាជាច្រើន (ជនទេសន្តរប្រវេសន៍) បានស្លាប់ក្នុងការងារប្រភេទនេះ (ជាអ្នកនេសាទ)" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី១០ មីនា ២០១១)។*

ក្នុង FGDs នាពេលថ្មីៗ ក៏មានលើកឡើងពីករណីជនទេសន្តរប្រវេសន៍កម្ពុជា មិនស្របច្បាប់ មិនបានទទួលប្រាក់ខែតាមការព្រមព្រៀងគ្នា ហើយរឿងនេះក៏មានច្រើនដែរក្នុងចំណោមជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាទូទៅ (Shah 2009)។ អ្នកខ្លះត្រូវក្រុមបងធំឆក់ប្លន់ ខ្លះទៀតត្រូវចាប់ខ្លួនដោយសារគ្មានឯកសារត្រឹមត្រូវ ហើយត្រូវទទួលរងការពិន័យជាប្រាក់ ហើយបញ្ជូនមកកម្ពុជាវិញ។ ជនទេសន្តរប្រវេសន៍កម្ពុជាមិនស្របច្បាប់ ត្រូវបានគេផាត់ចេញ ត្រូវប្រឈមនឹងការរំលោភបំពាន ហើយមិនអាចទទួលបានសេវាកម្មខាងសង្គមកិច្ចទេ ពីព្រោះការជៀសវាងពួកអាជ្ញាធរជាវិធីតែមួយគត់ ដើម្បីសុវត្ថិភាពនៃការរស់នៅដោយលួចលាក់នេះ។

*"ខ្ញុំត្រូវមេក្រុមបោកប្រាស់... គាត់មិនបើកប្រាក់ខែឱ្យខ្ញុំទេ... ពួកគេគំរាមរាយការណ៍ប្រាប់ប៉ូលីសពីស្ថានភាពខុសច្បាប់របស់ខ្ញុំ" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តបន្ទាយមានជ័យ ថ្ងៃទី៤ កញ្ញា ២០១០)។*

*"ខ្ញុំជាអតីតជនទេសន្តរប្រវេសន៍ខុសច្បាប់ម្នាក់។ ខ្ញុំត្រូវប៉ូលីសថៃចាប់ខ្លួន... ខ្ញុំត្រូវហូបខ្ទឹមជំនួសបាយនៅក្នុងគុក នៅថ្ងៃដែលគេបញ្ជូនខ្ញុំមកវិញ... វេទនាណាស់" (មន្ត្រីមួយរូបនៅខេត្តព្រៃវែង ថ្ងៃទី៣១ មករា ២០១១)។*

*"នៅពេលធ្លាក់ខ្លួនឈឺ ពួកគេមិនហ៊ានទៅពេទ្យទេ... ពួកគេទិញថ្នាំពីជនទេសន្តរប្រវេសន៍កម្ពុជាដូចគ្នា។ ប្រសិនបើជម្ងឺកាន់តែធ្ងន់ធ្ងរ ពួកគេនឹងរកផ្លូវមកផ្ទះវិញ" (មន្ត្រីមួយរូបនៅខេត្តបាត់ដំបង ថ្ងៃទី១៤ កុម្ភៈ ២០១១)។*

បញ្ហាមួយទៀតពាក់ព័ន្ធនឹងការអប់រំពួកកុមារជាកូនរបស់ជនទេសន្តរប្រវេសន៍។ តាមធម្មតា ឪពុកម្តាយតែងទុកកូននៅក្នុងប្រទេសកម្ពុជា ប្រសិនបើមានអ្នកថែទាំដែលជាទូទៅ គឺជាជីដូនជីតា។ ប្រសិនបើគ្មានអ្នកមើលទេ ពួកគេត្រូវនាំកូនទៅជាមួយ។ នៅឯបរទេស ពួកគេមិនអាចបញ្ជូនកូនទៅរៀនបានទេ ដោយសារស្ថានភាពខុសច្បាប់របស់ខ្លួន។

*" ...ពួកគេដឹងថាមិនល្អទេក្នុងការនាំកូនទៅជាមួយ ប៉ុន្តែពួកគេអាចធ្វើអ្វីបាន? ប្រសិនបើពួកគេមិនទៅ តើធ្វើម៉េចអាចរកប្រាក់បាន?" (មន្ត្រីមួយរូបនៅខេត្តកំពង់ធំ ថ្ងៃទី៣ កុម្ភៈ ២០១១)។*

ការធ្វើដំណើរតាមមធ្យោបាយខុសច្បាប់មិនដែលស្រួលទេ។ កម្មករត្រូវធ្វើដំណើរទាំងយប់ ហើយដើរកាត់ផ្លូវជាច្រើនមុនទៅដល់កន្លែងធ្វើការ។ មានរបាយការណ៍ពីករណីដែលជនទេសន្តរប្រវេសន៍ត្រូវមេខ្យល់បោះបង់ចោលនៅកណ្តាលផ្លូវ ហើយត្រូវរកផ្លូវទៅកន្លែងធ្វើការ ឬត្រឡប់មកផ្ទះវិញដោយខ្លួនឯង ប្រសិនបើពួកគេមានសំណាងអាចជៀសផុតពីប៉ូលីសថៃ។

*" ...ជនទេសន្តរប្រវេសន៍ ៤០នាក់ត្រូវមេខ្យល់បោះបង់ចោល... គ្មានផ្តល់ការងារអ្វីទេ... រដ្ឋាភិបាល (បន្ទាប់មក) បានជួយអ្នកទាំងនោះឱ្យមកផ្ទះវិញនៅពេលមានជម្លោះរវាងកម្ពុជា និងថៃ" (មន្ត្រីមួយរូបនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី១៧ កុម្ភៈ ២០១១)។*

ដើម្បីបង់ថ្លៃឈ្នួលជើងសារ ជនទេសន្តរប្រវេសន៍ភាគច្រើនរកប្រាក់កម្ចី ឬជឿមេខ្យល់សិន។ នេះជាមហន្តរាយមួយ ប្រសិនបើគេមិនអាចរកការងារនៅប្រទេសទីដៅ ឬត្រូវប៉ូលីសចាប់ខ្លួន ហើយបញ្ជូនមកផ្ទះវិញ។ ពួកគេត្រូវសងបំណុលនេះដោយលក់ទ្រព្យសម្បត្តិផ្សេងៗរបស់គ្រួសារជាដើម។

*"...ពលករខ្លះ ត្រឡប់មកវិញដោយជាប់បំណុលគេ ព្រោះមិនអាចរកការងារធ្វើបាននៅម៉ាឡេស៊ី...គ្រួសាររបស់គេបានលក់ដីស្រែ ឬលក់ដល់ដីផ្ទះទៀត ដើម្បីសងបំណុលមេខ្យល់" (ជនទេសន្តរប្រវេសន៍ត្រឡប់មកភូមិវិញ នៅខេត្តបាត់ដំបង ថ្ងៃទី៥ តុលា ២០១០)។*

ទេសន្តរប្រវេសន៍មិនស្របច្បាប់ បានក្លាយជាប្រធានបទយ៉ាងក្តៅគគុកសម្រាប់អ្នកធ្វើគោលនយោបាយជាតិទាំង

នៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល ដោយសារផលប៉ះពាល់អវិជ្ជមានជាច្រើនរបស់វា (Vutha *et al.* 2011)។ លំហូរក្រៅផ្លូវការច្រើនពាសពេញ អាចគំរាមកំហែងដល់អធិបតេយ្យភាពរបស់ប្រទេស បើកឱកាសដល់ការកកើតក្រុមភេរវករ និងបង្កហានិភ័យដល់សន្តិសុខរដ្ឋ (Koser 2005; Koslowski 2004)។ ខុសប្លែកពីជនទេសន្តរប្រវេសន៍ស្របច្បាប់ សុខភាពរបស់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ គ្មានការត្រួតពិនិត្យមុនពេលចេញដំណើរទេ ដូច្នេះការរីករាលដាលជម្ងឺឆ្លងជាយថាហេតុ គឺជាកង្វល់មួយ។ បញ្ហាសុខាភិបាលបង្កឡើងដោយទេសន្តរប្រវេសន៍មិនស្របច្បាប់នេះ មានលើកឡើងក្នុង MacPherson and Gushulak (2004) ។

ជនទេសន្តរប្រវេសន៍ជាសក្តានុពលជាច្រើននាក់ បានទទួលព័ត៌មានពីបញ្ហាដែលពួកគេអាចជួបប្រទះ។ ជាទូទៅ មេដឹកនាំមូលដ្ឋាន ជាមេភូមិ ឬមេឃុំ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល បានណែនាំពួកគេច្រើនណាស់ពីគ្រោះថ្នាក់នៃទេសន្តរប្រវេសន៍ខុសច្បាប់។ មិត្តភ័ក្តិ ឬសាច់ញាតិដែលជាអតីតជនទេសន្តរប្រវេសន៍ ក៏បានប្រាប់ពួកគេរឿងរ៉ាវច្រើនដែរ។ ទោះយ៉ាងនេះក្តី ការប្រមើលឃើញប្រាក់ចំណូលខ្ពស់នៅប្រទេសទីដៅ គួបផ្សំនឹងបញ្ហាសេដ្ឋកិច្ចក្នុងប្រទេសដើមរបស់ខ្លួន បានជំរុញពួកគេឱ្យធ្វើដំណើរដោយខុសច្បាប់ ដែលជាផ្លូវងាយស្រួលបំផុតនៃការធ្វើទេសន្តរប្រវេសន៍។

ដើម្បីដោះស្រាយបញ្ហា ទាំងប្រទេសបញ្ជូន និងប្រទេសទទួល បានលើកឡើងនូវវិធានការជាច្រើន។ ឧទាហរណ៍ ប្រទេសថៃបានផ្តួចផ្តើមធ្វើឱ្យជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ក្លាយជាស្របច្បាប់ដោយផ្តល់ប័ណ្ណធ្វើការដល់ពួកគេ ពង្រឹងការត្រួតពិនិត្យនៅព្រំដែន ដាក់ទណ្ឌកម្មនិយោជកដែលជួលជនទេសន្តរប្រវេសន៍គ្មានឯកសារត្រឹមត្រូវ និងនិរទេសជនទេសន្តរប្រវេសន៍ដែលចាប់បាន។ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ កំពុងធ្វើការលើកកម្ពស់ការយល់ដឹងអំពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាពដល់ជនទេសន្តរប្រវេសន៍ជាសក្តានុពល និងកំពុងកសាងគោលនយោបាយទេសន្តរប្រវេសន៍កម្លាំងពលកម្មដ៏រឹងប៉ឹងមួយផងដែរ។

**ករណីសិក្សា៖ ការដាក់ពន្ធនាគារ**

សារុន មានអាយុ២២ឆ្នាំ ជាកូនប្រុសក្នុងគ្រួសារក្រីក្រមួយនៅភូមិរំដួល ឃុំភ្នំលៀប ខេត្តបន្ទាយមានជ័យ។ សារុន បានសម្រេចចិត្តចាកចេញពីមាតុប្រទេស ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ បន្ទាប់ពីអស់សង្ឃឹមក្នុងការរកការងារនៅក្នុងភូមិ។ សារុន បានជឿតាមមិត្តភ័ក្តិ និងអ្នកជិតខាងដែលធ្លាប់ទៅធ្វើការនៅប្រទេសថៃ។ សារុន បានចាកចេញដោយពុំគិតពីហានិភ័យដែលអាចជួបប្រទះនោះទេ។

ដើម្បីទៅទីនោះ ដំបូង សារុន ត្រូវទាក់ទងមេខ្យល់ម្នាក់ដែលអ្នកជិតខាងណែនាំឱ្យស្គាល់។ សារុន ត្រូវបង់ប្រាក់ ៣០ម៉ឺនរៀល (ប្រហែល ៧៥ដុល្លារអាមេរិក) ដល់មេខ្យល់ ដើម្បីឲ្យជួយខ្លួនឆ្លងព្រំដែនទៅកន្លែងធ្វើការ។ សារុន ធ្វើដំណើរពីភូមិខ្លួនទៅប្រទេសថៃ តាមច្រកព្រំដែនបឹងត្រកួន នៅខេត្តបន្ទាយមានជ័យ។ សារុន មិនអាចរកប្រាក់បង់ឱ្យមេខ្យល់បានទេ ប៉ុន្តែគេអនុញ្ញាតឱ្យគាត់ជំពាក់សិន ដោយត្រូវកាត់ប្រាក់ខែសង បូកនឹងការប្រាក់ចំនួន ៥%។

នៅបាងកក សារុន បានការងារនៅរោងជាងដែកមួយដោយគាត់ត្រូវធ្វើការ ៩ម៉ោងក្នុងមួយថ្ងៃ ហើយទទួលប្រាក់ឈ្នួលប្រចាំថ្ងៃចំនួន ២៧០០០រៀល (ប្រហែល ៧ដុល្លារអាមេរិក)។ បន្ទាប់ពីធ្វើការនៅទីនោះបានមួយរយៈ គាត់ត្រូវប៉ូលីសថៃចាប់ខ្លួន ហើយសួររកលិខិតអនុញ្ញាតឲ្យធ្វើការស្របច្បាប់ដែលគាត់ពុំមានទេ។ គាត់ត្រូវជាប់ពន្ធនាគារ ៧ថ្ងៃ មុនពេលត្រូវនិរទេសមកកម្ពុជាវិញ។

សារុន អស់សង្ឃឹមយ៉ាងខ្លាំង ពីព្រោះប្រាក់ដែលគាត់រកបាន អាចត្រឹមតែសងមេខ្យល់ និងចំណាយធ្វើដំណើរតែប៉ុណ្ណោះ។ ប្រាក់គាត់សន្សំបាន មានតិចពេក មិនអាចទិញដីស្រែមួយក្បាលដែលគ្រួសាររបស់គាត់ចង់បាននោះទេ។

# ៥ ក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័ន

## ៥.១ គោលនយោបាយ

គោលនយោបាយទេសន្តរប្រវេសន៍ពលកម្មរបស់កម្ពុជា ទើបបានកំណត់ឡើងនាពេលថ្មីៗ ដើម្បីបង្កើនការបញ្ជូនពលករទៅបរទេស ក៏ដូចជាគ្រប់គ្រង ការពារ និងផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសន៍កម្ពុជា។ ឯកសារគោលនយោបាយដំបូងស្តីពីទេសន្តរប្រវេសន៍ពលកម្មមានចុះក្នុង *ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៩-២០១៣* របស់ក្រសួងការងារ។ ផែនការមានចែងពីគោលដៅ[2] នៃការជំរុញពលកម្មនៅបរទេស ដើម្បីដោះស្រាយបញ្ហាកំណើនកម្លាំងពលកម្មដោយ ១) កែលម្អការគ្រប់គ្រងសេវាកម្ម ផ្តល់ការងារនៅបរទេសតាមរយៈក្រុមហ៊ុនឯកជន ២) បង្កើតប្រព័ន្ធផ្តល់ប័ណ្ណការងារ ៣) ការពារពលករទេសន្តរប្រវេសន៍។

ឯកសារគោលនយោបាយសំខាន់ទី២ គឺ *គោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ពលកម្មសម្រាប់កម្ពុជា*។ គោលនយោបាយនេះលើកឡើងពីបញ្ហាប្រឈម ៣យ៉ាង គឺអភិបាលកិច្ចលើទេសន្តរប្រវេសន៍ កិច្ចការពារ និងការផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសន៍ និងទេសន្តរប្រវេសន៍និងអភិវឌ្ឍន៍។ បញ្ហាប្រឈមនៃអភិបាលកិច្ច ពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ពលកម្មដ៏ល្អមួយ ក្របខ័ណ្ឌច្បាប់ និងការគ្រប់គ្រងទេសន្តរប្រវេសន៍ដោយផ្អែកលើលិខិតុបករណ៍អន្តរជាតិ និងកិច្ចសន្ទនាក្នុងសង្គម។ បញ្ហាប្រឈមនៃកិច្ចការពារ និងការផ្តល់សិទ្ធិអំណាចពាក់ព័ន្ធនឹងវិធីសាស្ត្រ ផ្អែកលើសិទ្ធិដើម្បីបង្ការ និងការពារប្រឆាំងនឹងការប្រព្រឹត្តិបំពានលើទេសន្តរប្រវេសន៍ និងការអនុវត្ត និងការពង្រឹងបទបញ្ញត្តិច្បាប់ជាតិ ដោយអនុលោមតាមស្តង់ដារពលកម្មអន្តរជាតិ និងលិខិតុបករណ៍ថ្នាក់តំបន់។ បញ្ហាប្រឈមនៃទេសន្តរប្រវេសន៍ និងអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការបញ្ជ្រាបបញ្ហាទេសន្តរប្រវេសន៍ពលកម្មក្នុងរបៀបវារៈនៃការអភិវឌ្ឍជាតិ ការបង្កើតប្រព័ន្ធទទួលស្គាល់ជំនាញដែលទទួលបានពីទេសន្តរប្រវេសន៍កម្លាំងពលកម្ម ការជំរុញការប្រើប្រាស់ឲ្យមានផលិតភាពនូវប្រាក់ទៅផ្ទះ ដើម្បីអភិវឌ្ឍសហគមន៍ ការផ្តល់សេវានាំពលករត្រឡប់មកវិញ និងធ្វើសមាហរណកម្មជាថ្មីចូលក្នុងសហគមន៍ និងការបង្កើតចំណងទាក់ទងជួយគាំទ្រដល់ប្រជាជននៅក្រៅប្រទេស។

ថ្វីបើគោលនយោបាយបានកំណត់ឡើង ឆ្លងតាមការពិគ្រោះយោបល់ជាមួយស្ថាប័នសាធារណៈ ទីភ្នាក់ងារផ្តល់ជំនួយ អង្គការពលករនិងនិយោជក ក្រុមហ៊ុនជ្រើសរើសពលករ និងអង្គការមិនមែនរដ្ឋាភិបាល ដោយពិចារណាលើការអនុវត្តល្អៗនៅអន្តរជាតិក្តី ក៏គេបានសង្កេតឃើញនូវកង្វះភាពស៊ីចង្វាក់គ្នា និងការធ្វើសុខដុមនីយកម្ម រវាងផែនការអភិវឌ្ឍន៍ជាតិ និងគោលនយោបាយទេសន្តរប្រវេសន៍ ទោះបីជាមានការទទួលស្គាល់ជាទូទៅថា ទេសន្តរប្រវេសន៍ពលកម្មឆ្លងកាត់ព្រំដែន បានជួយរួមចំណែកដល់កំណើន ការអភិវឌ្ឍ និងការលើកកម្ពស់កម្រិតជីវភាព។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៥-២០០០ និង ២០០១-២០០៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រជាតិ បានធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ២០០៩-១៣ ដែលផ្តល់ការណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា គ្មានចែងពីផែនការសកម្មភាពសម្រាប់ទេសន្តរប្រវេសន៍ពលកម្មទេ ទោះដោយចំហឬដោយបង្កប់ន័យក្តី។ ការធ្វើសុខដុមនីយកម្មផ្នែកគោលនយោបាយ រវាងទេសន្តរប្រវេសន៍ និងវិស័យឯទៀត ពុំឃើញមានអ្វីច្បាស់លាស់ទេ ថ្វីបើទេសន្តរប្រវេសន៍ស្ថិតក្នុងសិទ្ធិអំណាចនៃក្រសួង និងស្ថាប័នជាច្រើនក្តី។ ក្រៅពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចេញ បញ្ហាទេសន្តរប្រវេសន៍មិនមានចែងក្នុងផែនការអភិវឌ្ឍន៍សហគមន៍ ឬផែនការអភិវឌ្ឍន៍តាមវិស័យទេ។ កង្វះចំណងទាក់ទងខាងគោលនយោបាយ តាមខ្សែឈរ និងខ្សែដេក នាំឱ្យមានការផ្លាស់ប្តូរព័ត៌មានគ្នា

2 វិស័យអាទិភាពទាំង៦នៅក្នុងផែនការគឺ ១) បង្កើតការងារ ២) ធានាលក្ខខណ្ឌការងារល្អ ៣) ជំរុញការពង្រឹងអនុវត្តច្បាប់ ស្តីពីសន្តិសុខសង្គម ៤) កសាងសមត្ថភាពក្នុងជំនាញបច្ចេកទេស និងជំនាញវិជ្ជាជីវៈ ៥) បញ្ជ្រាបយេនឌ័រក្នុងការបណ្តុះបណ្តាលការងារ និងវិជ្ជាជីវៈ ៦) ពង្រឹងស្ថាប័ន ភាពជាដៃគូ ប្រសិទ្ធភាពការងារ និងគណនេយ្យភាព។

មិនគ្រប់គ្រាន់ ការពិគ្រោះយោបល់អន្តរក្រសួងមិនទៀងទាត់ និងកង្វះកម្មវិធីរួមគ្នា។ ការពិគ្រោះយោបល់គ្នា នៅខ្វះខាតជាខ្លាំង។ កន្លងមកមិនមានកិច្ចសន្ទនាយ៉ាងទៀងទាត់ សព្វគ្រប់ ដោយមានព័ត៌មានគ្រប់គ្រាន់ស្ដីពីបញ្ហាទេសន្តរប្រវេសន៍ និងអភិវឌ្ឍន៍ទេ។ ប្រការនេះនាំទៅដល់ស្ថានភាពមួយដែលទំនុកចិត្តគ្នាទៅវិញទៅមក កិច្ចសហការ និងការប្រឹងប្រែងបំពេញបន្ថែមឲ្យគ្នាចុះឡើង វាមានកម្រិតទាប។

គោលនយោបាយដែលមិនសូវរលូនគ្នានេះ វាកាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារគេមិនបានដាក់បញ្ចូលបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់នៅក្នុងក្របខ័ណ្ឌគោលនយោបាយទេ។ វិធានការ ឬផែនការសម្រាប់ដោះស្រាយទេសន្តរប្រវេសន៍មិនស្របច្បាប់ មិនសូវឃើញមានទេនៅក្នុងម៉ាទ្រីសគោលនយោបាយ។ ផ្ទុយទៅវិញ ផែនការភាគច្រើនសំដៅកែលម្អក្របខ័ណ្ឌច្បាប់មានស្រាប់ ពិនិត្យតាមដាន និងត្រួតពិនិត្យការជ្រើសរើស និងផ្តល់ការងារ ការការពារ និងផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសន៍ និងការប្រើប្រាស់ទេសន្តរប្រវេសន៍ពលកម្ម ដើម្បីធ្វើការអភិវឌ្ឍន៍។ អនុសាសន៍ក្នុងអន្តរាគមន៍ផ្នែកគោលនយោបាយទេសន្តរប្រវេសន៍វាសំខាន់ និងចាំបាច់ សម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍ ពីព្រោះបើអនុវត្តដោយប្រសិទ្ធភាព វាអាចជួយដោះស្រាយដោយប្រយោល និងបានមួយចំណែកដែរនូវបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ដែលគួរទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នា អំពីរបៀបវារៈគោលនយោបាយ។

## ៥.២ ក្របខ័ណ្ឌច្បាប់

ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធកូនកាត់មួយដែលរួមមាន បទបញ្ញត្តិច្បាប់ជាតិ កិច្ចព្រមព្រៀងទ្វេភាគី និងអនុសញ្ញាអន្តរជាតិ។ ការត្រួតពិនិត្យថ្នាក់ជាតិចំបងមួយគឺ អនុក្រឹត្យលេខ៥៧ ក្នុងខែកក្កដា ១៩៩៥ ស្ដីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស។ ក្នុងបំណងធ្វើឱ្យនិរប្រវេសន៍ (emigration) ពលកម្មឆ្លងព្រំដែនក្លាយជាផ្លូវការ ដោយផ្តល់ឱ្យ MLVT នូវសិទ្ធិអំណាចផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុនបញ្ជូនពលករកម្ពុជាទៅបរទេស អនុក្រឹត្យនេះផ្តល់ក្របខ័ណ្ឌច្បាប់ និងនីតិវិធី សម្រាប់សម្រួលសហប្រតិបត្តិការ រវាងក្រសួងការងារ និងក្រុមហ៊ុនជ្រើសរើសពលករ មានជាអាទិ៍ សំណើជ្រើសរើសពលករ ការតម្រូវឲ្យដាក់ប្រាក់តម្កល់ កិច្ចសន្យាការងារ និងការបណ្តុះបណ្តាលមុនពេលចេញដំណើរ។

អនុក្រឹត្យលេខ៥៧ គេមើលឃើញជាទូទៅថា ចាស់ហួសសម័យ និងខ្វះការគ្របដណ្តប់គ្រប់ជ្រុងជ្រោយ។ អនុក្រឹត្យនេះ មិនមានចែងពីអាណត្តិរបស់អង្គការដែលទទួលបន្ទុកគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម ឬក៏ការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមហ៊ុនជ្រើសរើសទេ។ អនុក្រឹត្យក៏មិនមានបទបញ្ញត្តិស្ដីពី ការត្រួតពិនិត្យលើការផ្តល់ការងារ និងកម្មវិធីបណ្តុះបណ្តាលដែរ។

អនុក្រឹត្យលេខ៥៧ ក៏គេយល់ថា មិនច្បាស់លាស់ បទបញ្ញត្តិភាគច្រើនមានន័យទូលំទូលាយពេក និងគ្មានភាពច្បាស់លាស់។ឧទាហរណ៍មាត្រា១០ចែងពីការឈប់សម្រាកប្រចាំឆ្នាំប៉ុន្តែគ្មានចែងពីសិទ្ធិទទួលបានព័ត៌មានពេញលេញត្រឹមត្រូវ សិទ្ធិធ្វើការផ្លាស់ទីដោយសេរី សិទ្ធិទទួលបានការអប់រំនិងសេវាថែទាំសុខភាព និងសិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌។ មាត្រា២០ ចែងថា ជនរំលោភបទបញ្ញត្តិច្បាប់ត្រូវទទួលទោសទណ្ឌ ប៉ុន្តែគ្មានចែងពីការដាក់ទោសទណ្ឌទេ។ មាត្រា១៤ ចែងថា ទាំង MLVT និងក្រុមហ៊ុនជ្រើសរើស ត្រូវទទួលខុសត្រូវលើការរៀបចំ និងបើកវគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរ ប៉ុន្តែគេមិនច្បាស់លាស់ទេថាតើការបណ្តុះបណ្តាលបែបនេះជាកាតព្វកិច្ច ឬយ៉ាងណា។ មាត្រានេះ គួរកែតម្រូវឡើងវិញ ដោយកំណត់ឲ្យក្រុមហ៊ុនជ្រើសរើសពលករទទួលខុសត្រូវរៀបចំវគ្គបណ្តុះបណ្តាល ស្របតាមកម្មវិធីតាមស្តង់ដារដែលរៀបចំឡើងដោយ MLVT[3]។

ដោយទទួលស្គាល់អំពី ចំណុចខ្វះខាតក្នុងក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងលើក្រុមហ៊ុនជ្រើសរើសពលករ និងការ

3 សំណើនេះបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍ពីកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិរបស់កម្ពុជាស្ដីពីកិច្ចការពារ និងការជំរុញសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ដែលដាក់ជូនដល់ក្រុមការងារចម្រុះទទួលបន្ទុកពលករទេសន្តរប្រវេសន៍អាស៊ាន។

មិនប្រតិបត្តិតាម និងការអនុវត្តខុសឆ្គងដោយក្រុមហ៊ុនខ្លះ (ការបណ្តុះបណ្តាលក្រោមស្តង់ដារ ការដាក់កំហិតលើការផ្លាស់ទីក្នុងអំឡុងពេលបណ្តុះបណ្តាល និងឯកសារក្លែងក្លាយសម្រាប់ពលករមិនទាន់គ្រប់អាយុ) រដ្ឋាភិបាលបានកែសម្រួលអនុក្រឹត្យ និងគោលការណ៍ណែនាំស្តីពីការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅបរទេស ក៏ដូចជាសេចក្តីណែនាំឱ្យបង្កើតមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនជ្រើសរើស។ អនុក្រឹត្យកែសម្រួលថ្មី បានដាក់ជូនរួចហើយដល់គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច។ សេចក្តីណែនាំបានចែងថា ក្រុមហ៊ុនត្រូវបញ្ជាក់ឱ្យច្បាស់លាស់ពីបន្ទុកចំណាយដែលត្រូវរ៉ាប់រងដោយពលករ ត្រូវរៀបចំការបណ្តុះបណ្តាលទៅតាមស្តង់ដារមួយដែល MLVT ទទួលយក និងត្រូវចៀសវាងការប្រើពលកម្មកុមារ និងការដាក់កំហិតលើការផ្លាស់ទី។ សេចក្តីណែនាំបានកំណត់ស្តង់ដារសម្រាប់កម្មវិធីបណ្តុះបណ្តាលរបស់ក្រុមហ៊ុន។ ទោះបីជាមានសេចក្តីណែនាំដូច្នេះក្តី ក៏នៅតែមានការមិនប្រតិបត្តិតាម និងការអនុវត្តខុសឆ្គង ពិសេសព្រឹត្តិការណ៍នាពេលថ្មីៗពាក់ព័ន្ធនឹង កម្មវិធីសម្រាប់អ្នកបំរើការតាមផ្ទះនៅបរទេស[4] ដែលបង្ហាញច្បាស់ពីចន្លោះប្រហោងក្នុងបទបញ្ញត្តិច្បាប់គ្រប់គ្រងលើក្រុមហ៊ុនជ្រើសរើស កង្វះការត្រួតពិនិត្យរបស់ស្ថាប័នទទួលខុសត្រូវ និងភាពទន់ខ្សោយនៃការពង្រឹងអនុវត្តច្បាប់។

បទបញ្ញត្តិឯទៀតៗរបស់កម្ពុជាពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ រួមមាន ១) ប្រកាសលេខ១០៨ ស្តីពីការអប់រំអំពីជម្ងឺអេដស៍ ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងសិទ្ធិការងារសម្រាប់ពលករកម្ពុជានៅបរទេស ២) អនុក្រឹត្យលេខ៧០ ស្តីពីការបង្កើតគណៈកម្មការបណ្តុះបណ្តាលពលករ និងការបញ្ជូនពលករទៅបរទេស ៣) ប្រកាសលេខ០១២/០៧ ស្តីពីការបង្កើតក្រុមការងារចម្រុះទទួលបន្ទុកទេសន្តរប្រវេសន៍ពលកម្ម និង ៤) អនុក្រឹត្យលេខ៦៨/២០០៩ ស្តីពីតម្លៃលិខិតឆ្លងដែនសម្រាប់ពលករទេសន្តរប្រវេសន៍។

អនុស្សារណៈនៃការយោគយល់ (MoUs) ទ្វេភាគីស្តីពីការបញ្ជូនពលករកម្ពុជាទៅបរទេស ក៏គ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្មដែរ។ ថ្វីបើ MoU មិនបង្កើតកាតព្វកិច្ចជាផ្លូវការក្តី ក៏មានការជជែកវែកញែកជាច្រើនថា វាជាយន្តការមួយអាចបត់បែនបានសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីលើចលនាឆ្លងព្រំដែន (Vasuprasat 2008)។ កម្ពុជាបានចុះហត្ថលេខាលើ MoUs ជាមួយម៉ាឡេស៊ី ថៃ សាធារណរដ្ឋកូរ៉េ និងគុយវ៉ែត។ ដោយគ្របដណ្តប់លើនីតិវិធីសម្រាប់ជ្រើសរើស ការពារ ធ្វើមាតុភូមិនិវត្ត និងដោះស្រាយទំនាស់ MoUs ផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់កិច្ចសហប្រតិបត្តិការដើម្បីគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍។ ជាមួយលិខិតុបករណ៍នេះ ក៏នៅមានចំណុចខ្វះខាតខ្លះនៅឡើយ។ ការជ្រើសរើសនៅប្រើពេលយូរ និងស្មុគស្មាញ ដោយពាក់ព័ន្ធនឹងទម្រង់បែបបទ និងការិយាធិបតេយ្យ ទាំងនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល។ ដំណើរការផ្តល់ការងារដែលប្រើពេលយូរ នាំឱ្យមានបន្ទុកចំណាយខ្ពស់។ លោក Chan (2009) បានបញ្ជាក់ថា ការជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ នៅក្រោម MoUs ត្រូវចំណាយពេលពី ៣-៦ខែ ពោលគឺ ពី ១-២ខែនៅថៃ និងពី ២-៤ខែនៅកម្ពុជា។

ទេសន្តរប្រវេសន៍ពលកម្ម ក៏គ្រប់គ្រងដោយអនុសញ្ញាអន្តរជាតិផងដែរ។ កម្ពុជាជាហត្ថលេខីលើអនុសញ្ញាអន្តរជាតិ និងតំបន់ជាច្រើន។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្នូលទាំង៨ របស់ ILO គឺមាន ១) អនុសញ្ញាស្តីពីសិទ្ធិបង្កើតសមាគម និងកិច្ចការពារសិទ្ធិរៀបចំ ឆ្នាំ១៩៤៨ (លេខ៨៧) ២) អនុសញ្ញាស្តីពីសិទ្ធិរៀបចំ និងធ្វើការចរចារួមគ្នាឆ្នាំ១៩៤៩ (លេខ៩៨) ៣) អនុសញ្ញាស្តីពីពលកម្មដោយបង្ខំឆ្នាំ១៩៣០ (លេខ២៩) ៤) អនុសញ្ញាស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំឆ្នាំ១៩៥៧ (លេខ១០៥) ៥) អនុសញ្ញាស្តីពីការផ្តល់ប្រាក់ឈ្នួលស្មើគ្នាឆ្នាំ១៩៥១ (លេខ១០០) ៦) អនុសញ្ញាស្តីពីការរើសអើង (ក្នុងមុខរបរ និងការងារ) ឆ្នាំ១៩៥៨ (លេខ១១១) ៧) អនុសញ្ញាស្តីពីអាយុអប្បបរមាឆ្នាំ១៩៧៣ (លេខ១៣៨) ៨) អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ១៩៩៩ (លេខ១៨២)។ កម្ពុជាក៏ជាហត្ថលេខីលើអនុសញ្ញាសហប្រជាជាតិស្តីពីកិច្ចការពារពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសារ

4 ព្រឹត្តិការណ៍ធ្ងន់ធ្ងរជាច្រើនបានកើតឡើងនៅក្រុមហ៊ុនជ្រើសរើសពលករ T&P៖ ស្ត្រីអាយុ ៣៥ឆ្នាំម្នាក់ បានស្លាប់នៅមណ្ឌលបណ្តុះបណ្តាល។ ស្ត្រីអាយុ ៣១ឆ្នាំម្នាក់ ត្រូវបាក់ជើងខណៈពេលព្យាយាមរត់គេចខ្លួន។ ក្រុមហ៊ុនបានធ្វើឯកសារក្លែងក្លាយសម្រាប់កុមារីមិនទាន់គ្រប់អាយុម្នាក់។

របស់ពលករ ដែលជាអនុសញ្ញាមួយមានចែងជាក់លាក់បំផុតអំពីទេសន្តរប្រវេសន៍ពលកម្ម និងជាហត្ថលេខីលើសេចក្ដីប្រកាសអាស៊ានស្ដីពីកិច្ចការពារ និងការជំរុញសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ដែលបានអនុម័តនៅថ្ងៃទី ១៣ មករា ២០០៧។ កម្ពុជាស្ថិតក្នុងចំណោម ១៨ប្រទេស[5] ដែលបានអនុម័តលើសេចក្ដីប្រកាសទីក្រុងបាងកក ស្ដីពីទេសន្តរប្រវេសន៍មិនស្របច្បាប់នៅឆ្នាំ១៩៩៩។ ថ្វីបើអនុសញ្ញាគ្មានភ្ជាប់កាតព្វកិច្ចជាផ្លូវការក្ដី ក៏វាមានប្រយោជន៍ធ្វើឱ្យប្រទេសហត្ថលេខី ប្រឹងអនុវត្តការប្ដេជ្ញាចិត្ត និងភារកិច្ចរបស់ខ្លួន។ ប៉ុន្តែភាគច្រើននៃប្រទេសទទួលពលករ មិនចុះហត្ថលេខាលើអនុសញ្ញាសំខាន់ៗនោះទេ។

## ៥.៣ ក្របខ័ណ្ឌស្ថាប័ន

បញ្ហាទេសន្តរប្រវេសន៍ស្ថិតក្នុងសមត្ថកិច្ចនៃស្ថាប័ន និងក្រសួងផ្សេងៗ រួមមាន ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងគណៈរដ្ឋមន្ត្រី។ MLVT គឺជាស្ថាប័នស្នូលដែលទទួលបន្ទុកទេសន្តរប្រវេសន៍ពលកម្ម។ នាយកដ្ឋានមុខរបរ និងកម្លាំងពលកម្ម នៃអគ្គនាយកដ្ឋានការងារ គឺជាស្ថាប័នចម្បងដែលគ្រប់គ្រងការបញ្ជូនពលករកម្ពុជាទៅបរទេស ជ្រើសរើសនិងចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនជ្រើសរើសពលករ ពិនិត្យតាមដាននិងវាយតម្លៃក្រុមហ៊ុនជ្រើសរើស ដោះស្រាយវិវាទរវាងពលករទេសន្តរប្រវេសន៍ និងក្រុមហ៊ុនផ្ដល់ការងារក្នុងស្រុក និងរវាងពលករទេសន្តរប្រវេសន៍និងនិយោជក គាំទ្រក្រុមហ៊ុនផ្ដល់ការងារក្នុងការបញ្ជូនពលករទៅបរទេស និងទប់ស្កាត់ការជ្រើសរើសខុសច្បាប់។ នាយកដ្ឋានមាន ៥ ការិយាល័យ ទទួលបន្ទុកលើអធិការកិច្ចពលកម្ម វិវាទខាងពលកម្ម ការងារនិងកម្លាំងពលកម្ម ពលកម្មកុមារនិងសុខភាព និងសុវត្ថិភាពការងារ។ អនុក្រឹត្យលេខ៧០ នៅខែកក្កដា ២០០៦ បានបន្ថែមគណៈកម្មាធិការទទួលបន្ទុកការបណ្ដុះបណ្ដាលពលករ និងបញ្ជូនពលករទៅបរទេសនៅក្នុងរចនាសម្ព័ន្ធ។ គណៈកម្មាធិការនេះ មានមុខងារជាស្ថាប័នជ្រើសរើសសាធារណៈ ដែលទទួលបន្ទុកជ្រើសរើស បណ្ដុះបណ្ដាល និងបញ្ជូនពលករទៅកូរ៉េខាងត្បូង។

ក្រសួងឯទៀតមានការចូលរួមមិនសូវច្រើនទេ និងលើប្រការជាក់លាក់។ ក្រសួងមហាផ្ទៃ ទទួលខុសត្រូវផ្ដល់លិខិតឆ្លងដែន និងទប់ស្កាត់ការជ្រើសរើសខុសច្បាប់ និងការជួញដូរមនុស្សឆ្លងដែន។ ក្រសួងការបរទេស ទទួលបន្ទុកចែកចាយឯកសារ និងបទបញ្ញត្តិពាក់ព័ន្ធទាំងអស់ ជួយសម្របសម្រួលទេសន្តរប្រវេសន៍ពលកម្មស្របច្បាប់ ព្រមទាំងគ្រប់គ្រង និងដោះស្រាយវិវាទរវាងពលករ និងនិយោជកនៅក្នុងប្រទេសទទួល តាមរយៈស្ថានទូតកម្ពុជា។ គណៈរដ្ឋមន្ត្រី ចូលរួមក្នុងក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្ត MoU ជាមួយថៃ។ មានក្រុមការងារអន្តរក្រសួងពីរក្រុម ដែលធ្វើការងារជាក់លាក់ផ្នែកទេសន្តរប្រវេសន៍។ ក្រុមទទួលបន្ទុកអនុវត្ត MoU ជាមួយថៃ បានបង្កើតឡើងនៅថ្ងៃទី១០ មករា ២០០៥ ដោយមានសមាជិកមកពី MLVT ក្រសួងការបរទេស ក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី។ ភារកិច្ចចំបងរបស់ក្រុមនេះគឺ ពិនិត្យសញ្ជាតិរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាខុសច្បាប់ និងចេញឱ្យពួកគេនូវវិញ្ញាបនប័ត្រសម្គាល់ខ្លួន។ ក្រុមការងារចម្រុះអន្តរក្រសួងទទួលបន្ទុកទេសន្តរប្រវេសន៍ ត្រូវបានបង្កើតឡើងដោយប្រកាសលេខ ០១២/០៧ នៅខែមករា ២០០៧ ដើម្បីបង្កើត និងអនុវត្តគោលនយោបាយ និងសកម្មភាពការងារស្ដីពីទេសន្តរប្រវេសន៍ពលកម្ម។

មានអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដែលធ្វើការងារលើផ្នែកទេសន្តរប្រវេសន៍គឺ IOM, ILO, UNIFEM, UNIAP អង្គការសម្របសម្រួលសកម្មភាពស្រាវជ្រាវ លើជំងឺអេដស៍ អង្គការទេសន្តរប្រវេសន៍កម្ពុជា និងអង្គការគាំទ្រផ្លូវច្បាប់សម្រាប់កុមារ និងស្ត្រី។ ពួកគេផ្ដោតលើវិស័យផ្សេងៗ និងអ្នកទទួលផលជាច្រើន។ កម្មវិធីទេសន្តរប្រវេសន៍របស់ ILO ផ្ដោតលើអភិបាលកិច្ចពលកម្ម សិទ្ធិ និងការទទួលបានការងារសមរម្យ និងមានផលិតភាព។ IOM ផ្ដោតច្រើនជាងលើកិច្ចការពារ និងសេវាកម្មគាំទ្រដល់ជនទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ។ UNIAP ផ្ដោតចំលើការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ។ អង្គការអន្តរជាតិភាគច្រើនដែលធ្វើការលើ

5 អូស្ត្រាលី បង់ក្លាដែស ប្រ៊ុយណេ កម្ពុជា ចិន ឥណ្ឌូនេស៊ី ជប៉ុន សាធារណៈរដ្ឋកូរ៉េ ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ញូហ្សីលែន ប៉ាពួញូហ្គីណេ ហ្វីលីពីន សិង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។

ផ្នែកទេសន្តរប្រវេសន៍ បានធ្វើជាដៃគូជាមួយ MLVT តាមរយៈការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីកំណត់គោលនយោបាយ ធ្វើកំណែទម្រង់បទបញ្ញត្តិច្បាប់ និងកសាងសមត្ថភាព។ ILO បានជួយ MLVT រៀបចំស្រេចបាច់នូវគោលនយោបាយអំពីទេសន្តរប្រវេសន៍ពលកម្ម និងកសាងសមត្ថភាព ដើម្បីគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មឲ្យបានរៀបរយ។ IOM បានធ្វើការជាមួយក្រសួង ដើម្បីកែសម្រួលអនុក្រឹត្យលេខ៥៧ ប្រមូលព័ត៌មាន និងធ្វើការអប់រំអំពីការផ្លាស់ទីដោយមានសុវត្ថិភាព។ NGOs ក្នុងស្រុកបានធ្វើការដោយផ្ទាល់ និងជិតស្និទ្ធជាងជាមួយជនទេសន្តរប្រវេសន៍ និងសហគមន៍របស់ពួកគេ លើការតស៊ូមតិ ការបំផុសចំណាប់អារម្មណ៍ ការគាំទ្រនិងការថែទាំជនទេសន្តរប្រវេសន៍ ព្រមទាំងការធ្វើសហប្រតិបត្តិការ និងការកសាងបណ្តាញ ប៉ុន្តែមិនសូវផ្តោតលើគោលនយោបាយ និងច្បាប់ទេ។

ការទទួលខុសត្រូវដោយចំហ និងដោយបង្កប់ របស់ក្រុមហ៊ុនផ្តល់ការងារជាឯកជនគឺ ជ្រើសរើស និងផ្តល់ការងារនៅបរទេសដល់ពលករកម្ពុជា បណ្តុះបណ្តាលមុនពេលចេញដំណើរ ពិនិត្យតាមដានកន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់ពលករ ធានាឲ្យពលករចៀសផុតពីការជួញដូរ ឬកេងប្រវ័ញ្ចផ្លូវភេទ ចរចានិងដោះស្រាយវិវាទការងារ និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករនៅពេលចប់កិច្ចសន្យា។ មកដល់ឆ្នាំ២០១០ មាន ២៨ក្រុមហ៊ុនជ្រើសរើសពលករឯកជនចំនួន២ ដែលមានអាជ្ញាប័ណ្ណដើម្បីជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករកម្ពុជាទៅបរទេស (សូមមើលបញ្ជីពេញលេញក្នុងឧបសម្ព័ន្ធ)។ ក្រុមហ៊ុនជាច្រើនបានរួមគ្នាបង្កើត សមាគមជ្រើសរើសពលករកម្ពុជា[6] ដែលធ្វើសកម្មភាពចម្បងក្នុងការប្រមូលនិងផ្សព្វផ្សាយព័ត៌មាន សម្របសម្រួលនិងរៀបចំវគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរ ពិគ្រោះយោបល់លើគោលនយោបាយជាតិ និងធ្វើសហប្រតិបត្តិការជាមួយ MLVT ដើម្បីតាក់តែងកិច្ចសន្យាស្តង់ដារ។

ដូចស្ថាប័នសាធារណៈជាច្រើនទៀតដែរ MLVT នៅខ្វះខាតធនធាន។ ក្រសួងនេះទទួលបានថវិកាប្រចាំឆ្នាំប្រមាណ ៧លានដុល្លារអាមេរិកពីរដ្ឋាភិបាល និងខ្វះខាតបុគ្គលិកធ្វើការនៅលើទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងទេសន្តរប្រវេសន៍ Chan (2009) ។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ឬមួយមិនទាន់មាន ឬមួយនៅតូចតាច ។ សព្វថ្ងៃមិនទាន់មានមណ្ឌលធនធានផ្នែកទេសន្តរប្រវេសន៍នៅក្រុងភ្នំពេញ ឬនៅតាមខេត្ត ដើម្បីផ្តល់ព័ត៌មាន និងចុះបញ្ជីពលករទេសន្តរប្រវេសន៍នៅឡើយទេ។ ការអប់រំ និងបណ្តុះបណ្តាលមុនពេលធ្វើទេសន្តរប្រវេសន៍ក៏មិនទាន់រៀបចំឲ្យមានក្រឹត្យក្រមច្បាស់លាស់នៅឡើយ ដែលធ្វើឱ្យយុទ្ធនាការអប់រំពីទេសន្តរប្រវេសន៍ហុចលទ្ធផលមិនស្មើគ្នា។ ជនទេសន្តរប្រវេសន៍បានទទួលព័ត៌មានតិចតួចណាស់ពីសិទ្ធិរបស់ខ្លួន ព្រមទាំងភារកិច្ច និងកាតព្វកិច្ចរបស់និយោជក និងទីភ្នាក់ងារផ្តល់ការងារ កន្លែងធ្វើការនិងលក្ខខណ្ឌរស់នៅ សុខភាពនិងសុវត្ថិភាព ទីតាំងនិងលេខទូរស័ព្ទរបស់ស្ថានទូតកម្ពុជា ឬក៏ ទីកន្លែងនិងវិធីត្រូវស្វែងរកជំនួយ (Lee 2007a) ។

ធនធានមិនគ្រប់គ្រាន់នាំឱ្យការជ្រើសរើស និងផ្តល់ការងារ គ្មានការតាមដានត្រួតពិនិត្យត្រឹមត្រូវ។ ដូច្នេះត្រូវមានជាបន្ទាន់នូវ យន្តការពិនិត្យតាមដានមួយដែលមានដំណើរការជាក់ស្តែង។ ក្រុមហ៊ុនឯកជនតែងគិតគូរពីផលចំណេញ ហើយការត្រួតពិនិត្យទន់ខ្សោយ ផ្តល់ឱកាសឱ្យពួកគេមិនអើពើពីបទបញ្ញត្តិច្បាប់ និងស្តង់ដារផ្សេងៗ។ មានករណីជាច្រើននៃក្រុមហ៊ុនជ្រើសរើសពលករឯកជនដែលយកថ្លៃខ្ពស់ហួសហេតុពីពលករ ដកហូតលិខិតឆ្លងដែនពីពលករ មិនផ្តល់កិច្ចសន្យាការងារតាមស្តង់ដារ និងធ្វេសប្រហែសអំពីសុខុមាលភាព និងកិច្ចការពារកម្មករ (Lee 2007a)។

ការសម្របសម្រួល និងចែករំលែកព័ត៌មានក្នុងចំណោមស្ថាប័នពាក់ព័ន្ធនៅទន់ខ្សោយនៅឡើយ ហើយជាអនុសាសន៍ គួរផ្តល់អាទិភាពដល់ការពង្រឹងក្រុមការងារចម្រុះទទួលបន្ទុកទេសន្តរប្រវេសន៍ជាស្ថាប័នពិគ្រោះយោបល់មួយ ដើម្បីធានាឱ្យមានការសម្របសម្រួលរលូនល្អរវាងក្រសួងនានា។ បច្ចុប្បន្នពុំទាន់មានវិធីងាយស្រួលសម្រាប់ឲ្យពលករទេសន្តរប្រវេសន៍ ដាក់ពាក្យប្តឹងពីការរំលោភបំពាន ឬទទួលបានការគាំទ្រក្នុងករណីមានការរំលោភសិទ្ធិការងារនោះទេ។ កង្វះខាតនេះធ្វើឱ្យជនទេសន្តរប្រវេសន៍ងាយរងគ្រោះដោយសារក្រុមហ៊ុនជ្រើសរើស និងនិយោជក។ សព្វថ្ងៃកម្ពុជាមិនទាន់មានប្រព័ន្ធមួយ សម្រាប់គ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មឲ្យបានសក្តិសិទ្ធិទេ។

---

6 នៅគេហទំព័រ៖ http://www.acramanpower.org/

# ៦ វិធីសាស្ត្រកសាងក្របខ័ណ្ឌច្បាប់គ្រប់គ្រងទេសន្តរប្រវេសន៍មិនស្របច្បាប់

ការវិភាគបានបង្ហាញថា ថ្វីបើជនទេសន្តរប្រវេសន៍ខ្លះបានកែលម្អជីវភាពរស់នៅ ប៉ុន្តែក៏មានច្រើននាក់ដែលមិនបានកែលម្អ ឬកាន់តែយ៉ាប់យ៉ឺនថែមទៀត។ ជនទាំងនោះប្រឈមនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ច ហើយទទួលបានកិច្ចការពារតាមផ្លូវច្បាប់ និងខាងសង្គមកិច្ចតិចតួចបំផុត ឬគ្មានសោះ។ បញ្ហាទេសន្តរប្រវេសន៍ចោទឡើងពាសពេញបានបង្កើតជាបញ្ហាប្រឈមផ្នែកការពារដ៏ធំមួយសម្រាប់ប្រទេសប្រភពដើម។ សព្វថ្ងៃមានគម្លាតយ៉ាងធ្ងន់ធ្ងររវាងគោលនយោបាយ និងការអនុវត្ត ដើម្បីទប់ស្កាត់ទេសន្តរប្រវេសន៍មិនស្របច្បាប់ និងការពារសិទ្ធិជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ ក៏បានប៉ះពាល់ដល់អភិបាលកិច្ចលើទេសន្តរប្រវេសន៍ពលកម្ម ទាំងនៅក្នុងប្រទេសទទួល និងប្រទេសបញ្ជូន។ ក្នុងនេះមានការឯកភាពគ្នាជាអន្តរជាតិថា ត្រូវដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ក្នុងទម្រង់ធំទូលាយ និងគ្រប់ជ្រុងជ្រោយ ដោយពិនិត្យពីមូលហេតុ និងដោះស្រាយផលប៉ះពាល់របស់វាព្រមទាំងកែលម្អកិច្ចសហប្រតិបត្តិការអន្តរជាតិ។

## ៦.១ ការដោះស្រាយមូលហេតុនៃទេសន្តរប្រវេសន៍មិនស្របច្បាប់

ភាពក្រីក្របំផុត និងកង្វះឱកាសការងារ បន្ទុកចំណាយខ្ពស់នៅក្នុងទេសន្តរប្រវេសន៍ស្របច្បាប់ បទបញ្ញត្តិច្បាប់តឹងរ៉ឹងនៅប្រទេសទីដៅ ព្រំដែនបិទមិនជិត ការប្រព្រឹត្តិខុសឆ្គងដោយក្រុមហ៊ុនផ្តល់ការងារឯកជនខ្លះ និងសកម្មភាពរបស់ជនល្មើសជួញដូរ បានជំរុញពលករកម្ពុជា ឱ្យធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ដែលត្រូវថយចុះវិញ បើសិនមានអន្តរាគមន៍ដោះស្រាយកត្តាជំរុញទាំងនេះ។

- **ការពង្រឹងការអភិវឌ្ឍនៅសហគមន៍ប្រភពដើម៖** ការវិភាគនៅខាងលើបង្ហាញថា គ្រួសារបានជ្រើសរើសការធ្វើទេសន្តរប្រវេសន៍ ដើម្បីរំដោះខ្លួនពីភាពក្រីក្របំផុត ការធ្វើកសិកម្មមិនបានផល និងការខ្សត់ធនធានធម្មជាតិ។ យើងឯកភាពតាមសេចក្តីថ្លែងការណ៍ នៅក្រុងបាងកកដែលថា ទេសន្តរប្រវេសន៍មិនស្របច្បាប់មានមូលហេតុពាក់ព័ន្ធជិតស្និទ្ធនឹងការអភិវឌ្ឍ ហើយត្រូវប្រឹងប្រែងសម្រេចការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពឲ្យបាន។ ថ្វីបើមិនទាន់មានភស្តុតាងរឹងមាំអំពីទំនាក់ទំនង រវាងការអភិវឌ្ឍសហគមន៍ និងទេសន្តរប្រវេសន៍ក្តីក៏ការអភិវឌ្ឍអាចកាត់បន្ថយទេសន្តរប្រវេសន៍ដោយជួយជំនះលើមូលហេតុរបស់ជនទេសន្តរប្រវេសន៍ក្នុងការធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ និងធ្វើឱ្យទេសន្តរប្រវេសន៍ក្លាយជាជម្រើសដោយសេរី ជាវិជ្ជមាន និងស្របច្បាប់។

  សហគមន៍នៅជនបទកម្ពុជាភាគច្រើន មានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងប្រព័ន្ធធារាសាស្ត្រអន់ខ្សោយ ខ្វះខាតសេវាកម្មទ្រទ្រង់កសិកម្ម និងមានលទ្ធភាពតិចក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ ដូច្នេះត្រូវមានយុទ្ធសាស្ត្រដើម្បីជំនះលើកំហិតផ្នែកសេដ្ឋកិច្ចរបស់សហគមន៍ និងបង្កើនកាលានុវត្តភាព ជាពិសេសសម្រាប់ប្រជាជនក្រីក្របំផុត។ វិធានការចំបងដែលអាចធ្វើបាន រួមមាន ការផ្តល់ជំនួយកសិកម្ម ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ការបង្កើនលទ្ធភាពបានប្រើប្រាស់ធនធានធម្មជាតិ និងការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រង ការពង្រឹងការផ្តល់សេវាកម្មសាធារណៈ ជាពិសេសការអប់រំ និងសុខាភិបាល ការបណ្តុះបណ្តាលជំនាញសហគមន៍ និងសេវាកម្មមីក្រូហិរញ្ញវត្ថុ។ ជំនួយអភិវឌ្ឍន៍ ត្រូវផ្តោតលើសហគមន៍នានា ដែលមានអត្រាធ្វើទេសន្តរប្រវេសន៍កម្រិតខ្ពស់ ។

- **បើកឱកាសដល់ទេសន្តរប្រវេសន៍ស្របច្បាប់៖** ទេសន្តរប្រវេសន៍ទៅធ្វើការនៅបរទេស តាមរយៈបណ្តាញស្របច្បាប់មានភាពស្មុគស្មាញ ចំណាយពេលវែង និងមានតម្លៃខ្ពស់។ ដោយមានជម្រើសតិចតួចដើម្បីធ្វើទេសន្តរ

ប្រវេសន៍ផ្លូវការ ទេសន្តរប្រវេសន៍មិនស្របច្បាប់ ក៏ក្លាយជាច្រកតែមួយគត់ដែលពលករទេសន្តរប្រវេសន៍កម្ពុជាភាគច្រើន អាចរ៉ាប់រងចំណាយបាន។ ដូចបានបង្ហាញក្នុងកិច្ចប្រជុំត្រីភាគីតំបន់អាស៊ីរបស់ ILO នៅក្រុងបាងកក នៅឆ្នាំ២០០៣ មានការឯកភាពជាអន្តរជាតិថា ឱកាសធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ដោយមានតម្លាភាព និងងាយស្រួល អាចជាដំណោះស្រាយដ៏សក្តិសិទ្ធិមួយ ចំពោះទេសន្តរប្រវេសន៍មិនស្របច្បាប់។ ថ្វីបើកម្ពុជាអាចចរចាធ្វើកិច្ចព្រមព្រៀងទ្វេភាគី ជាមួយប្រទេសទទួលពលកម្មដើម្បីបានកូតាកាន់តែច្រើន និងសហប្រតិបត្តិការកាន់តែល្អក្តី ប៉ុន្តែអាទិភាពដ៏សំខាន់សម្រាប់ការជ្រើសរើសជាផ្លូវការរបស់កម្ពុជា គឺត្រូវតម្រឹមនីតិវិធីរដ្ឋបាល ពន្លឿនសេវាជួយសម្រួល និងកាត់បន្ថយចំណាយ។

ដំណើរការជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅថៃ ត្រូវចំណាយពេលវែង។ តាមការសម្ភាសជាមួយក្រុមជ្រើសរើសពលករ ការចេញលិខិតឆ្លងដែន ចេញទិដ្ឋាការ និងឯកសារឯទៀតដោយអាជ្ញាធរមានសមត្ថកិច្ច ស៊ីពេលៈអស់ប្រហែលពាក់កណ្តាលទៅហើយ[7]។ ការយឺតយូរនេះ ឆ្លុះបញ្ចាំងពីកង្វះការជួយជ្រោមជ្រែង និងសេវាកម្មគាំទ្រទេសន្តរប្រវេសន៍។ ទម្រង់បែបបទនេះមិនងាយបំបាត់បានទេ ប៉ុន្តែគេអាចកាត់បន្ថយបានច្រើននូវការយឺតយ៉ាវ គ្មានហេតុផលនានា។ ឧទាហរណ៍ នាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន គួរអនុវត្តយ៉ាងម៉ត់ចត់តាមអនុក្រឹត្យលេខ១៩៥ ស្តីពីលិខិតឆ្លងដែនសម្រាប់ពលករទេសន្តរប្រវេសន៍ ដោយចេញលិខិតឆ្លងដែនក្នុងរយៈពេល ២០ថ្ងៃ។ ក្រសួងមហាផ្ទៃ ក៏គួរពិចារណាលើការបង្កើតការិយាល័យលិខិតឆ្លងដែនក្នុងបណ្តាខេត្តមានទេសន្តរប្រវេសន៍ច្រើន ដូចជា បាត់ដំបង បន្ទាយមានជ័យ និងព្រៃវែង។ ការិយាល័យតាមខេត្តទាំងនេះ គួរចាត់ចែងលិខិតឆ្លងដែន សម្រាប់តែពលករទេសន្តរប្រវេសន៍ជាសក្តានុពលប៉ុណ្ណោះ ហើយប្រការនេះអាចកាត់បន្ថយរយៈពេល និងបន្ទុកចំណាយលើការចេញលិខិតឆ្លងដែនបាន។ រយៈពេលចេញទិដ្ឋាការធ្វើការ គួរកាត់បន្ថយ ៥០% ។

ដូចលោក Chan (2009) ដែលបានផ្តល់មតិឱ្យកាត់បន្ថយបន្ទុកចំណាយលើការជ្រើសរើសពី ៧០០ដុល្លារអាមេរិក មកត្រឹម ៣០០ដុល្លារអាមេរិកនោះដែរ ការសិក្សានេះជំរុញដល់ស្ថាប័នបន្ទុក ជាពិសេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យពិនិត្យពីចំណាយជាក់ស្តែង ហើយប្រឹងប្រែងកាត់បន្ថយវាថែមទៀត។ ការបំបែកបន្ទុកចំណាយនៃការបញ្ជូនពលករទៅថៃ បង្ហាញថា ចំណាយដ៏ច្រើន (ប្រហែល ២២០ដុល្លារអាមេរិក ឬ ៣១% នៃចំណាយសរុប)។ ស្ថិតក្នុងខ្ទង់ "ចំណាយផ្សេងៗ" ដែលគេមិនអាចដឹងបាន។ រឿងធ្វើឲ្យក្រុមហ៊ុន ឬមន្ត្រីឱកាសនិយម កាន់តែងាយស្រួលទាមទារប្រាក់កម្រៃខ្ពស់។ ដូច្នេះគួរតែផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីដំណើរការជ្រើសរើស ប្រាក់កម្រៃ ក៏ដូចជាមុខចំណាយដែលច្បាប់បានអនុញ្ញាត និងគួរដាក់កម្រិតលើប្រាក់កម្រៃដែលក្រុមហ៊ុនទាមទារបាន។

- **ការធ្វើច្បាប់គ្រប់គ្រងក្រុមហ៊ុនជ្រើសរើសឯកជន៖** ការមិនប្រតិបត្តិតាម និងការប្រព្រឹត្តិខុសឆ្គងធ្ងន់ធ្ងរដដែលៗ បានបង្ហាញពីតម្រូវការធ្វើច្បាប់រឹងប៉ឹងដើម្បីគ្រប់គ្រងជាបន្ទាន់លើក្រុមហ៊ុនជ្រើសរើស។ នាបច្ចុប្បន្ន អនុក្រឹត្យលេខ៥៧ គឺជាលិខិតុបករណ៍ចំបងគេ ប៉ុន្តែនៅខ្វះការគ្របដណ្តប់ទូលំទូលាយ និងភាពច្បាស់លាស់ ជាពិសេសចំពោះប្រាក់កម្រៃ ការបណ្តុះបណ្តាល និងការពិនិត្យតាមដានកន្លែងធ្វើការ ការត្រួតពិនិត្យ ការប្រតិបត្តិតាម និងការដាក់ទណ្ឌកម្ម។ ច្បាប់គ្រប់គ្រងការជ្រើសរើស និងការផ្តល់ការងារ ត្រូវធ្វើតាមរយៈប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ដែលក្នុងនោះ ការទទួលខុសត្រូវរបស់ក្រុមហ៊ុន លក្ខខណ្ឌជ្រើសរើស និងការដាក់ទណ្ឌកម្មលើការរំលោភបំពាន និងការធានាគុណភាពអនុវត្តន៍ ត្រូវតែកំណត់ឱ្យច្បាស់។ បទបញ្ញត្តិច្បាប់គួរមានចែងពីការលុបចោលអាជ្ញាប័ណ្ណក្នុងករណីមានការប្រព្រឹត្តិខុស និងនីតិវិធីព្រហ្មទណ្ឌក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ។ ច្បាប់ល្អគ្មានន័យអ្វីទេ ប្រសិនបើគ្មានការពង្រឹងអនុវត្ត។ ក្នុងពេលជាមួយគ្នា ត្រូវមានការពិនិត្យតាមដានយ៉ាងសកម្ម ដើម្បីធានាឱ្យមាន

7 ការចេញលិខិតឆ្លងដែនចំណាយពេលពី ២០ថ្ងៃ ដល់ ១ខែ ការចេញទិដ្ឋាការការងារចំណាយពេលប្រហែល ១ខែ ហើយឯកសារផ្សេងៗពីក្រសួងការបរទេសអស់ ប្រហែល ២សប្តាហ៍។

ការប្រតិបត្តិតាមជាអតិបរមា។ ការពិនិត្យតាមដានគួររួមបញ្ចូលនូវ៖

- ការទទួលបានរបាយការណ៍ពីក្រុមហ៊ុន អំពីការផ្តល់ការងារ និងស្ថានភាពការងាររបស់ពលករដែលបានបញ្ជូន។
- ទស្សនកិច្ច ឬអធិការកិច្ចជាទៀងទាត់ដោយស្ថាប័នរដ្ឋ ឬអ្នកតំណាង។
- ព័ត៌មានបញ្ជាក់ពីក្រុមហ៊ុនជ្រើសរើស ឬនិយោជកបរទេសដែលជាប់ឈ្មោះក្នុងបញ្ជីខ្មៅ ពីការរំលោភបំពានច្បាប់។
- ពិនិត្យឡើងវិញយ៉ាងច្បាស់លាស់លើកិច្ចសន្យាការងាររបស់ពលករទេសន្តរប្រវេសន៍ មុនពេលចុះហត្ថលេខា និងការពង្រឹងអនុវត្តក្នុងអំឡុងពេលបម្រើការងាររបស់ពួកគេ។

• **ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស៖** របាយការណ៍មួយរបស់ UNIAP ស្តីពីការជួញដូរមនុស្សនៅកម្ពុជា បានបញ្ជាក់ថា មានបុរស ស្ត្រី និងកុមារ ត្រូវបានគេជួញដូរ ដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ នៅប្រទេសថៃ ម៉ាឡេស៊ី ម៉ាកាវ និង តៃវ៉ាន់។ ការទប់ស្កាត់ការជួញដូរ អាចកាត់បន្ថយការងារកុមារ និងពលកម្មដោយបង្ខំ។ វាក៏អាចជួយកាត់បន្ថយទេសន្តរប្រវេសន៍មិនស្របច្បាប់ និងការពារជនទេសន្តរប្រវេសន៍ឱ្យរួចផុតពីទាសភាព និងការកេងប្រវ័ញ្ចធ្ងន់ធ្ងរ។ ការស្រាវជ្រាវនេះមិនព្យាយាមកំណត់ពីគោលនយោបាយប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនោះទេ ប៉ុន្តែវិធានការដូចខាងក្រោមអាចជួយទប់ស្កាត់បានខ្លះ៖

- ពង្រឹងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ដើម្បីដោះស្រាយការជួញដូរ។
- ចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមថ្នាក់តំបន់ (ឧទាហរណ៍ គំនិតផ្តួចផ្តើមឲ្យមានការសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីនៅតំបន់មេគង្គ ប្រឆាំងនឹងការជួញដូរ) និងធ្វើការងារកាន់តែជិតស្និទ្ធជាមួយប្រទេសទីដៅធំៗ ដូចជាថៃ និងម៉ាឡេស៊ី។
- សហការច្រើនថែមទៀតនៅក្នុងប្រទេសកម្ពុជា ជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងនិយោជក។
- ពង្រឹងការអនុវត្តនច្បាប់ និងពង្រឹងសមត្ថភាពមន្ត្រីនានា។
- កសាងមូលដ្ឋានចំណេះដឹង តាមរយៈទិន្នន័យល្អៗ ព័ត៌មានត្រឹមត្រូវ និងការស្រាវជ្រាវពីការជួញដូរមនុស្ស។
- បង្កើនការតស៊ូមតិ និងលើកកម្ពស់ការយល់ដឹង។

## ៦.២ កិច្ចការពារ និងសុខុមាលភាពរបស់ពលករទេសន្តរប្រវេសន៍

• **បង្កើនការអប់រំ និងលើកកម្ពស់ចំណាប់អារម្មណ៍៖** ជនទេសន្តរប្រវេសន៍ភាគច្រើន ជាពិសេសក្នុងស្ថានភាពមិនស្របច្បាប់ មិនបានដឹងពីផលប៉ះពាល់ផ្នែកច្បាប់ សង្គមកិច្ច និងសេដ្ឋកិច្ចនៃការផ្លាស់ទីទៅប្រទេសមួយទៀតឡើយ។ ពួកគេមិនបានទទួលព័ត៌មានច្បាស់លាស់ពី ការងារ ការរស់នៅ ទំនៀមទម្លាប់ ប្រពៃណី ពលកម្ម សិទ្ធិមនុស្ស និងច្បាប់ នៅឯប្រទេសទីដៅនោះទេ។ ព័ត៌មានកាន់តែល្អ មានន័យថា មានកិច្ចការពារកាន់តែប្រសើរ ហេតុនេះជាអនុសាសន៍ គួរបង្កើនការអប់រំ និងចំណាប់អារម្មណ៍មុនពេលចេញដំណើរ។ ការរៀបចំគ្រប់គ្រាន់សម្រាប់លក្ខខណ្ឌការងារនៅឯបរទេស និងព័ត៌មានអំពីសិទ្ធិរបស់ខ្លួន ជួយឱ្យពលករទេសន្តរប្រវេសន៍មានបទពិសោធន៍កាន់តែល្អ។ ព័ត៌មានអាចផ្សព្វផ្សាយចេញតាមរយៈវិធានការចម្រុះដូចតទៅ៖

- មណ្ឌលធនធានទេសន្តរប្រវេសន៍ថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីចុះបញ្ជី ពលករទេសន្តរប្រវេសន៍ជាសក្តានុពល និងផ្តល់ព័ត៌មាន។ មណ្ឌលនេះធ្វើជាកន្លែងកណ្តាលសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងសម្រាប់ឲ្យ

ជនទេសន្តរប្រវេសន៍ទូរស័ព្ទទាក់ទង ឬមកទទួលការប្រឹក្សាយោបល់។ ព័ត៌មានអាចផ្សព្វផ្សាយតាមរយៈកូនសៀវភៅ ផ្ទាំងរូបភាពធំៗ ការប្រឹក្សាយោបល់ ទស្សនកិច្ច ប្រព័ន្ធផ្សព្វផ្សាយ កិច្ចប្រជុំ និងសិក្ខាសាលា។ ឧទាហរណ៍ល្អៗនៃការអប់រំមុនពេលចេញដំណើរ រួមមាន មណ្ឌលធនធានព័ត៌មានរបស់ Tajikistan សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលផ្តល់ព័ត៌មានអំពី លក្ខខណ្ឌការងារ ការធ្វើដំណើរ និងតម្រូវការឯកសារ ការចុះបញ្ជី សិទ្ធិ ផែនទី កន្លែងសម្រាប់ទាក់ទង ហានិភ័យនៃការជួញដូរ និងការរត់ពន្ធ និងគ្រោះថ្នាក់ផ្នែកសុខភាព។

- ត្រូវពង្រឹងយុទ្ធនាការអប់រំផ្តោតចំលើសហគមន៍ដែលមានអត្រាទេសន្តរប្រវេសន៍មិនស្របច្បាប់ខ្ពស់។ ការអប់រំ គួរផ្តោតច្រើនលើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងគ្រោះថ្នាក់នៃទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាពិសេស ការជួញដូរដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ។ ដោយការិយាល័យពលកម្មថ្នាក់ខេត្ត និងស្រុកមានធនធានមិនគ្រប់គ្រាន់ ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍ មេភូមិ មេឃុំ ព្រះសង្ឃ និងគ្រូបង្រៀន អាចដើរតួនាទីសំខាន់ជួយផ្តល់ព័ត៌មានដល់ជនទេសន្តរប្រវេសន៍។ MLVT គួរធ្វើការជាមួយអង្គការអន្តរជាតិ ដើម្បីប្រមូលការគាំទ្រសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការអប់រំ និងព័ត៌មាននៅតាមសហគមន៍ស្តីពីទេសន្តរប្រវេសន៍។

- **ការពង្រីកសេវាកម្មគាំទ្រ៖** កន្លងមកការផ្តល់ការគាំទ្រដើម្បីការពារ និងផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសន៍ ជាពិសេសជនទេសន្តរប្រវេសន៍មិនស្របច្បាប់ នៅមានតិចតួច។ ការចាត់តាំងអនុព័ន្ធការងារ នៅតាមប្រទេសដែលមានពលករទេសន្តរប្រវេសន៍កម្ពុជាច្រើនៗអាចជាវិធីមួយ ដើម្បីពង្រឹងសេវាកម្មគាំទ្រ។ មុខងាររបស់ពួកគេ គួរមានទាំងការបង្កើតទំនាក់ទំនងការងាររឹងមាំជាមួយប្រទេសម្ចាស់ផ្ទះ ស្តីពីបញ្ហាការងារ ការពិនិត្យតាមដានការចាត់ចែងលើពលករទេសន្តរប្រវេសន៍ ការផ្តល់ជំនួយផ្លូវច្បាប់ប្រឆាំងការរំលោភកិច្ចសន្យា ការបំពាន ឬការកេងប្រវ័ញ្ច ការជួយមតិលើបញ្ហាកិច្ចសន្យាឬការងារ និងធានាឲ្យជនទេសន្តរប្រវេសន៍មិនស្របច្បាប់ ទទួលបានកិច្ចការពារ និងការជួយសម្រួលនៅពេលធ្វើមាតុភូមិនិវត្តន៍។ គួរមានអនុព័ន្ធការងារនៅក្នុងប្រទេសថៃ និងម៉ាឡេស៊ី ដែលមានពលករទេសន្តរប្រវេសន៍កម្ពុជាភាគច្រើនកំពុងធ្វើការ ជាពិសេសពលករទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ អនុព័ន្ធការងារ គួរមានចំណេះដឹង និងជំនាញមូលដ្ឋាន ដូចជា ការយល់ដឹងអំពីលិខិតុបករណ៍ផ្លូវច្បាប់អន្តរជាតិ សន្ធិសញ្ញានិងកិច្ចព្រមព្រៀង ចំណេះដឹងអំពីតម្រូវការនិងការផ្គត់ផ្គង់ពលកម្មនៅប្រទេសម្ចាស់ផ្ទះ និងចំណេះដឹងអំពីច្បាប់ និងគោលនយោបាយពលកម្មនៃប្រទេសទាំងពីរ។

## ៦.៣ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ទេសន្តរប្រវេសន៍ជាបញ្ហាពហុភាគី ដូច្នេះត្រូវមានកិច្ចសន្ទនានិងសហប្រតិបត្តិការអន្តរជាតិដើម្បីញ៉ាំងឱ្យទេសន្តរប្រវេសន៍ពលកម្មមានច្បាប់ និងសណ្តាប់ធ្នាប់ល្អ ( ILO 2010 )។ សេចក្តីប្រកាសក្រុងបាងកក ក៏បានទទួលស្គាល់ទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាបញ្ហាតំបន់ដែរ ហើយដើម្បីដោះស្រាយបញ្ហានេះ ត្រូវមានកិច្ចប្រឹងប្រែងរួមគ្នាដោយផ្អែកលើសមភាព ការយល់ដឹង និងគោរពគ្នាទៅវិញទៅមក។ ទេសន្តរប្រវេសន៍មិនស្របច្បាប់ អាចដោះស្រាយបានល្អបំផុតក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ដោយបំពេញបន្ថែមលើគោលនយោបាយជាតិ។

- **ការពង្រឹងសហប្រតិបត្តិការទ្វេភាគី៖** សហប្រតិបត្តិការរវាងប្រទេសបញ្ជូន និងប្រទេសទទួល មានប្រសិទ្ធភាពល្អក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់។ MoU ដែលចុះហត្ថលេខាដោយកម្ពុជា និងថៃ នៅឆ្នាំ២០០៣ ឧទាហរណ៍ដ៏ល្អមួយនៃសហប្រតិបត្តិការដ៏សក្តិសិទ្ធិ ដើម្បីដោះស្រាយបញ្ហាទេសន្តរប្រវេសន៍។ គោលដៅចំបងគឺ ក្របខ័ណ្ឌផ្លូវការមួយ ដើម្បីជ្រើសរើសជនកម្ពុជា ឱ្យទៅធ្វើការនៅថៃ ប៉ុន្តែ MoU នេះក៏ប្រឹងប្រែងកែសម្រួលពលករកម្ពុជាដែលគ្មានឯកសារត្រឹមត្រូវ ឱ្យក្លាយជាជនទេសន្តរប្រវេសន៍ស្របច្បាប់

ផងដែរ។ រដ្ឋាភិបាលទាំងពីរបានរួមគ្នាធ្វើការងារនេះ ដោយផ្តល់វិញ្ញាបនប័ត្រសម្គាល់ខ្លួនដល់ពលករគ្មានឯកសារដើម្បីដាក់ពាក្យសុំប័ណ្ណធ្វើការរយៈពេលពីរឆ្នាំ។ រហូតដល់ឆ្នាំ២០០៧ មានពលករកម្ពុជាគ្មានឯកសារ ៤៨.៣៦២នាក់ ត្រូវបានកំណត់ជាក្រុមគោលដៅសម្រាប់ធ្វើឱ្យស្របច្បាប់ ក្នុងនោះមាន ២៤.៧៨៣នាក់ បានទទួលការពន្យាពេលប័ណ្ណធ្វើការ ១០.០៩៤នាក់ បានទទួលការចេញលិខិតបញ្ជាក់ថ្នាក់ជាតិ និង ១២.៤៦១នាក់ មិនបានមកបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យទេ[8]។ ប្រទេសថៃ កំពុងប្រឈមមុខនឹងកង្វះខាតពលករមានជំនាញទាប ដូច្នេះរដ្ឋាភិបាលថៃ គួរបន្តកិច្ចសហការជាមួយប្រទេសបញ្ជូនលើការធ្វើឱ្យស្របច្បាប់។ ឆ្លងតាមបទពិសោធន៍ដ៏ជោគជ័យនេះ កម្ពុជាគួរស្នើម៉ាឡេស៊ីឱ្យពិចារណាលើការធ្វើឱ្យស្របច្បាប់នូវពលករកម្ពុជាមិនស្របច្បាប់ ។

ភាពជាដៃគូមានជោគជ័យមួយទៀតក្នុងការដោះស្រាយទេសន្តរប្រវេសន៍មិនស្របច្បាប់ គឺកិច្ចព្រមព្រៀងរវាងកម្ពុជា និងថៃ លើការចេញបញ្ជាប័ណ្ណឆ្លងព្រំដែនប្រចាំថ្ងៃឲ្យពលករតាមរដូវ និងអ្នកធ្វើដំណើរចុះឡើង ដែលរស់នៅក្នុងខេត្តតាមព្រំដែន។ តាមរយៈប័ណ្ណនេះ ជនជាតិកម្ពុជា ដែលភាគច្រើនជាពលករតាមកសិដ្ឋាន អ្នកបម្រើតាមផ្ទះ និងអាជីវករតូចតាច អាចទៅធ្វើការនៅប្រទេសថៃ ដោយមិនសូវមានកង្វល់ពីការចាប់ខ្លួន។ អង្កេតបង្ហាញថា ជនទេសន្តរប្រវេសន៍មិនស្របច្បាប់ បម្រើការជាពលករតាមកសិដ្ឋាននៅក្បែរព្រំដែន មិនសូវងាយរងគ្រោះដោយសារការរំលោភបំពាន និងការកេងប្រវ័ញ្ច ដូចពលករធ្វើការក្នុងផ្នែកនេសាទ សំណង់ ឬ រោងចក្រទេ។ វិធីនេះបានជួយដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ ដូច្នេះប្រទេសនានាគួរបន្តកិច្ចសហការដើម្បីជួយសម្រួលចលនាឆ្លងព្រំដែននៅតាមបណ្តាខេត្តជាប់ព្រំដែន។

- **ដើម្បីបង្កើតទីផ្សារពលកម្មចម្រុះនៅមហាអនុតំបន់មេគង្គ៖** ចលនាពលកម្មឆ្លងកាត់ព្រំដែននៅក្នុង GMS មានសន្ទុះខ្លាំងដោយសារភាពខុសគ្នាខាងសេដ្ឋកិច្ច និងសង្គមកិច្ច និងភាពបំពេញឲ្យគ្នានៃរចនាសម្ព័ន្ធទីផ្សារពលកម្ម។ ថៃជាប្រទេសទីដៅនៃទីផ្សារពលកម្ម ចំណែកឯកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា ជាប្រភពនៃការផ្គត់ផ្គង់ពលកម្មគ្មានជំនាញ។ ថ្វីបើលំហូរពលកម្មក្នុងតំបន់មានទំហំធំ និងមានសារៈសំខាន់ខាងសេដ្ឋកិច្ចក្តី ក៏សព្វថ្ងៃមិនទាន់មានក្របខ័ណ្ឌច្បាប់ ឬស្ថាប័នកម្រិតអនុតំបន់ សម្រាប់ជួយសម្រួលលំហូរនេះទេ។ បន្ថែមលើចំណុចខ្សោយនេះ បញ្ហាទេសន្តរប្រវេសន៍ពលកម្ម ក៏មិនទាន់បានដាក់បញ្ចូលក្នុងកម្មវិធីសហប្រតិបត្តិការ GMS ដែរ។ គេព្យាករណ៍ថាទេសន្តរប្រវេសន៍ពលកម្មឆ្លងព្រំដែននៅ GMS នឹងបន្តកើនឡើងទាំងទំហំ និងវិសាលភាព ហេតុនេះគួរមានទីផ្សារពលកម្មចម្រុះមួយ។

  សំណើខាងលើអាចផ្តល់ផលប្រយោជន៍ដល់គ្រប់ប្រទេសចូលរួម។ សម្រាប់ប្រទេសខ្វះខាតពលកម្មដូចជាថៃ ការទទួលបានទីផ្សារពលកម្មចម្រុះថ្នាក់តំបន់ អាចធានាឲ្យមានការផ្គត់ផ្គង់យ៉ាងទៀងទាត់និងទុកចិត្តបាននូវ កម្លាំងពលកម្មដែលសំខាន់បំផុតដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងក្នុងវិស័យប្រើពលកម្មច្រើន។ សម្រាប់ប្រទេសសំបូរពលកម្មដូចជា កម្ពុជា ឡាវ និង មីយ៉ាន់ម៉ា លំហូរអន្តរជាតិនៃពលករកាន់តែងាយស្រួល និងសេរី អាចជួយកាត់បន្ថយសំពាធភាពគ្មានការងារធ្វើ។ ដើម្បីសម្រេចកិច្ចការនេះ ជំហានដំបូង ត្រូវដាក់បញ្ចូលបញ្ហាទេសន្តរប្រវេសន៍ពលកម្មទៅក្នុងផែនការអភិវឌ្ឍន៍ធំទូលាយនៃ GMS ហើយបន្ទាប់មកបង្កើតជា វេទិកាអ្នកជំនាញមួយដើម្បីសិក្សាពីភាពអាចធ្វើបាន និងផ្តល់អនុសាសន៍ដល់អ្នកដឹកនាំ។

- **សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងចលនាពលកម្មដោយសេរី៖** ខុសប្លែកពីសហភាពអឺរ៉ុប អាស៊ានគ្មានចែងពីចលនាពលកម្មដោយសេរីទេ។ ថ្វីបើទេសន្តរប្រវេសន៍ និងការផ្លាស់ទី គួរកំណត់ជាបញ្ហាអាទិភាពក្នុងអាស៊ានក្តី ក៏កន្លងមកមានការពិភាក្សាតិចតួចអំពីលំហូរពលកម្ម ឬទេសន្តរប្រវេសន៍ នៅក្នុងកិច្ចប្រជុំនានានៃរដ្ឋមន្ត្រីការងារ។ នៅមុនឆ្នាំ២០០៧ គំនិតផ្តួចផ្តើមជាច្រើនអំពីទេសន្តរប្រវេសន៍ គឺសំដៅដោះស្រាយបញ្ហាជួញដូរមនុស្ស។ រហូត

8 ដកស្រង់ពី ILO (2008), *សហប្រតិបត្តិការអន្តររដ្ឋ ស្តីពីពលកម្មទេសន្តរប្រវេសន៍៖ មេរៀនពី MOU រវាងប្រទេសថៃ និងប្រទេសជិតខាង* ឯកសារពិភាក្សាលេខ 16 (ក្រុងបាងកក៖ អង្គការពលកម្មអន្តរជាតិ)។

មកដល់ឆ្នាំ២០០៧ ទើបមេដឹកនាំអាស៊ានបានចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពី កិច្ចការពារ និងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។ ប្រទេសជាច្រើនយល់ឃើញថា សេចក្តីប្រកាសរបស់អាស៊ាន ជាជំហានដំបូងដ៏សំខាន់សំដៅបង្កើនកិច្ចការពារ និងការគោរពសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការងាររបស់ គណៈកម្មាធិការអាស៊ានទទួលបន្ទុកការអនុវត្តសេចក្តីប្រកាស ដែលគេបានបង្កើតឡើងដើម្បីតាមដានការអនុវត្តសេចក្តីប្រកាស ដោយមានការអនុម័តផែនការសកម្មភាពមួយ ការតាក់តែងលិខិតុបករណ៍របស់អាស៊ានស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងបង្កើតវេទិកាអាស៊ានមួយស្តីពីទេសន្តរប្រវេសន៍ពលកម្ម ដើម្បីឱ្យមានការពិគ្រោះយោបល់យ៉ាងទៀងទាត់។

ទោះជាយ៉ាងនេះក្តី សេចក្តីប្រកាសរបស់អាស៊ានគ្មានភ្ជាប់កាតព្វកិច្ចជាផ្លូវការ និងគ្មានដាក់កាតព្វកិច្ចដល់រដ្ឋជាសមាជិកទេ។ អង្គការសង្គមស៊ីវិលបានផ្តល់អនុសាសន៍ថា លិខិតុបករណ៍ក្របខ័ណ្ឌអាស៊ានត្រូវតែមានភ្ជាប់កាតព្វកិច្ចជាផ្លូវការ ដោយឈរលើគោលការណ៍ស្នូល ៤យ៉ាងគឺ ទី១ ឯកសារគួរដាក់បញ្ចូល និងគ្របដណ្តប់លើពលករទេសន្តរប្រវេសន៍ទាំងអស់ក្នុងអាស៊ាន។ ទី២ គួរទទួលស្គាល់ថា កិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ជាភារកិច្ចរួមគ្នារបស់ប្រទេសបញ្ជូន និងប្រទេសទទួល។ ទី៣ គួរអនុលោមតាមគោលការណ៍មិនរើសអើងក្នុងការចាត់ចែងលើពលករទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ។ ទី៤ គួរមានការធានាថា គោលនយោបាយទេសន្តរប្រវេសន៍ និងការអនុវត្ត បានគិតគូរដល់បញ្ហាយេនឌ័រ។ គណៈកម្មាធិការអនុវត្ត បានធ្វើការងារលើលិខិតុបករណ៍ក្របខ័ណ្ឌ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ រដ្ឋមន្ត្រីការងារអាស៊ានគួរពិចារណាយ៉ាងល្អិតល្អន់លើអនុសាសន៍របស់គណៈកម្មាធិការ និងធ្វើការងារសំដៅឱ្យមានក្របខ័ណ្ឌភ្ជាប់កាតព្វកិច្ច។

បន្ថែមលើកិច្ចការពារសិទ្ធិពលករទេសន្តរប្រវេសន៍ អាស៊ានត្រូវធ្វើការសំដៅឱ្យមានលំហូរពលកម្មដោយសេរីនៅក្នុងតំបន់។ ឯកសារសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលជា ផែនការសកម្មភាពយុទ្ធសាស្ត្រមួយដើម្បីសម្រេចឲ្យបានសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ មានចែងតែអំពី លំហូរដោយសេរីនៃពលករមានជំនាញប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងលំហូរពលកម្មមួយភាគធំ គឺជាពលករគ្មានជំនាញ ដូច្នេះអាស៊ានគួរចាត់ទុកទេសន្តរប្រវេសន៍ជាកត្តាគន្លឹះសម្រាប់ការធ្វើសមាហរណកម្ម ដោយជួយសម្រួលដល់ចរាចរណ៍ដោយសេរីនៃពលករមានជំនាញ និងគ្មានជំនាញ។

# ៧ សេចក្តីសន្និដ្ឋាន

ថ្វីបើទេសន្តរប្រវេសន៍មិនស្របច្បាប់ បានក្លាយជាបញ្ហាសំខាន់មួយក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍អន្តរជាតិក្តី ក៏កន្លងមកមានការពិភាក្សាតិចតួចណាស់ពីបញ្ហានេះ នៅក្នុងបរិបទធំទូលាយនៃការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ បញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ ពុំមានចែងច្បាស់នៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ទេ ហើយក៏មិនបានទទួលកិច្ចការពារខាងសង្គមកិច្ច និងកិច្ចការពារតាមផ្លូវច្បាប់ឲ្យបានគ្រប់គ្រាន់ នៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួលដែរ។ កង្វះខាតផ្នែកគោលនយោបាយដ៏ធ្ងន់ធ្ងរនេះ នាំឱ្យទេសន្តរប្រវេសន៍មិនស្របច្បាប់ កើតមានឡើងយ៉ាងច្រើនដោយសឹងគ្មានការត្រួតពិនិត្យ និងមានហានិភ័យខ្ពស់នៃការរំលោភបំពាន ការកេងប្រវ័ញ្ច និងការជួញដូរមនុស្ស។ កម្ពុជាត្រូវតែកំណត់ថា ទេសន្តរប្រវេសន៍មិនស្របច្បាប់ វាសំខាន់ស្មើគ្នានឹង ទេសន្តរប្រវេសន៍ផ្លូវការ។ ដោយសារបញ្ហាជនទេសន្តរប្រវេសន៍មិនស្របច្បាប់ មានច្រើនពាសពេញ និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម គេត្រូវតែប្រឹងប្រែងដោះស្រាយវា។ ការគ្រប់គ្រងទេសន្តរប្រវេសន៍មិនស្របច្បាប់ វាស្មុគស្មាញ និងពិបាក ហើយជាការប្រសើរ គេត្រូវដោះស្រាយវាតាមវិធីសាស្ត្រ ផ្តោតលើបញ្ហាទាំងមូល និងគ្រប់ជ្រុងជ្រោយ ដែលមានទាំងគោលនយោបាយ និងអន្តរាគមន៍តាមកម្មវិធីនៅគ្រប់ដំណាក់កាលនៃទេសន្តរប្រវេសន៍ ដោយភាគីពាក់ព័ន្ធទាំងអស់។

ករណីសិក្សារបស់កម្ពុជាស្តីពីទេសន្តរប្រវេសន៍មិនស្របច្បាប់ បានផ្តល់លទ្ធផលស្របគ្នានឹងឯកសារអន្តរជាតិ ដោយស្នើឱ្យមានយ៉ាងហោចណាស់វិធានការបីបែបគឺ ការដោះស្រាយមូលហេតុ ការពង្រឹងកិច្ចការពារ និងការកែលម្អសហប្រតិបត្តិការអន្តរជាតិ។ វិធានការពីរបែបដំបូង ពាក់ព័ន្ធច្រើនដល់អធិបតេយ្យភាពជាតិ និងអាទិភាពអភិវឌ្ឍន៍ ក្នុងនេះមាន ការអភិវឌ្ឍសហគមន៍ ការកែលម្អក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើឱ្យទេសន្តរប្រវេសន៍ស្របច្បាប់កាន់តែមានតម្លាភាព និងងាយប្រើបាន និងការកែលម្អសេវាកម្មគាំទ្រលើការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និងកិច្ចការពារតាមផ្លូវច្បាប់។ វិធានការទីបី ពាក់ព័ន្ធដល់សហប្រតិបត្តិការទ្វេភាគី សហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ។ កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងប្រទេសទទួលពលករ លើការធ្វើឱ្យស្របច្បាប់ ឬធ្វើឱ្យទេសន្តរប្រវេសន៍ផ្លូវការកាន់តែងាយប្រើបាន អាចជាវិធានការមួយក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍មិនស្របច្បាប់ ។ ក្នុងរយៈពេលវែង ទេសន្តរប្រវេសន៍មិនស្របច្បាប់ អាចដោះស្រាយបានតាមរយៈ ទីផ្សារពលកម្មចម្រុះក្នុង GMS ដែលគាំទ្រដោយស្ថាប័ន និងច្បាប់ថ្នាក់អនុតំបន់ ក៏ដូចជាតាមរយៈ សហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលមានកំណត់ក្របខ័ណ្ឌច្បាប់មួយសម្រាប់លំហូរពលកម្មដោយសេរី។ ដើម្បីសម្រេចគំនិតផ្តួចផ្តើមថ្នាក់តំបន់នេះ មេដឹកនាំទាំងអស់ត្រូវចាត់ទុកទេសន្តរប្រវេសន៍ ជាពិសេសទេសន្តរប្រវេសន៍មិនស្របច្បាប់ ជាចំណែកមួយនៃទីផ្សារពលកម្មធំទូលាយ មិនមែនត្រឹមតែជាបញ្ហាសន្តិសុខ និងបញ្ហាផ្លូវច្បាប់ប៉ុណ្ណោះទេ។ ជោគជ័យនៃការគ្រប់គ្រងទេសន្តរប្រវេសន៍មិនស្របច្បាប់ នៅកម្ពុជា ត្រូវពឹងផ្អែកមិនត្រឹមតែលើលទ្ធភាពរបស់កម្ពុជាដើម្បីផ្លាស់ប្តូរ "ទេសន្តរប្រវេសន៍ដើម្បីរស់រាន" ទៅជា "ទេសន្តរប្រវេសន៍តាមការជ្រើសរើស" ប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យលើដំណោះស្រាយរបស់អង្គការថ្នាក់តំបន់ដូចជា GMS និងអាស៊ាន និងរបស់សហគមន៍អន្តរជាតិ ក្នុងបញ្ហានេះដែរ។

# ឯកសារយោង

Battistella, Graziano (2002), "Unauthorized Migrants as Global Workers in the ASEAN Region", *Southeast Asian Studies* 40(3), pp. 350–371

Brennan, M. Ellen (1984), "Irregular Migration: Policy Responses in Africa and Asia", *International Migration Review* 18(3), pp. 409–425

Chan, Sophal (2009), *Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study*, Working Paper No.47 (Phnom Penh: CDRI)

Chiuri, Concetta M., Giuseppe de Arcangelis & Giovanni Ferri (2005), *Crisis in Countries of Origin and Illegal Immigration into Europe via Italy* (Geneva: Global Commission on International Migration)

FitzGerald, Ingrid & Sovannarith So (2007), *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

Global Commission on International Migration (2005), *Migration in an Interconnected World: New Directions for Action* (Geneva: Global Commission on International Migration)

Hing, Vutha, Pide Lun & Dalis Phann (2011), "Labour Migration Situation and Policy Framework in Cambodia", *Annual Development Review 2010-2011*, pp. 83–102

International Council on Social Welfare (2007), *Trafficking and Related Labour Exploitation in the ASEAN Region* (Utrecht: ICSW)

International Labour Organisation (2010), *International Labour Migration: A Rights-based Approach* (Geneva: ILO)

International Organisation for Migration (2003), *Labour Migration in Asia: Trends, Challenges and Policy Responses in Countries of Origin* (Geneva: IOM)

International Organisation for Migration (2008), *World Migration Report 2008* (Geneva: IOM)

International Organisation for Migration (2010a), *Analyzing the Impact of Remittances from Cambodian Migrant Workers in Thailand on Local Communities in Cambodia* (Phnom Penh: IOM)

International Organisation for Migration (2010b), *World Migration Report 2010–The Future of Migration: Building Capacities for Changes* (Geneva: IOM)

Koser, Khalid (2005), *Irregular Migration, State Security and Human Security* (Geneva: Global Commission on International Migration)

Koslowski, Rey (2004), "Possible Steps towards an International Regime for Mobility and Security", paper presented to the Workshop on Global Mobility Regimes, Stockholm, June

Lee, Chen C. (2007a), "Exploitative Labour Brokerage Practices in Cambodia: The Role and Practices of Private Recruitment Agencies" (Unpublished Paper)

Lee, Chen C. (2007b), "Female Labour Migration in Cambodia" in United Nations Economic and Social Commission for Asia and the Pacific (ed.), *Perspectives on Gender and Migration* (Bangkok: United Nations)

Lee, Tang L. (2005), *Statelessness, Human Rights and Gender: Irregular Migrant Workers from Burma in Thailand* (Leiden: Koninklijke Brill NV)

LeVoy, Michele & Eve Geddie (2010), "Irregular Migration: Challenges, Limits and Remedies", *Refugee Survey Quarterly* 28(4), pp. 87–113

MacPherson, Douglas W. & Brian D. Gushulak (2004), *Global Migration Perspectives:*

*Irregular Migration and Health* (Geneva: Global Commission on International Migration)

Maltoni, Bruno (2006a), *Review of Labour Migration Dynamics in Cambodia* (Phnom Penh: IOM)

Maltoni, Bruno (2006b), "Impact of Remittances on Local Communities in Cambodia: The Case of Prey Veng Province" (World Bank: unpublished paper)

Marshall, Phil (2001). *Globalization, Migration and Trafficking: Some Thoughts from the South-East Asian Region,* (Kuala Lumpur: UN Inter-Agency Project on Trafficking in Women and Children in the Mekong Sub-region)

Massey, Douglas S., Joquin Arango, Graeme Hugo, Ali Kouaouci, Adela Pellegrino & Edward J. Taylor (1993), "Theories of International Migration: A Review and Appraisal", *Population and Development Review* 19(3), pp. 431–466

MLVT (2009), *Action Plan to Implement the Rectangular Strategy, Phase II 2009–2013* (Phnom Penh: Ministry of Labour and Vocational Training)

MLVT (2010), *Policy on Labour Migration for Cambodia* (Phnom Penh: Ministry of Labour and Vocational Training)

MWRM (2009), *Strategic Development Plan 2009-2013* (Phnom Penh: Ministry of Water Resource and Meteorology)

Naro, Neth (2009), *Human Trafficking in Cambodia: Reintegration of the Cambodian Illegal Migrants from Vietnam and Thailand*, Working Paper No 181 (Singapore: S. Rajaratnam School of International Studies)

Paitoonpong, Srawooth and Chothiga Sakuruji (forthcoming), *Managing International Labour Migration in ASEAN* (Bangkok: Thailand Development Research Institute)

RGC (1995), *Sub-Decree No.57 on Sending of Khmer Worker to Work Abroad* (Phnom Penh: Royal Government of Cambodia)

Rukumnuaykit, Pungpond (2006), *A Synthesis Report on Labour Migration Policies, Management and Immigration Pressure in Thailand* (Bangkok: International Labour Organisation)

Shah, Nasra (2009), *The Management of Irregular Migration and Its Consequences for Development: Gulf Cooperation Council,* Working Paper No.19 (Bangkok: International Labour Organisation)

Stoyanova, Mariya (2008), *Challenges of Irregular Migration* (Geneva: Friedrich Ebert Stiftung)

UN General Assembly, "Resolution 3449: Measure to Ensure the Human Rights and Dignity of All Migrant Workers", http://www.un.org/documents/ga/res/30/ares30.htm (accessed 27 August 2010)

UNIAP (2010), *Human Trafficking Sentinel Surveillance: Poipet, Cambodia 2009-2010* (Bangkok: United Nations Inter-Agency Project on Human Trafficking)

UNIAP report on human trafficking in Cambodia: http://www.humantrafficking.org/countries/cambodia (accessed 20 February 2011)

Vasuprasat, Pracha (2008), *Inter-state Cooperation on Labour Migration: Lessons learned from MOUs between Thailand and neighbouring countries,* Working Paper No.16 (Bangkok: International Labour Organisation)

World Bank (2011), *Migration and Remittance Factbook 2011,* Second Edition (Washington DC: World Bank)

# ឧបសម្ព័ន្ធ

## A. ឧបសម្ព័ន្ធផ្នែកស្ថិតិ

តារាង A ១៖ ពលករទេសន្តរប្រវេសន៍កម្ពុជាដែលបានបញ្ជូនទៅក្រៅជាផ្លូវការ

| ឆ្នាំ | ម៉ាឡេស៊ី | | | កូរ៉េ | | | ថៃ | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| 1998 | 120 | | 120 | | | | | | |
| 1999 | 86 | | 86 | | | | | | |
| 2000 | 502 | 307 | 195 | | | | | | |
| 2001 | 846 | 342 | 504 | | | | | | |
| 2002 | 1049 | 246 | 803 | | | | | | |
| 2003 | 573 | 73 | 500 | 756 | 638 | 118 | | | |
| 2004 | 809 | 105 | 704 | 674 | 519 | 115 | | | |
| 2005 | 1776 | 467 | 1309 | 468 | 432 | 36 | | | |
| 2006 | 1690 | 231 | 1459 | 1501 | 1341 | 160 | 4116 | 3222 | 894 |
| 2007 | 3081 | 174 | 2907 | 584 | 499 | 85 | 4846 | 3249 | 1957 |
| 2008 | 3432 | 53 | 3379 | 2531 | 2127 | 404 | 2991 | 1816 | 1175 |
| 2009 | 9682 | 876 | 8806 | | | | 3543 | 1968 | 1575 |
| សរុប | 23646 | 2874 | 20772 | 6514 | 5556 | 958 | 15496 | 10255 | 5241 |

ប្រភព៖ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

តារាង A ២៖ បញ្ជីរាយមុខចំណាយលើការបញ្ជូនពលករទៅប្រទេសថៃ

| មុខចំណាយ | ថ្លៃ (គិតជាដុល្លារ) |
|---|---|
| ***ចំណាយត្រូវបង់សម្រាប់ប្រទេសកម្ពុជា*** | 480 |
| លិខិតឆ្លងដែន | 150 |
| ការត្រួតពិនិត្យសុខភាព | 10 |
| ថ្លៃចាកចេញ | 5 |
| ការបណ្តុះបណ្តាល | 15 |
| ការធ្វើដំណើរ | 10 |
| ចំណូលភ្នាក់ងារជ្រើសរើសពលករ | 70 |
| ចំណាយផ្សេងៗ | 220 |
| ***ចំណាយត្រូវបង់ទៅឲ្យប្រទេសថៃ*** | 220 |
| លិខិតអនុញ្ញាតឲ្យធ្វើការ | 106 |
| សំណុំបែបបទសុំធ្វើការ | 3 |
| ការត្រួតពិនិត្យសុខភាព | 18 |
| ថ្លៃទិដ្ឋកា | 59 |
| ការធ្វើដំណើរទៅកន្លែងធ្វើការ | 20 |
| ចំណាយផ្សេងៗ | 14 |
| ***សរុប*** | 700 |

ប្រភព៖ Chan (2009)

តារាង A ៣៖ បញ្ជីរាយនាមអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករដែលទទួលអាជ្ញាប័ណ្ណ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១០

| ល.រ | ឈ្មោះ | ថៃ | ម៉ាឡេស៊ី | ជប៉ុន | អារ៉ាប់ គុយវ៉ែត & លីប៊ យ៉ា |
|---|---|---|---|---|---|
| 1 | Cambodia Labour Supply PTY., LTD | √ | √ | √ | |
| 2 | Human Resource Development Co., LTD | √ | √ | | √ |
| 3 | Philimore Cambodia Co., LTD | √ | √ | | |
| 4 | Human Power Co., LTD | √ | √ | | |
| 5 | Mey Yorn Service Co., LTD | √ | √ | | |
| 6 | Top Manpower Co., LTD | √ | √ | | |
| 7 | CDM Trading Manpower Co., LTD | √ | | | |
| 8 | Chhun Hong Manpower Co., LTD | √ | √ | √ | |
| 9 | Ung Rithy Group Co.,LTD | √ | √ | | |
| 10 | STP International Cambodia Public Co., LTD | √ | | | |
| 11 | (Cambodia) Victory Cooperation Co., LTD | √ | | √ | |
| 12 | C-Pro Co., LTD | √ | | √ | |
| 13 | VC Manpower Col, LTD | | √ | | |
| 14 | PRO CAST(Cambodia)Co., LTD | | | √ | |
| 15 | MALCAM Human Resource Management & Consultant Co., LTD | √ | √ | | |
| 16 | T& P Co., LTD | √ | √ | | |
| 17 | CECH Co., LTD | √ | √ | | |
| 18 | NGO ALC COMMUNICATION | | | √ | |
| 19 | NGO GCHCC | | | √ | |
| 20 | CJC Co., LTD | | | √ | |
| 21 | Equine Resources (Cambodia) Co., LTD | | √ | | |
| 22 | A.P.T.S.E&C(Cambodia)co., LTD | √ | √ | | |
| 23 | Job Asia | √ | √ | √ | |
| 24 | GPGC International Pte Co., LTD | √ | √ | √ | |
| 25 | Master Cam Human Resource Co., LTD | √ | √ | | |
| 26 | Unicorn Manpower Group Co., LTD | √ | √ | √ | |
| 27 | Champa Manpower Group LTD | √ | √ | √ | គុយវ៉ែត |
| 28 | SKMM Investment Group Co., LTD | √ | √ | √ | |
| | **TOTAL** | **22** | **20** | **12** | **2** |

ប្រភពៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ឧបសម្ព័ន្ធ B៖ អនុក្រឹត្យលេខ ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៖ ៥៧ អនុក្រ.បក

**អនុក្រឹត្យ**
ស្តីពី
ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩៩ក្រ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ១៩៩២
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

**សំរេច**

**មាត្រា ១៖** ដើម្បីដោះស្រាយជីវភាព និងបង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលអនុញ្ញាតអោយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស នៅពេលដែលទីផ្សារការងារក្នុងប្រទេសមិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និងអ្នកដែលមានការងារមិនពេញលេញបានអស់ និង រកប្រាក់ចំណូលចូលថវិកាជាតិ។

**មាត្រា ២៖** ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងការគ្រប់គ្រងពលករទាំងនេះ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងឱ្យក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសបាន។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចេញសារាចរណែនាំអនុវត្តបន្ថែមទៀតក្នុងករណីចាំបាច់។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការធ្វើទំរង់បែបបទ ដូចជាលិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិ

ការអន្តរជាតិក្នុងការគ្រប់គ្រងពលករខ្មែរដែលធ្វើការនៅបរទេស។

**មាត្រា ៣៖** ត្រូវបានចាត់ទុកជាបេក្ខជនសម្រាប់ជ្រើសរើសបញ្ជូនទៅធ្វើការនៅបរទេស ពលករខ្មែរទាំងពីរភេទ មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

**មាត្រា ៤៖** ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ហៅថាភាគីផ្តល់ពលករ។ ក្រុមហ៊ុនដែលស្នើសុំជ្រើស ពលករ ហៅថាភាគីទទួលពលករ។

**មាត្រា ៥៖** រាល់សំណើពីភាគីទទួលពលករ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ៗ ជាអាទិ៍៖

- កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និងបញ្ចប់ការងារ
- ប្រភេទការងារ
- ទីកន្លែងទៅធ្វើការងារ
- ចំនួន និងមុខជំនាញរបស់ពលករ
- ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល ព្រមទាំងបញ្ហា ផ្សេងៗទៀតក្នុងជីវភាពប្រចាំថ្ងៃ
- ការដឹកជញ្ជូនពលករទៅ និងមក។

ក្រោយពីបានទទួលសំណើ ភាគីផ្តល់ពលករត្រូវឆ្លើយទៅភាគីទទួលពលករវិញយ៉ាងយូរបំផុត ៤៥ថ្ងៃ ដោយត្រូវ បញ្ជាក់ថា តើអាចផ្តល់ពលករបានកំរិតណាឬមិនបាន ឬត្រូវពិភាក្សាគ្នាបន្ថែមទៀត។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ ៣០ថ្ងៃ ថាតើត្រូវការពលករទាំងអស់នោះឬទេ ឬ ត្រូវការតែកំរិតណាមួយនោះ ដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ។ ហួសរយៈពេល ៣០ថ្ងៃ ហើយ បើគ្មានចម្លើយ និងមិនឃើញចូលមកពិភាក្សាទេ ភាគីផ្តល់ពលករកំណត់ថា ភាគីទទួលពលករមិនត្រូវការពលករទាំង នោះទេ។

**មាត្រា ៦៖** ការបញ្ជូនពលករទៅបរទេស អាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតពីភាគីផ្តល់ពលករ និងត្រូវ មានកិច្ចសន្យាការងាររវាងពលករ ជាមួយភាគីទទួលពលករ។

**មាត្រា ៧៖** ក្រោយពេលទទួលការអនុញ្ញាតជាផ្លូវការរយៈពេល ៧ថ្ងៃយ៉ាងយូរ ភាគីទទួលពលករ ត្រូវតំកល់ ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិកនៅក្នុងគណនីរបស់ភាគីផ្តល់ពលករ។ បើភាគីទទួលពលករមិនបានបង់ ប្រាក់ធានានេះទេ ការអនុញ្ញាតនេះនឹងត្រូវចាត់ទុកជាមោឃៈ។

ប្រាក់តំកល់នេះ សម្រាប់ឱ្យភាគីផ្តល់ពលករបើកឱ្យពលករជំនួសភាគីទទួលពលករ ក្នុងករណីដែលភាគីនេះមិន បានគោរពល័ក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះត្រូវបានដក់ខ្លះ ដើម្បីឱ្យពលករ ភាគីទទួលពលករត្រូវបង់ បំពេញឱ្យបានគ្រប់ចំនួនឡើងវិញ។

ភាគីទទួលពលករអាចដកប្រាក់តំកល់នេះទៅវិញបាន នៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករ ទាំងអស់។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបាន ចំពោះនិយោជកដែលត្រូវការជ្រើសរើសពលករខ្មែរតែបន្តិចបន្តួច ដោយផ្ទាល់ ដើម្បីយកទៅធ្វើការក្នុងរោងជាង ឬរោងសិប្បកម្មរបស់ខ្លួន។ ប៉ុន្តែនិយោជកនោះ ចាំបាច់ត្រូវពិភាក្សាជាមួយ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភូតជាមួយពលករទាំងនោះ។

**មាត្រា ៨៖** ភាគីទទួលពលករ ត្រូវបង់សោហ៊ុយសេវា និងការរៀបចំឯកសារផ្សេងៗជូនភាគីផ្តល់ពលករតាមការ ឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា។

**មាត្រា ៩៖** កិច្ចសន្យាការងារ ត្រូវបញ្ជាក់ឱ្យច្បាស់ ជាអាទិ៍៖

- ឈ្មោះ និងអាស័យដ្ឋានរបស់ភាគីនីមួយៗ
- កាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់កិច្ចសន្យា
- ទីកន្លែង និងប្រភេទការងារជាក់ស្តែង
- មុខជំនាញពលករ
- ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ
- ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដែលត្រូវបញ្ជូនមកគ្រួសារ
- ពេលម៉ោងធ្វើការ និងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល
- ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ៗ
- ការប្រគល់ និងទទួលពលករពេលទៅ និងពេលត្រឡប់មកវិញ
- សោហ៊ុយដឹកជញ្ជូនពលករទៅ និងមក
- ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ។

**មាត្រា ១០៖** ពលករទាំងអស់ ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលដែលភាគីទទួលពលករត្រូវចេញឱ្យ។ ឯចំនួនថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះយ៉ាងតិចក្នុងរយៈពេលធ្វើការមួយខែជាប់។

**មាត្រា ១១៖** កិច្ចសន្យាការងារ ត្រូវធ្វើជាពីរភាសាដែលមានតំលៃស្មើគ្នា គឺភាសាខ្មែរ និងភាសាបារាំង ឬអង់គ្លេស។ រយៈពេលនៃកិច្ចសន្យាការងារ មិនត្រូវឱ្យលើសពីពីរឆ្នាំឡើយ។

នៅពេលចប់អាណត្តិនៃកិច្ចសន្យាការងារ ភាគីទាំងពីរអាចពិភាក្សាគ្នាបន្តអនុវត្តកិច្ចសន្យាទៅទៀតបាន ឬមួយធ្វើកិច្ចសន្យាសាថ្មី។ កិច្ចសន្យាបន្តការងារតទៅទៀត ឬធ្វើសាជាថ្មី ក៏ត្រូវមានការចុះទិដ្ឋាការសាថ្មីពីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនដែរ។

**មាត្រា ១២៖** ភាគីផ្តល់ពលករ ជាអ្នកជ្រើសរើសពលករតាមមុខជំនាញនីមួយៗឱ្យបានគ្រប់ចំនួនដែលបានកំណត់ក្នុងកិច្ចសន្យាការងារ។

កិច្ចសន្យាការងារដែលពលករចុះហត្ថលេខាជាមួយភាគីទទួលពលករ ត្រូវមានចុះទិដ្ឋាការរបស់អធិការការងារមានសមត្ថកិច្ច។

**មាត្រា ១៣៖** នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ៗ ត្រូវផ្តល់៖

- ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤x៦ ស.ម ២ សន្លឹក
- សំបុត្រថ្កោលទោស ២ ច្បាប់
- លិខិតបញ្ជាក់សុខភាព ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ ២ ច្បាប់
- សេចក្តីចម្លងសញ្ញាប័ត្រ ឬលិខិតបញ្ជាក់មុខជំនាញ (បើសិនជាមាន) ២ ច្បាប់
- សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន ២ ច្បាប់
- ប័ណ្ណសុំការងារ ១ ច្បាប់

**មាត្រា ១៤៖** មុនពេលចេញដំណើរទៅបរទេស ភាគីផ្តល់ពលករនិងទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងារ របៀបរបបរស់នៅ ទំនៀមទំលាប់ប្រពៃណី និងច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ។

**មាត្រា ១៥៖** ប្រាក់បៀវត្សរបស់ពលករម្នាក់ៗត្រូវជាប់ពន្ធតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៦៖** ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយឱ្យមន្ត្រីរបស់ប្រទេសផ្តល់ពលករទៅបំពេញបេសកកម្ម ដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករ ត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ទីកន្លែងធ្វើការងារ និងទីស្នាក់អាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការអនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈពេលដែលចាំបាច់។

**មាត្រា ១៧៖** បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សា និងដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកទៅលើកិច្ចសន្យាការងារ។ បើការពិភាក្សាគ្នានេះ មិនអាចសំរុះសំរួលគ្នាបានទេនោះ គេត្រូវផ្តល់ព័ត៌មានភ្លាមទៅស្ថានឯកអគ្គរាជទូត ឬបេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ។

**មាត្រា ១៨៖** ភាគីទទួលពលករ ត្រូវផ្តល់ព័ត៌មានដល់ភាគីផ្តល់ពលករឱ្យបាន ៤៥ថ្ងៃ មុនកាលបរិច្ឆេទនៃការវិលត្រឡប់មកមាតុប្រទេសវិញពិតប្រាកដរបស់ពលករ។

ភាគីទទួលពលករ និងភាគីផ្តល់ពលករ ត្រូវរៀបចំរួមគ្នាអំពីប្រតិទិននៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។

**មាត្រា ១៩៖** ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូត ឬបេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និងមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២០៖** ជនណាដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ដោយល្មើសនឹងបទបញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា ២១៖** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២២៖** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ត្រា និងហត្ថលេខា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

កន្លែងទទួលៈ
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា ២២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលម្អ* (ឯកសារពិភាក្សា លេខ ១) ជាភាសាខ្មែរ តម្លៃ ៤.០០០ រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ជាភាសាខ្មែរ ៤.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សា លេខ ៣) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិច្ចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារ ពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,៥០ដុល្លារ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ច តំបន់សម្រាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍ កម្ពុជា* (ឯកសារពិភាក្សា លេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិត គ្រួសារនៅក្នុង ភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមាន ផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនRDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ ៤.៥០០រៀល ជាភាសាអង់គ្លេស ៤,៥០ដុល្លារ។

១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្ដាប្រទេស អាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។

១៣. អ៊ឹង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកម្ពស់អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សា លេខ ១៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍ សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៦. ស៊ិក ប៊ូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យ វិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,០០ដុល្លារ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៨,០០ដុល្លារ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ* (ឯកសារពិភាក្សា លេខ១៨) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៧,០០ដុល្លារ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតម្លៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២១. Bhargavi Ramamurthy ស៊ិក-ប៊ូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តម្លៃ ៨.០០០រៀល។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាម ជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ១០.០០ដុល្លារ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជរ័ទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣០. Caroline Hughes និង គឹម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥០ដុល្លារ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣១) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥០ដុល្លារ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ។

៣៤. ប៉ក់-គឹមជឿន ហ៊ីង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦,០០ដុល្លារ។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស តម្លៃ ៤,០០ដុល្លារ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣៦) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥០ដុល្លារ។

៣៧. ចែម ផល្លា និងអ្នកផ្សេងទៀត (ឧសភា 2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៨. ប៉ក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៩. ហ៊ីង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤០. អេង នេត្រា និង David Craig (មីនា ២០០៩), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិនចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ។

៤២. ធន់ វិមាលា អ៊ូ ស៊ីវហួច អេង នេត្រា និង លី តឹម (តុលា 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៤៥. ការបោះពុម្ពរបស់ CDRI (ធ្នូ 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៦. ការបោះពុម្ពរបស់ CDRI (ធ្នូ 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៧. ជា ជូ (សីហា 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៨. ការបោះពុម្ពរបស់ CDRI (សីហា 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី (ឧសភា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៥០. ប៉ក់ គឹមជឿន (ឧសភា ២០១១), *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់* ជាភាសាអង់គ្លេសតម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths (មិថុនា ២០១១), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥២. អ៊ួច ច័ន្ទតារ៉ានី សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (សីហា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាអង់គ្លេស តម្លៃ ៣,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៥៣. Chann Sopheak, Nathan Wales and Tim Frewer (August 2011), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៥៤. ណាំង ភិរុណ ខៀវ ដារ៉ាវី, Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១), *លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ ១២.០០០រៀល។

៥៥. គឹម សុធន ឈឹម ឈន់ ថេង វុទ្ធី និង សូ សុវណ្ណារិទ្ធ (កក្កដា ២០១១), *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៥៦. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៧. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។




**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315 ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា

☎ (855-23) 881-384/881-701/881-916/883-603/012 867-278

(855-23) 880-734

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh



តម្លៃ ១០.០០០៛

9 789996 352515